សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវរបស់អនីតិជន

# ក្នុងរឿងក្ដីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អ៊ុត សុផានីត**

កញ្ញា **អ៊ុំ ស៊ិនសារណា**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៧

ជំនាន់ទី ២១

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **អ៊ុត សុផានីត** និងនាងខ្ញុំឈ្មោះ **អ៊ុំ ស៊ិនសារណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ជំនាន់ទី ២១ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៧-២០២១។

## សូមសម្តែងការវគិច្ច និងកតញ្ញូតាធម៌ជូនចំពោះ

**លោកឪពុក និងអ្នកម្តាយ** ជាអ្នកមានគុណយ៉ាងធំធេង ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ទំនុកបម្រុងកូនតាំងពីតូចក្រូចឆ្មា រហូតដល់កូនអាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្រមកដល់សព្វថ្ងៃនេះ។ បើគ្មានការយកចិត្តទុកដាក់ ថ្នាក់ថ្នម ស្រលាញ់ពីអ្នកមានគុណទេ ម្ល៉េះកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ។ នេះជាគុណូបការៈដ៏វិសេសវិសាល ដែលមិនអាចយកអ្វីមកកាត់ថ្លៃបាន។

ឯកឧត្តម **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រចារ្យទាំងអស់ដែលបានបំពេញការងារ ក្នុងការគ្រប់គ្រង ដឹកនាំ បង្ហាត់បង្ហាញផ្លូវ និងជួយតម្រង់ទិសពួកយើងខ្ញុំ ដោយមិនខ្លាចនឿយហត់ដោយអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីចូលរួមបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពពេញលេញ មុននឹងឈានទៅដល់ការប្រកបវិជ្ជាជីវៈនាថ្ងៃអនាគត។

លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រដែលបានចំនាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំ និងជ្រោមជ្រែង រហូតដល់ការរៀបរៀងសារណានេះអាចលេចចេញជាផ្លែផ្កាមក។ ទោះបីជាលោករវល់នឹងកិច្ចការលោកយ៉ាងណាក្តី ក៏លោកតែងតែផ្តល់ស្នាមញញឹមរីករាយស្វាគមន៍ជានិច្ច ក្នុងការជួយបង្ហាត់បង្ហាញ និងផ្តល់មតិដើម្បីកែតម្រូវកំហុសឆ្គងមួយចំនួន ក្នុងការសរសេរសារណានេះ ព្រមទាំងអនុសាសន៍ល្អៗដែលលោកបានផ្តល់ឲ្យរូបយើងខ្ញុំទាំងពីរដើម្បីយកមកពិចារណា។

កញ្ញា **ខែម មួយគី** ជាចៅក្រមសាលាដំបូង ខេត្តសៀមរាប ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការផ្តល់គំនិតយោបល់ និងដំបូន្មានល្អៗដល់យើងខ្ញុំទាំងពីរនាក់ក្នុងការធ្វើសារណាមួយនេះ ឱ្យកាន់តែមានភាពល្អប្រសើរ។

ជាកិច្ចចុងក្រោយ យើងខ្ញុំទាំងពីររូប សូមជូនពរឲ្យអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិកបម្រើការងានៅសកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងនិស្សិតទាំងអស់ឲ្យមានសុខភាពល្អ សម្រេចជោគជ័យគ្រប់ភារកិច្ចដូចអ្វីដែលបានប៉ងប្រាថ្នា និងសូមជូនពរឲ្យជួបប្រទះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតពីរូបយើងខ្ញុំទាំងពីរនាក់។

# អារម្ភកថា

ជាកិច្ចចាប់ផ្ដើម ខ្ញុំបាទឈ្មោះ **អ៊ុត សុផានីត** និងនាងខ្ញុំឈ្មោះ **អ៊ុំ ស៊ិនសារណា** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានក្ដីសោមនស្ស រីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សា។ រូបយើងខ្ញុំទាំងពីរសូមធ្វើការស្វាគមន៍យ៉ាងកក់ក្ដៅដល់ប្រិយមិត្តអ្នកអានគ្រប់ទិសទី ជាពិសេសនិស្សិតជាទីរាប់អាន និងសាស្ត្រចារ្យជាទីគោរព។

សារណានេះមានចំណងជើងថា «**ការទទួលខុសត្រូវរបស់អនីតិជនក្នុងរឿងក្ដីព្រហ្មទណ្ឌ**» មានគោលបំណងឲ្យអ្នកអានបានយល់ដឹងស៊ីជម្រៅពីសិទ្ធិជាមូលដ្ឋានរបស់អនីតិជន ព្រមទាំងនីតិវិធី និងទោសព្រហ្មទណ្ឌដែលអនុវត្តលើអនីតិជន ដែលកើតមានឡើងនាពេលបច្ចុប្បន្ននេះ។ នេះជាការកើតចេញពីសមិទ្ធផលនៃការខិតខំស្រាវជ្រាវ និងរៀបចំចងក្រងឡើង ដោយផ្អែកលើច្បាប់ និងបទដ្ឋានគតិយុត្តនានា ដើម្បីឲ្យប្រធានបទនេះប្រកបដោយសុក្រឹតភាព ហើយម្យ៉ាងវិញទៀត វាក៏ជួយឲ្យនិស្សិតបានសិក្សាផ្នែកមួយជ្រុងនៃបច្ចុប្បន្នភាពនៃច្បាប់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្ដមសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជំរុញទឹកចិត្ត និងបង្ហាត់បង្ហាញ ឆ្លៀតពេលវេលាក្នុងការណែនាំដល់រូបខ្ញុំទាំងពីររហូតអាចបញ្ចប់ការសរសេរសារណានេះ។

នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើនក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗដែលមានស្រាប់នៅក្នុងបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះអាចជាចំណែកនៃគុណប្រយោជន៍តូចមួយ ដើម្បីជាជំនួយដល់ការសិក្សាស្រាវជ្រាវបន្ថែមរបស់និស្សិតជំនាន់ក្រោយដែលមានបំណងក្នុងការសិក្សាស្វែងយល់នូវប្រធានបទនេះ។ យើងខ្ញុំយល់ថា ការសរសេរ និងរៀបរៀងសរសេរសារណានេះ អាចនៅមានចំនុចខ្វះខាតទាំងពាក្យពេចន៍ និងខ្លឹមសារ មិនទាន់ពេញលេញនៅឡើយទេ ដូច្នេះហើយ យើងខ្ញុំសូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំស្វាគមន៍ទទួលមតិរិះគន់ជានិច្ចពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើជាទុនក្នុងការស្ថាបនាឲ្យសារណានេះកាន់តែមានអត្ថន័យត្រឹមត្រូវ និងកាន់តែប្រសើរថែមមួយកម្រិតទៀត។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិត និងអ្នកអានជួបតែសុខដុមរមនា និងជោគជ័យគ្រប់ភារកិច្ច។ យើងខ្ញុំសង្ឃឹមថាយុវជន យុវនារីខ្មែរនឹងខិតខំសិក្សាស្រាវជ្រាវ ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្ដានុពលក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

## ជំពូកទី១
## សញ្ញាណទូទៅពាក់ព័ន្ធនឹងអនីតិជន

១.១ សិទ្ធិ និងគោលការណ៍ជាមូលដ្ឋាន ........................................ ៥

១.១.១ សិទ្ធិជាមូលដ្ឋានរបស់អនីតិជន ........................................ ៥

១.១.២ គោលការណ៍មូលដ្ឋានអនុវត្តលើអនីតិជន ........................................ ៦

១.២ លក្ខខណ្ឌគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ........................................ ៧

១.២.១. ការកំណត់នីតិភាពនៃអនីតិជនក្នុងការទទួលខុសត្រូវ ........................................ ៨

១.២.២. លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អនីតិជន ........................................ ១០

១.៣ តួអង្គសំខាន់ៗដែលមានវត្តមាន និង វិធានបង្វែរ ........................................ ១៤

១.៣.១ តួអង្គសំខាន់ៗចូលរួម ........................................ ១៤

១.៣.២ វិធានការបង្វែរ ........................................ ១៦

## ជំពូកទី២
## ដំណាក់កាលនីតិវិធីនៃការអនុវត្តចំពោះអនីតិជន

២.១ ដំណាក់កាលនៃការស៊ើបអង្កេត និងការចោទប្រកាន់ ........................................ ១៩

២.១.១ ដំណាក់ការស៊ើបអង្កេតដោយនគរបាលយុត្តិធម៌ ........................................ ១៩

២.១.២ ដំណាក់កាលចោទប្រកាន់ដោយអង្គការអយ្យការ ........................................ ២៤

២.២ ដំណាក់កាលនៃការស៊ើបសួរ និងការជំនុំជម្រះ ........................................ ២៦

២.២.១ ដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ ........................................ ២៦

២.២.២ ដំណាក់កាលជំនុំជម្រះដោយសាលាដំបូង និងតុលាការជាន់ខ្ពស់ ........................................ ៣០

## ជំពូកទី៣

## ការអនុវត្តទោសចំពោះអនីតិជន


៣.១ ការពិន័យចំពោះអនីតិជន............................................................................................................ ៣៥

៣.១.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ ........................................................................................ ៣៥

៣.១.២ ការរួចខ្លួនពីការបង្ខំដល់រូបកាយ......................................................................................... ៣៥

៣.២ ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលឃុំនីតិសម្បទា............................................................ ៣៦

៣.២.១ ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ ..................................................................................... ៣៧

៣.២.២ ការឃុំខ្លួនអនីតិជនក្នុងមណ្ឌលឃុំនីតិសម្បទា ..................................................................... ៣៨

៣.៣ ការផ្តល់ ការមាននីតិសម្បទាឡើងវិញ និងការដោះលែងដោយមានលក្ខខណ្ឌ ................................. ៤១

៣.៣.១ ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ .......................................................................... ៤១

៣.៣.២ ការដោះលែងដោយមានលក្ខខណ្ឌ...................................................................................... ៤៣

**សេចក្តីសន្និដ្ឋាន** ...................................................................................................................... ៤៥

**អនុសាសន៍** ............................................................................................................................... ៤៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

## ១. បុព្វហេតុនៃការសិក្សា

នៅក្នុងសង្គមមួយ វាជារឿងចៀសមិនផុតទេ ដែលទំនាក់ទំនងរវាងមនុស្សនឹងមនុស្សត្រូវបានចងភ្ជាប់ឡើង មានទាំងបុគ្គលល្អដែលជាធនធានមនុស្សប្រកបដោយសក្ដានុពលសម្រាប់ប្រទេសជាតិ មានទាំងបុគ្គលមួយចំនួនតូចដែលបង្កការរំខាន អំពើអស្ថិរភាព អសន្ដិសុខ ឬភាពវឹកវរដល់សង្គមជាតិ។ នេះជាមូលហេតុមួយដែលញ៉ាំងឲ្យច្បាប់ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងសកម្មភាពនានារបស់មនុស្ស ទោះបីជាពួកគេមានសិទ្ធិសេរីភាពពេញលេញក៏ដោយ ប៉ុន្តែការប្រើប្រាស់សិទ្ធិនេះត្រូវស្របតាមការចែងរបស់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗពោលគឺ ពលរដ្ឋពុំអាចធ្វើអ្វីតាមទំនើងចិត្តដែលហួសនឹងព្រំដែននៃច្បាប់ ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិដទៃ និងសង្គមបានឡើយ។ ជាក់ស្ដែងបុគ្គលមួយចំនួនបានប្រព្រឹត្តបទល្មើស ដូចជា លួច ឆក់ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ អំពើឃាតកម្ម អំពើហិង្សា ដែលបង្កភាពអនាធិបតេយ្យជាខ្លាំងដល់សង្គម ដូច្នេះហើយទើបប្រទេសកម្ពុជាបានផ្ដួចផ្ដើមបង្កើតនូវ «ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា» ដើម្បីកំណត់ពីប្រភេទបទល្មើស និងការអនុវត្តទោសទៅលើជនល្មើស។ ចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើស ត្រូវតែទទួលទោសនូវអំពើដែលខ្លួនបានប្រព្រឹត្ត ព្រោះនេះជាសញ្ញាមួយបង្ហាញថា វាជាគំរូមួយមិនល្អសោះ ដែលពលរដ្ឋផ្សេងទៀតពុំគួរយកតម្រាប់តាមនោះឡើយ ហើយបុគ្គលដែលបានជាប់ទោសហើយប្រាកដជាលែងមានសិទ្ធិសេរីភាព រស់នៅតែក្នុងបន្ទប់បួនជ្រុងតូចចង្អៀត ដើម្បីធ្វើការកែប្រែ ពិចារណាអំពើរបស់ខ្លួនឡើងវិញ និងវៀងចាលឈប់ប្រព្រឹត្តិទង្វើដែលសង្គមស្អប់ខ្ពើមបែបនេះទៀត។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរូបវន្តបុគ្គលសំដៅទៅលើនីតិជន និងអនីតិជន។ **នីតិជន** សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ រីឯ**អនីតិជន** សំដៅទៅជនដែលមានអាយុតិចជាង ១៨ ឆ្នាំ នៅពេលជននេះបានប្រព្រឹត្តបទល្មើស។ ដោយឡែកចុះបើអនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌវិញ តើអនីតិជនត្រូវទទួលខុសត្រូវបែបណា ហើយច្បាប់ត្រូវអនុវត្តដាក់ទោសយ៉ាងដូចម្ដេច?

ជាការពិតណាស់ បុគ្គលដែលប្រព្រឹត្តបទល្មើសពុំអាចរួចផុតពីសំណាញ់នៃច្បាប់នោះឡើយ ប៉ុន្តែដោយឡែក បើយើងក្រឡេកទៅមើលករណីពិសេសមួយគឺ អនីតិជនដែលបានប្រព្រឹត្តបទល្មើសហើយ បែរជាអាចរួចផុតពីការទទួលខុសត្រូវនៃព្រហ្មទណ្ឌ ឬទទួលការខុសត្រូវក្នុងកម្រិតណាមួយកំណត់ដោយច្បាប់ខុសពីរូបវន្តបុគ្គលជានីតិជន ព្រោះថាអនីតិជនមានសិទ្ធិពិសេសការពារដោយច្បាប់ ហើយ «**ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន**» នោះត្រូវបានយកមកសំអាងក្នុងការកំណត់សិទ្ធិជាមូលដ្ឋាន កំណត់នីតិភាពនៃការទទួលខុសត្រូវ និងនីតិវិធីនៃការអនុវត្តទោសនេះ។ កុមារ ឬក៏យើងហៅថា អនីតិជន ជាជនដែលមានអាយុក្រោម១៨ឆ្នាំ ស្ថិតនៅក្នុងវ័យមួយដែលកំពុង

អភិវឌ្ឍទាំងផ្នែកខួរក្បាលស្មារតី និងសរីរាង្គ ហើយកាលណាអនីតិជនទទួលបានឥទ្ធិពលល្អ នោះគេនឹងក្លាយជាក្មេងល្អ ប៉ុន្តែប្រសិនបើគេទទួលបានឥទ្ធិពលអាក្រក់ក៏ធ្វើឲ្យគេប្រព្រឹត្តរឿងមិនល្អដែរ។ ឥទ្ធិពលទាំងនោះអាចកើតចេញពីមជ្ឈដ្ឋានជុំវិញខ្លួន ដូចជាការអូសទាញពីមិត្តភក្តិ ស្ថានភាពគ្រួសារមិនអំណោយផល កម្រិតនៃចំណេះដឹង និងកម្រិតនៃការអប់រំជាដើម។ ដោយសារឥទ្ធិពលទាំងនោះ បូកបញ្ចូលទាំងសមត្ថភាពនៃការគិតនៅមានកម្រិត ជាហេតុដែលអនីតិជនពុំអាចពិចារណា ត្រិះរិះ ថ្លឹងថ្លែងថា អ្វីដែលល្អ អ្វីដែលអាក្រក់ ពោលគឺគេស្ថិតនៅវ័យឈោមរាវចូលចិត្តសាកល្បងអ្វីថ្មីៗសម្រាប់ខ្លួន ទោះបីសកម្មភាពនោះបង្កគ្រោះថ្នាក់ក៏ដោយ។ ឧទាហរណ៍ ក្មេងអាយុ១៥ឆ្នាំម្នាក់ ដោយសារតែគេមានបញ្ហាគ្រួសារ ហើយឪពុកម្តាយមិនបានអប់រំដិតដល់ ការសិក្សាក៏មិនពូកែ ពុំមានមិត្តភក្តិចង់រាប់អាន គេក៏ទៅរាប់អានមនុស្សខុសដែលអូសទាញឲ្យប្រព្រឹត្តអំពើខុសច្បាប់។

ប្រទេសនីមួយៗមានការកំណត់កម្រិតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ដោយយោងទៅលក្ខណៈពិសេសនៃគោលការណ៍ព្រហ្មទណ្ឌ ការីកចំរើនផ្នែករាងកាយ និង ប្រាជ្ញស្មារតីរបស់អនីតិជននោះផងដែរ។ បើយើងក្រឡេកទៅមើលក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រង់បញ្ញត្តិនៃមាត្រា ៣៨ បានចែងថា «នីតិភាពនៃការទទួលខុសត្រូវខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់កំរិតអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ» ប៉ុន្តែតុលាការក៏អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ឡើងទៅបានផងដែរ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ តុលាការនឹងធ្វើការវិនិច្ឆ័យ និងសម្រេចដោយផ្អែកលើទល្បីករនានាពាក់ព័ន្ធនឹងអនីតិជន ស្របនឹងគោលការណ៍នីត្យានុកូល មុននឹងសម្រេចថាត្រូវដាក់ទោសបែបណាចំពោះអនីតិជន។ ការអនុវត្តទោសព្រហ្មទណ្ឌលើអនីតិជនមានបញ្ហាស្មុគស្មាញ និងដំណាក់កាលនីតិវិធីជាច្រើន ដោយមានការចូលរួមពីមន្ត្រីនគរបាល ចៅក្រម តុលាការ អមជាមួយវត្តមាននៃភាគីពាក់ព័ន្ធរបស់អនីតិជន ដើម្បីធានាថាការសម្រេចរបស់យុត្តាធិការមានភាពត្រឹមត្រូវ និងសុក្រិតភាព។ ដំណាក់កាលនីមួយៗត្រូវគោរពតាមគោលការណ៍នីតិវិធីកុមារមេត្រី ដែលជានីតិវិធីសំខាន់សម្រាប់យកមកអនុវត្តលើអនីតិជនដោយផ្តល់បរិយាកាសឲ្យអនីតិជនមានភាពកក់ក្តៅ សុវត្ថិភាព អាចយល់ និងឆ្លើយតបក្នុងភាសាសាមញ្ញងាយស្រួលយល់។ ក្រៅពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ អនីតិជនអាចទទួលខុសត្រូវលើសំណងរដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬការដាក់ទណ្ឌកម្មផ្សេងទៀត តាមរយៈការដាក់ពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ដើម្បីផ្តល់ការអប់រំណែនាំដល់អនីតិជននោះ ឲ្យដឹងពីកំហុសរបស់ខ្លួន និងបន្ទាប់ពីការអនុវត្តទោសនោះ អនីតិជននឹងបញ្ជូនទៅរស់នៅក្នុងសង្គមវិញដើម្បីកសាងខ្លួនជាពលរដ្ឋល្អដែលមានប្រយោជន៍សម្រាប់សង្គម គ្រួសារ និងមិត្តភក្តិ។

តាមរយៈបុព្វហេតុខាងលើ យើងអាចស្វែងយល់ពីចំនុចសង្ខេបនានាពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អនីតិជន ហើយក៏ជាមូលហេតុដែលយើងខ្ញុំសម្រេចលើកយកប្រធានបទ «**ការទទួលខុសត្រូវរបស់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ**» យកមកធ្វើការស្រាវជ្រាវបន្ថែម ដើម្បីពង្រីកនូវចំណេះដឹងទាក់ទងនឹងសិទ្ធិ នីតិវិធីទៅលើការអនុវត្តទោសអនីតិជនទៅរឿងក្តីព្រហ្មទណ្ឌ ឲ្យបានកាន់តែទូលំទូលាយ និងជ្រួលជ្រាបដល់អ្នកអានបន្ថែមទៀត។

## ២. ចំណោទបញ្ហា

បញ្ហាចោទដែលយើងខ្ញុំនឹងលើកឡើងនៅក្នុងប្រធានបទនេះ តើនីតិវិធី និងទោសពិសេសត្រូវបានយកមកអនុវត្តយ៉ាងដូចម្តេចខ្លះ លើអនីតិជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទ «**ការទទួលខុសត្រូវរបស់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ**» មានគោលបំណងស្រាយបំភ្លឺនូវចំណោទគតិយុត្តដែលលើកឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អនីតិជន ពោលគឺ បកស្រាយឲ្យអ្នកអានបានស្វែងយល់ពី សិទ្ធិ និងផលប្រយោជន៍របស់អនីតិជនត្រូវបានការពារដោយយុត្តិធម៌ នៅពេលគាត់បានដើរខុសគន្លងក៏ដោយ ក៏ដូចជាការពារផលប្រយោជន៍របស់សង្គមជាតិប្រកបដោយចីរភាព និងស្ថេរភាព។ ប្រធានបទនេះក៏មានគោលបំណងក្នុងការគាំទ្រដល់ការស្តានីតិសម្បទាចំពោះអនីតិជន ដើម្បីអាចឲ្យអនីតិជនបានធ្វើការអប់រំកែប្រែ ទទួលបានកិច្ចគាំពារ និងថែទាំ ឬការដាក់កម្រិតទោសឲ្យបានសមស្របនឹងអាយុ លក្ខខណ្ឌជាក់ស្តែងរបស់អនីតិជន។ លើសពីនេះ យើងខ្ញុំចង់លើកយកវិស័យព្រហ្មទណ្ឌនេះ មកបញ្ជ្រាបទៅដល់គ្រប់ស្រទាប់វណ្ណៈប្រជាជនខ្មែរឲ្យមានការស្វែងយល់ពីសិទ្ធិដែលខ្លួនមាន និងដែនកំណត់ក្នុងការធ្វើសកម្មភាពរបស់ខ្លួនឲ្យស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ដើម្បីប្រទេសជាតិរីកចម្រើន។

## ៤. ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះមានវិសាលភាពគ្របដណ្តប់លើបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុវត្តទៅលើអនីតិជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅលើទឹកដីប្រទេសកម្ពុជា ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។ ជាពិសេស ប្រធានបទ «**ការទទួលខុសត្រូវរបស់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ**» នេះនឹងលើកយក រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងឯកសារនានាដែលពាក់ព័ន្ធដែលមានអនុភាពគតិយុត្តមកគ្របដណ្តប់លើប្រធានបទនេះ។ យើងនឹងផ្តោតសំខាន់ទៅលើច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ ដើម្បីលើកឡើងពីនីតិវិធី និងទោសដែលអនុវត្តលើអនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌនេះ។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានរៀបរៀងឡើងដោយលើកយកច្បាប់ បទដ្ឋានគតិយុត្តមកបកស្រាយពណ៌នាដោយផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពជាក់ស្តែងនៅក្នុងសង្គមយកមកធ្វើការវិភាគពិចារណា ដោយការសំអិតសំអាង មានអំណះអំណាងត្រឹមត្រូវ និងច្បាស់លាស់។ ព័ត៌មាន ទិន្នន័យ ដែលយកមកលើកឡើងមានប្រភពពីស្ថាប័នអនុម័តច្បាប់ និងដកស្រង់ពីរូបវន្តបុគ្គលស្ថិតនៅវិស័យព្រហ្មទណ្ឌនេះផ្ទាល់ ដែលជាបច្ច័យមួយធ្វើឲ្យប្រធានបទស្រាវជ្រាវប្រកបដោយភាពសម្បូរបែប និងសុក្រិដ្ឋភាពស្របតាមគោលការណ៍នៃគតិយុត្ត។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទនេះមានសារៈប្រយោជន៍ដល់អ្នកសិក្សា អ្នកអាន និងអ្នកស្រាវជ្រាវបានស្វែងយល់កាន់តែស៊ីជម្រៅពីការកំណត់នូវវិធាន និងនីតិវិធីនៃការអនុវត្តទោសព្រហ្មទណ្ឌ ទៅលើអនីតិជនដែលប្រព្រឹត្តបទល្មើស តាំងពីដំណាក់កាលនគរបាល រហូតដល់ដំណាក់កាលជំនុំជម្រះក្តី ដោយផ្អែកទៅលើការវិនិច្ឆ័យប្រកបដោយភាពហ្មត់ចត់។ អ្នកអាននឹងបានសិក្សាបន្ថែមទៅលើការកំណត់អត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយអនីតិជនប្រកបដោយសុក្រឹត្យភាព នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកអាននឹងអាចយកការស្រាវជ្រាវនេះ ធ្វើជាទុនដើម្បីបកស្រាយនូវសិទ្ធិ និងបង្ការអំណាចរំលោភដោយសមត្ថកិច្ច ឬអ្នកមានអំណាច លើអនីតិជនផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាកិច្ចបន្តនៃការមុជជ្រៅប្រធានបទខាងលើឲ្យកាន់តែស៊ីជម្រៅ យើងនឹងសិក្សាទៅលើរចនាសម្ព័ន្ធនៃការស្រាវជ្រាវនៃប្រធានបទនេះ ដែលផ្តោតទៅលើ ៣ ជំពូកធំៗ ដូចជា៖

**ជំពូកទី ១ សញ្ញាណទូទៅពាក់ព័ន្ធនឹងអនីតិជន**

**ជំពូកទី ២ ដំណាក់កាលនីតិវិធីនៃការអនុវត្តចំពោះអនីតិជន**

**ជំពូកទី ៣ ការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១
# សញ្ញាណទូទៅពាក់ព័ន្ធនឹងអនីតិជន

## ១.១ សិទ្ធិ និងគោលការណ៍ជាមូលដ្ឋាន

ជាទូទៅ អនីតិជន ឬកុមារតែងទទួលបានសិទ្ធិជាមូលដ្ឋាន តាំងពីចាប់កំណើតមកម្ល៉េះ ដែលឳពុកម្តាយមានភារកិច្ចចិញ្ចឹមកូន ផ្តល់កន្លែងស្នាក់នៅ ការអប់រំ ផ្តល់អាហារ និងទំនុកបម្រុងកូនសព្វបែបយ៉ាង[1]។ អនីតិជន ជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់ ឬជនដែលមានអាយុក្រោម ១៨ឆ្នាំ។[2] សិទ្ធិអនីតិជនត្រូវបានធានាការពារដោយរដ្ឋ ដូចជាសិទ្ធិក្នុងការរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ សិទ្ធិទទួលបានការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការពារប្រឆាំងនឹងការជួញដូរកុមារ ដែលបានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។[3] រដ្ឋជាសមាជិកនៃអនុសញ្ញានេះ ត្រូវធានាសិទ្ធិរបស់កុមារដែលមានចែងឲ្យបានខ្ជាប់ខ្ជួនក្នុងដែនដីរបស់ខ្លួន ដោយគ្មានការរើសអើងប្រកាន់ពូជសាសន៍ឡើយ។[4] កុមារមានសិទ្ធិជាអាទិភាពជានិច្ច ដោយសាររដ្ឋចាត់ទុកពួកគេស្ថិតនៅវ័យក្មេង និងងាយរងគ្រោះ[5] ហើយសិទ្ធិរបស់ពួកគេត្រូវបានធានាដោយច្បាប់ ទោះបីស្ថិតនៅក្រោមការឃាត់ខ្លួន ឃុំខ្លួន ឬចាប់ខ្លួនដោយសារប្រព្រឹត្តបទល្មើសក៏ដោយ ដែលសិទ្ធិ និងគោលការណ៍ជាមូលដ្ឋានរបស់អនីតិជនមានដូចតទៅ៖

### ១.១.១ សិទ្ធិជាមូលដ្ឋានរបស់អនីតិជន

នៅមុនដំណាក់កាល ក្នុងដំណាក់កាល និងក្រោយដំណាក់កាលនៃនីតិវិធីលើអនីតិជន គឺអនីតិជនមានសិទ្ធិដែលការពារដោយច្បាប់ពេញលេញដូចជា សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី។[6] មុនពេលចាប់ផ្តើមនីតិវិធីស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាមានតួនាទីមួយគឺតែងតែប្រាប់អនីតិជនអាចមានសិទ្ធិក្នុងការមិនផ្តល់ចម្លើយក្នុងកាលៈទេសៈណាមួយ ហើយអនីតិជនក៏មានសេរីភាពក្នុងការឆ្លើយដោយពុំត្រូវបានទទួលរងសម្ពាធក្នុងការបង្ខិតបង្ខំឲ្យផ្តល់ចម្លើយដែលមិនមែនជាការពិតនោះដែរ។ សិទ្ធិរក្សាការសម្ងាត់នៃ

[1] *សូមមើល* រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា ៤៧

[2] *សូមមើល* សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧, លេខរាង ១៨៧

[3] *សូមមើល* រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា ៤៨

[4] *សូមមើល* អនុសញ្ញាស្តីពី សិទ្ធិកុមារ ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ១៩៨៩

[5] *សូមមើល* អនុសញ្ញាស្តីពី សិទ្ធិកុមារ និងពិធីសារបន្ថែម ឆ្នាំ២០០៩, ទំព័រ៨

[6] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦

ជីវិតឯកជនរបស់អនីតិជនត្រូវបានការពារ ពោលគឺអត្តសញ្ញាណ ប្រវត្តិរូប ប្រវត្តិគ្រួសាររបស់អនីតិជន ត្រូវបានលាក់ទុកជាសម្ងាត់មិនឲ្យលេចឮដល់សាធារណៈជនណាឡើយ។ ម្យ៉ាងវិញទៀត នៅពេលអនីតិជនជួបគ្រោះថ្នាក់ រងរបួស ឬមានជំងឺ អនីតិជននឹងទទួលបានសិទ្ធិក្នុងការពិនិត្យសុខភាព និងការព្យាបាលដោយពុំមានការបង្ខាំងនោះឡើយ។ នៅពេលដែលមានការចាប់ខ្លួនលើអនីតិជន អនីតិជនត្រូវទទួលបានសិទ្ធិក្នុងការឲ្យដំណឹងពីការចាប់ខ្លួននេះជាមុន ដោយអាជ្ញាធរមិនអាចមកធ្វើការចាប់ខ្លួនភ្លាមៗដោយមិនផ្តល់ដំណឹងនោះទេ ដែលនាំឲ្យផ្ទុយនឹងច្បាប់ ហើយអ្នកតំណាងដែលច្បាប់បានកំណត់ក៏ត្រូវទទួលបានសិទ្ធិពីការផ្តល់ដំណឹងនៃការចាប់អនីតិជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដែរ។

លើសពីនេះទៅទៀត អនីតិជនមានសិទ្ធិទទួលបានមេធាវីក្នុងការការពារក្តី តាមការជ្រើសរើសរបស់អនីតិជនផ្ទាល់ ប៉ុន្តែប្រសិនបើអនីតិជនពុំមានលទ្ធភាពក្នុងការជួលមេធាវីទេ គេនឹងទទួលបានការចាត់តាំងមេធាវីដោយមិនគិតថ្លៃសេវានោះទេ ដែលជាលក្ខណៈពិសេសមួយដែលអនីតិជនទទួលបាននៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។ ដោយឡែកអ្នកតំណាងដែលច្បាប់បានកំណត់ នឹងមានសិទ្ធិក្នុងការចូលរួមក្នុងដំណាក់កាលរបស់អនីតិជន លើកលែងតែវត្តមានរបស់អ្នកនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជនប៉ុណ្ណោះ។ ក្នុងករណីដែលអនីតិជននោះជាជនបរទេសដែលស្ថិតក្នុងកម្រិតមួយពុំអាចយល់ពីខេមរៈភាសាបាន គេអាចស្នើសុំជំនួយពីអ្នកបកប្រែដោយឥតគិតថ្លៃសេវា ដើម្បីផ្តល់លក្ខណៈងាយស្រួលក្នុងការទំនាក់ទំនងរវាងអនីតិជន និងអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយប្រសិទ្ធិភាព ហើយគេអាចសុំសិទ្ធិក្នុងការធ្វើទំនាក់ទំនងជាមួយកុងស៊ុលផងដែរ។ ក្នុងដំណាក់កាលនៃនីតិវិធី អនីតិជនមានសិទ្ធិក្នុងការបង្ហាញភស្តុតាង និងសាក្សី ដោយជាអាទិ៍ដោយគ្មានការហាមឃាត់នោះឡើយ។ ជាចុងក្រោយ អនីតិជនមានសិទ្ធិអាចស្នើសុំសេចក្តីសម្រេចឲ្យអនុញ្ញាតអនីតិជនឲ្យនៅក្រៅឃុំ ឬសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ រួមទាំងសិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងវិធានគតិយុត្តផ្សេងទៀត។

### ១.១.២ គោលការណ៍មូលដ្ឋានអនុវត្តលើអនីតិជន

ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានភារកិច្ចក្នុងការចូលរួមក្នុងនីតិវិធីដែលត្រូវអនុវត្តចំពោះអនីតិជន ច្បាប់បានកំណត់នូវគោលការណ៍ជាមូលដ្ឋាន ដើម្បីឆ្លើយតបនឹងសិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលក្នុងនោះ បុគ្គលនោះត្រូវយកចិត្តទុកដាក់លើសិទ្ធិរស់រានមានជីវិត និងការរីកលូតលាស់របស់អនីតិជន ដោយប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរ។[7] ក្នុងនីតិវិធី អនីតិជនត្រូវបានលើកទឹកចិត្តឲ្យបញ្ចេញមតិ ដោយប្រើនីតិវិធីកុមារមេត្រី

[7] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៥

ដែលជានីតិវិធីមួយអាចអនុញ្ញាតឲ្យអនីតិជនចូលរួមក្នុងរឿងក្តីតាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតមួយដែលអនីតិជនមានសមត្ថភាពអាចយល់ និងឆ្លើយតបបាន ក្នុងលក្ខខណ្ឌដែលអនីតិជនទទួលបានសុវត្ថិភាព ពុំមានការរើសអើង ការប្រើខ្មោះ ការប្រើទារុណកម្មតាមមធ្យោបាយផ្សេងៗ ដែលប៉ះពាល់ទៅលើផ្លូវចិត្ត និងរូបកាយរបស់អនីតិជននោះឡើយ។ មួយវិញទៀត ដំណាក់កាលនៃការអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និងការដាក់ទោសលើអនីតិជនជាវិធានការចុងក្រោយ និងត្រូវចាប់អនុវត្តប្រតិបត្តិឲ្យបានឆាប់រហ័សបំផុតដែលអាចធ្វើទៅបាន។ រីឯព័ត៌មានទូទៅទាក់ទងនឹងអនីតិជនចាំបាច់ត្រូវរក្សាជាការសម្ងាត់ឲ្យបានល្អ ដោយមិនត្រូវបញ្ចេញផ្សព្វផ្សាយនោះឡើយ លើកលែងតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដើម្បីប្រយោជន៍សាធារណៈ ប៉ុន្តែត្រូវស្ថិតក្នុងលក្ខខណ្ឌមួយដែលអត្តសញ្ញាណរបស់អនីតិជនមិនត្រូវបង្ហាញ។

## ១.២ លក្ខខណ្ឌគតិយុត្តនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ប្រទេសនីមួយៗមានការអនុវត្តនីតិព្រហ្មទណ្ឌមានលក្ខណៈប្លែកពីគ្នាទៅលើការកំណត់អាយុរបស់អនីតិជនដែលប្រព្រឹត្តបទល្មើស ដើម្បីឲ្យអនីតិជននោះទទួលខុសត្រូវព្រហ្មទណ្ឌ។ ចំណែកព្រះរាជាណាចក្រកម្ពុជា ច្បាប់បានកំណត់ពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបុគ្គលដែលមានអាយុ១៨ឆ្នាំឡើងទៅ[8] ដូច្នេះមានន័យថាលុះត្រាតែបុគ្គលប្រព្រឹត្តបទល្មើសនោះអាយុចាប់ពី១៨ឆ្នាំឡើងទៅ ទើបតុលាការអាចអនុវត្តទោសព្រហ្មទណ្ឌបាន ព្រោះបុគ្គលនេះ មានអត្តសញ្ញាណប័ណ្ណដែលក្លាយជាពលរដ្ឋមានសិទ្ធិ និងការទទួលខុសត្រូវពេញលេញ មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត និងមានសមត្ថភាពក្នុងការពិចារណាដឹងខុសត្រូវ។ ទោសផ្នែកព្រហ្មទណ្ឌសំដៅទៅលើការដាក់ទោស និងពិន័យជាប្រាក់។ បុគ្គលដែលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងពេលដែលជននោះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ និងដល់កម្រិតអាយុ ដែលច្បាប់បានកំណត់។[9] ជាគោលការណ៍ទូទៅ ចំពោះអនីតិជនដែលមានអាយុក្រោម១៨ ដែលបានប្រព្រឹត្តិបទល្មើស ត្រូវបានច្បាប់ការពារដោយលើកលែងអនីតិជនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលខុសត្រូវព្រហ្មទណ្ឌមានកម្រិត។ យ៉ាងណាក្តី ក្នុងនោះច្បាប់បានកំណត់ថាចំពោះអនីតិជនដែលមានអាយុ១៤ឆ្នាំឡើងទៅ អាចត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្អែកទៅលើកាលៈទេសៈ ឬបុគ្គលិកលក្ខណៈតម្រូវ[10]។ នេះសរបញ្ជាក់ឲ្យឃើញថា ច្បាប់បានផ្តល់ថេរវេលាមួយយ៉ាងសមស្របសម្រាប់យុត្តាធិ

[8] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៣៨

[9] *សូមមើល* នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ ហ៊ី សោភា, ទំព័រ ៧

[10] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៣៩

ការពិនិត្យលើលក្ខខណ្ឌកាលៈទេសៈ ឬ បុគ្គលិកលក្ខណៈ មុននឹងឈានដល់ការសម្រេចប្រកាសទោសលើអនីតិជន។

ដូច្នេះយើងនឹងសិក្សាទៅលើពីរចំនុចដែលផ្តោតទៅលើលក្ខខណ្ឌគតិយុត្តិទាក់ទងនៃអនីតិជន ដូចជាការកំណត់នីតិភាពនៃអនីតិជនក្នុងការទទួលខុសត្រូវ (២.១.១) និងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អនីតិជន (២.២.២)៖

### ១.២.១. ការកំណត់នីតិភាពនៃអនីតិជនក្នុងការទទួលខុសត្រូវ

ច្បាប់បានកំណត់ពីអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌលើអនីតិជន គឺគិតចាប់ពីថ្ងៃដែលអនីតិជននោះបានប្រព្រឹត្តបទល្មើសតែម្តង[11]។ ភស្តុតាងនៃអាយុនោះ ផ្អែកលើសំបុត្រអត្រានុកូលដ្ឋានរួមមានសំបុត្រកំណើត[12] ឬឯកសារផ្សេងៗទៀតដែលបញ្ជាក់អំពីកំណើត។ ប៉ុន្តែប្រសិនបើពុំមានឯកសារ ឬនៅមានមន្ទិលសង្ស័យពីអាយុរបស់អនីតិជន អាជ្ញាធរតុលាការអាចស្វែងរកភស្តុតាងនៃអាយុរបស់អនីតិជនតាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាចទុកចិត្តបាន។

#### ១.២.១.១. អាយុក្រោម១៤ឆ្នាំ

អនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ដែលបានសង្ស័យថាប្រព្រឹត្តបទល្មើស គឺពុំត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ដូច្នោះសមត្ថកិច្ចពុំមានអំណាចចាប់ខ្លួនគេនោះទេ។ មន្ត្រីនគរបាលដែលជាសមត្ថកិច្ចដំបូងដែលបំពេញបេសកកម្មលើសកម្មភាពពាក់ព័ន្ធនឹងអនីតិជន ត្រូវប្រគល់ខ្លួនអនីតិជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង[13]។ ឧទាហរណ៍ ចំពោះបទល្មើសដែលក្មេងអាយុ១០ឆ្នាំម្នាក់ បានគប់វត្ថុរឹងធ្វើឲ្យភាគីម្ខាងទៀតរងរបួស ច្បាប់បានបញ្ញត្តិថាអនីតិជនពុំទទួលទោសនោះទេ ពីព្រោះត្រូវគេចាត់ទុកថាជាបុគ្គលដែលមានកម្រិតការលូតលាស់ខួរក្បាល និងសរីរាង្គពុំទាន់ពេញលេញនៅឡើយ ជាហេតុធ្វើឲ្យគេប្រព្រឹត្តអំពើខុសឆ្គងដោយឥតពិចារណាជាមុន។

#### ១.២.១.២. អាយុពី១៤ឆ្នាំ ដល់ ក្រោម១៨ឆ្នាំ

ដោយឡែកអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទលហុ ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដោយមន្ត្រីនគរបាលមានសមត្ថកិច្ចគ្រាន់តែយកអនីតិ

---

[11] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៩

[12] *សូមមើល* អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០, មាត្រា២

[13] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១៤

ជននោះធ្វើការអប់រំណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ បន្ទាប់មកប្រគល់អនីតិជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ហើយបើអនីតិជនសារភាពកំហុសខ្លួន គេអាចអនុវត្តវិធានការសម្រុះសម្រួលរវាងភាគីដើម្បីបញ្ចប់វិវាទ[14]។

ករណីអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសមជ្ឈិម បទឧក្រិដ្ឋជាក់ស្តែង នឹងត្រូវមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួន ឬឃាត់ខ្លួន និងបញ្ជូនសំណុំរឿងក្តីនេះទៅយុត្តាធិការពាក់ព័ន្ធនឹងអនីតិជនដើម្បីធ្វើការចាត់ចែង។[15] ទោះយ៉ាងណាក៏ដោយ ចំពោះអនីតិជនដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចត្រូវបានចាប់ខ្លួនបាន ក្នុងករណីដែលគេប្រព្រឹត្តបទមជ្ឈិមដោយចេតនាតែប៉ុណ្ណោះ[16]។ ចំពោះបទឧក្រិដ្ឋ ការឃាត់ខ្លួនអនីតិជនដែលមានអាយុ ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ត្រូវធ្វើឡើងមិនលើស ៣៦ ម៉ោង និងមិនលើស ៤៨ ម៉ោង សម្រាប់អនីតិជនអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ។ ចំណែកចំពោះបទមជ្ឈិម អនីតិជនអាយុដល់ ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ អាចឃាត់ខ្លួនបានមិនលើសពី ២៤ ម៉ោង ហើយអនីតិជនអាយុ ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ អាចឃាត់ខ្លួនមិនលើស ៣៦ ម៉ោង។[17]

តុលាការបានសម្រេចដាក់ទោសព្រហ្មទណ្ឌអនីតិជន ដោយការបន្ធូរពាក់កណ្តាលទោស ពីទោសធម្មតា[18] មានន័យថា បើទោសធម្មតា ១០ ឆ្នាំ នោះអនីតិជននឹងត្រូវទទួលទោសតែ ៥ ឆ្នាំទេ។ ឧទាហរណ៍ បទល្មើសឃាតកម្មដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ១៥ឆ្នាំ[19] ដោយឡែកអនីតិជនត្រូវតុលាការប្រកាសទោសពី ៥ឆ្នាំទៅ៧ឆ្នាំកន្លះវិញ។ បើបទល្មើសនោះជាបទល្មើសព្រហ្មទណ្ឌដែលតម្រូវឲ្យជាប់ពន្ធនាគារមួយជីវិត គឺតុលាការនឹងកាត់បន្ថយទោសនោះ ២០ ឆ្នាំតែប៉ុណ្ណោះ ចំពោះអនីតិជនដែលមានវ័យពី១៤ឆ្នាំ ដល់១៨ឆ្នាំ។ ចំណែកទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយពាក់កណ្តាលដែរ។ ក្រៅពីមូលទោស អនីតិជន អាចប្រកាសទោសបន្ថែម និងទោសការងារសហគមន៍បានដែរតាមសេចក្តីសម្រេចរបស់តុលាការ។[20]

---

14 *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១៣

15 *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១២

16 *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១៥

17 *សូមមើល* សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ, ឆ្នាំ២០១៣-២០១៤ , ទំព័រ២១

18 *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ១៦០

19 *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ១៩៩

20 *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ១៦១ និង មាត្រា ១៦២

កាលណាបទល្មើសនោះបង្កព្យសនកម្ម ឬការខូចខាតផ្សេងៗ ជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះ[21] អាចដាក់បណ្តឹងរដ្ឋប្បវេណីបាន ដើម្បីទាមទារឲ្យអនីតិជនសងសំណងជាប្រាក់ គេអាចធ្វើបានទោះបីជាមានបណ្តឹងអាជ្ញាក៏ដោយ។[22] ករណីនេះ អនីតិជននឹងត្រូវទទួលខុសត្រូវបណ្តឹងរដ្ឋប្បវេណី ដើម្បីជួសជុលសងការខូចខាតដែលបណ្តាលមកពីអំពើល្មើសរបស់ជនល្មើសចំពោះជនរងគ្រោះ ដើម្បីទទួលបានព្យសនកម្មដែលសមទទួលបាន។[23] ការបង្ហាញព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែពិតប្រាកដ និងដោយផ្ទាល់ ហើយដើមបណ្តឹងត្រូវធ្វើឡើងតាំងពីសាលាជម្រះក្តីថ្នាក់ទីមួយមកម្ល៉េះ។[24] ទោះជាយ៉ាងណាក្តី បណ្តឹងរដ្ឋប្បវេណីនឹងត្រូវរលត់ នៅពេលដែលផុតចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា[25] មានន័យថា កាលណាជនល្មើសត្រូវបានរួចខ្លួនពីការចោទប្រកាន់ហើយ បណ្តឹងរដ្ឋប្បវេណីក៏ពុំមានសុពលភាពផងដែរ។

### ១.២.២. លក្ខខណ្ឌនៃការទទួលខុសត្រូវរបស់អនីតិជន

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាពុំបានចែងពីនិយមន័យ ឬលក្ខណៈវិនិច្ឆ័យនៃ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណរបស់អនីតិជនឲ្យបានច្បាស់ឡើយ។ ប៉ុន្តែបើយើងធ្វើការវិភាគមើលទៅលើបទល្មើសដែលអនីតិជនដែលមានអាយុពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំបានប្រព្រឹត្ត យើងនឹងគិតទៅដល់ធាតុផ្សំសំខាន់ៗ ដូចជា **ទីមួយ** គឺគោលការណ៍នីត្យានុកូលដែលច្បាប់បានចែងពីទោសដែលអនីតិជនត្រូវទទួលខុសត្រូវ **ទីពីរ** គឺគោលការណ៍សត្យានុម័តនៃបទល្មើសថាបទល្មើសនោះប្រើមធ្យាបាយអ្វីប្រព្រឹត្តនៅទីកន្លែងណា និង**ទី៣** គឺយើងពិនិត្យមើលបុគ្គលិកលក្ខណៈនៃអនីតិជននោះផងដែរ។

#### ១.២.២.១ លក្ខខណ្ឌកាលៈទេសៈនៃបទល្មើស

កាលៈទេសៈនៃបទល្មើស គឺជាធាតុផ្សំមួយសំខាន់សម្រាប់វិនិច្ឆ័យទៅលើការដាក់ទោសអនីតិជនដែលវាប្រៀបដូចជា ធាតុសន្យានុម័ត ដែលកំណត់ពីបទល្មើស និងកំណត់ព្រំដែននៃបទល្មើស ហើយនេះដោយផ្អែកទៅលើ

[21] *សូមមើល* នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ១៥

[22] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៨

[23] *សូមមើល* នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ២

[24] *សូមមើល* សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ, ឆ្នាំ២០១៣-២០១៤ , ទំព័រ១០

[25] *សូមមើល* នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ២៦

បទពិសោធន៍នៃសេចក្តីសម្រេចរបស់តុលាការ គេមើលទៅលើមធ្យោបាយប្រព្រឹត្តបទល្មើស វិធីសាស្ត្រប្រព្រឹត្តបទល្មើស ជាពិសេសគឺពេលវេលា ទីកន្លែង និងទិដ្ឋភាពនានា។[26]

**មធ្យោបាយប្រព្រឹត្តបទល្មើស**

មធ្យោបាយប្រព្រឹត្តបទល្មើស គឺសម្តៅលើការប្រើប្រាស់សម្ភារៈ ឧបករណ៍ ឬវត្ថុអ្វីមួយ ដើម្បីយកមកប្រើប្រាស់ធ្វើសកម្មភាពដែលប្រាសចាកនឹងច្បាប់។ ឧទាហរណ៍ អនីតិជនម្នាក់អាយុ១៥ឆ្នាំ បានប្រើចបកាប់ទៅវាយប្រហារបុរសម្នាក់ដោយកំហឹង ជាហេតុធ្វើឲ្យបុរសនោះបែកក្បាលហូរឈាមយ៉ាងដំណំ។ តុលាការបានបកស្រាយថា ចបកាប់នេះ ជាមធ្យោបាយប្រព្រឹត្តបទល្មើសដែលបង្កជាព្យសនកម្ម នាំឲ្យតុលាការសម្រេចចិត្តនឹងផ្តន្ទាទោសពីបទហិង្សាដោយចេតនា ដោយគិតស្ថានទម្ងន់ទោស។[27]

**វិធីសាស្ត្រប្រព្រឹត្តបទល្មើស**

វិធីសាស្ត្រប្រព្រឹត្តបទល្មើស សំដៅលើ វិធីសាស្ត្រ បែបផែន ឬតិចនិចក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ឧទាហរណ៍ អនីតិជនអាយុ១៧ឆ្នាំម្នាក់ បានគំរាមកំហែងហែកកេរ្តិ៍ អ្នកដទៃដោយប្រើ វិធីសាស្ត្រប្រព្រឹត្តបទល្មើសគឺគំរាមកំហែងបើកកកាយ ឬទម្លាក់កំហុសទៅលើអំពើដែលនាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដើម្បីអាចទទួលប្រយោជន៍ណាមួយដូចជា ស្នាមមេដៃដើម្បីទទួលបានបណ្តាំ។ តុលាការអាចនឹងដាក់ទោសអនីតិជននោះ ពីបទគំរាមកំហែងហែកកេរ្តិ៍ ដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌ។[28]

**ពេលវេលាប្រព្រឹត្តបទល្មើស**

ពេលវេលាប្រព្រឹត្តបទល្មើស សំដៅទៅលើរយៈពេលកំណត់មួយ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបានស្តែងចេញក្រៅ។ នេះមានន័យថា ពេលវេលាប្រព្រឹត្ត ដែលបានកំណត់នៅក្នុងច្បាប់ព្រហ្មទណ្ឌ ក៏ជាធាតុផ្សំយ៉ាងសំខាន់ដើម្បីកំណត់នូវបទល្មើសផ្ទាល់តែម្តង។ ជាក់ស្តែង ការធ្វើនេសាទក្នុងរដូវបិទនេសាទដែលពុំទទួលបានការអនុញ្ញាតឲ្យធ្វើនេសាទ[29] ដែលយើងត្រូវលើកយកពិចារណាលើពេលវេលានៃការប្រព្រឹត្តបទល្មើសនេះដែលជនល្មើសនេសាទខុសរដូវ ខុសពេលវេលា ដែលធ្វើឲ្យប៉ះពាល់ដល់មច្ឆជាតិ និងធម្មជាតិ។

---

[26] *សូមមើល* សាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌទូទៅ, ទំព័រ ៧៣ ដល់ ៧៥

[27] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ២១៨

[28] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៣៧២

[29] *សូមមើល* ច្បាប់ស្តីពី ការគ្រប់គ្រងវិស័យជលផល, ឆ្នាំ២០០៦, មាត្រា ៣៩

**ទីកន្លែងបទល្មើស**

ទីកន្លែងបទល្មើស សំដៅលើទីតាំង ដែនដីមួយ ដែលជនល្មើសបានប្រព្រឹត្តសកម្មភាពខុសច្បាប់ តាំងពីចាប់ផ្តើម និងបញ្ចប់ ឬជាដែនដីមួយដែល ច្បាប់ព្រហ្មទណ្ឌបានចែងថា វាជាទីតាំងដែលសំរាប់កំណត់នូវបទល្មើសព្រហ្មទណ្ឌ។ ឧទាហរណ៍ ការហាមឃាត់នូវកន្លែងអភិរក្សជលផលក្នុងធ្វើការនេសាទគ្រប់ប្រភេទ រួមមាន តំបន់ទឹកជួរ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹងទន្លេ សាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់សម្រាប់និរន្តភាពនៃធនធានជលផល។[30] ការនេសាទនៅតំបន់អភិរក្សនេះធ្វើបានលុះត្រាតែមានការអនុញ្ញាតពីក្រសួង ហើយបើជនល្មើសនៅតែប្រព្រឹត្តបទល្មើសនៅកន្លែងហាមឃាត់នេះ នឹងត្រូវទទួលទោសតាមការកំនត់របស់ច្បាប់។

**ទិដ្ឋភាពនានាជុំវិញបទល្មើស**

ទិដ្ឋភាពនានាជុំវិញបទល្មើស សំដៅលើ ករណីលម្អិតនានាជុំវិញការប្រព្រឹត្តបទល្មើសដែលមានឥទ្ធិពលលើកម្រិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស ឬក៏អាចបញ្ញាត្តិថា ជាសញ្ញានៃស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោសផងដែរ។ ឧទាហរណ៍ បើក្មេងស្រីម្នាក់១៦ឆ្នាំ ម្នាក់ប្រើកាំបិតទៅចាក់ភ្លៅស្តាំបុរសម្នាក់ទៀត ដោយមូលហេតុបុរសនោះប៉ុនប៉ងប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើក្មេងស្រីនោះ ដូច្នេះក្មេងស្រីនោះ បានប្រើការការពារដោយស្របច្បាប់ដែលជាហេតុពុំទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ[31] តែបើតុលាការពិនិត្យទៅខុសពីការពិត នោះជនល្មើសនោះនឹងទទួលទោសជាមិនខាន។

**១.២.២.២. លក្ខខណ្ឌបុគ្គលិកលក្ខណៈ**

បុគ្គលិកលក្ខណៈរបស់អនីតិជន សម្តៅលើ អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត[32] របស់អនីតិជនដែលមានសមត្ថភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត។ ដូចនេះ ពេលដែលតុលាការសម្រេចដាក់ទណ្ឌកម្មលើអនីតិជន ត្រូវពិចារណាលើ សរីរាង្គ កម្រិតនៃការយល់ដឹងជាមុនសិន។ គេមានលក្ខខណ្ឌពីរយ៉ាង ដើម្បីវាយតម្លៃថា អនីតិជនមានសមត្ថភាពយល់ដឹង ឬមិនយល់ដឹង រួមមានតាមបែបធម្មជាតិ និងបែបវេជ្ជសាស្ត្រ។[33]

---

[30] *សូមមើល* ច្បាប់ស្តីពី ការគ្រប់គ្រងវិស័យជលផល, ឆ្នាំ២០០៦, មាត្រា ១៨ និងមាត្រា១៩

[31] *សូមមើល* ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, មាត្រា ៣៣

[32] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៤

[33] *សូមមើល* សាស្ត្រាចារ្យ ហ៊ី សោភា, នីតិព្រហ្មទណ្ឌទូទៅ, , ទំព័រ ៨០ ដល់ ៨៣

**របបតាមបែបធម្មជាតិ**

ការវាយតម្លៃបែបធម្មជាតិ សម្តៅលើការពិនិត្យលើរូបរាងកាយសរីរាង្គ និងផ្នែកខួរក្បាល។ នៅវ័យនេះ អនីតិជនជាវ័យកំពុងផ្លាស់ប្តូរយ៉ាងខ្លាំងទាំងរូបរាងកាយ ខួរក្បាល និងអារម្មណ៍ចិត្តគំនិត។[34] ការផ្លាស់ប្តូរផ្នែកជីវសាស្ត្ររបស់វ័យនេះ ហៅថា ការពេញរូបរាង ដែលជាធម្មតាក្មេងស្រីឆាប់ពេញរូបរាងជាងក្មេងប្រុសប្រមាណពី២ទៅ៣ឆ្នាំ ហើយផុតរយៈពេលនោះ ក្មេងប្រុសរីកលូតលាស់លឿនរហូតដល់ទាន់ក្មេងស្រី។ ក្នុងវ័យនេះ អនីតិជនមានរាងកាយមាំទាំ ខួរក្បាលកំពុងរីកចម្រើនស្ទើរតែពេញលេញទៅហើយ ដែលធ្វើឲ្យគេចង់សិក្សារៀនសូត្រអ្វីដែលថ្មីៗ។ ដោយសារតែការរីកចម្រើនដ៏ខ្លាំងនៃបច្ចេកវិទ្យា និងលទ្ធិសម្ភារៈនិយមនាសម័យបច្ចុប្បន្ន អនីតិជនពោរពេញទៅដោយតណ្ហាចង់បានរបស់ទុកបង្អួតគ្នីគ្នា។ ឧទាហរណ៍ ក្មេង១៥ឆ្នាំម្នាក់ឃើញគេមានទូរសព្ទទំនើបស៊េរី Iphone 12 ខ្លួនក៏ចង់បានដែរ ប៉ុន្តែដោយសារតែកង្វះខាតផ្នែកហិរញ្ញវត្ថុ ក្មេងនោះក៏បែកគំនិតឆក់ទូរសព្ទអ្នកទៃ ហើយត្រូវប៉ូលីសត្រូវចាប់ខ្លួន។ ដូច្នេះហើយមុននឹងអនុវត្តទោសលើអនីតិជន គេត្រូវវាយតម្លៃទៅលើ អាយុ កាយសម្បទាថា ក្មេងនោះថា មានរីកលូតលាស់កម្រិតណាដែលប្រើកម្លាំងពេញលេញរបស់ខ្លួនទៅប្រព្រឹត្តបទល្មើស ហើយគេពិនិត្យមើលកម្រិត និងលំនាំនៃការគិតថា ក្មេងនោះអាចស្វែងយល់ថាទង្វើដែលខ្លួនប្រព្រឹត្តនោះត្រឹមត្រូវ ឬអត់។

**របបវេជ្ជសាស្ត្រ**

ដោយឡែកការវាយតម្លៃតាមវេជ្ជសាស្ត្រ មានលក្ខណៈខុសពីការវាយតម្លៃតាមបែបធម្មជាតិ ពីព្រោះត្រូវការជំនួយពីអ្នកជំនាញដូចជាគ្រូពេទ្យ ចិត្តវិទូ ឬអ្នកដែលមានវិជ្ជាជីវៈទាក់ទងនឹងវេជ្ជសាស្ត្រ ដើម្បីពិនិត្យទៅលើសុខភាពផ្លូវចិត្តរបស់អនីតិជន។ អនីតិជននឹងត្រូវបានវាយតម្លៃថា តើមានបញ្ហាសតិអារម្មណ៍ដូចជា វិបល្លាសស្មារតីដែលបណ្តាលឲ្យអនីតិជនអសមត្ថភាពក្នុងការយល់ដឹងបាន ឬក៏អនីតិជនជួបវិបត្តិផ្លូវចិត្ត ដូចជាភាពតានតឹង ជម្ងឺទុកព្រួយ (Depression) ជំងឺអ៊ីពែរអាក់ទីវ (Hyper Active) ជំងឺភ័យខ្លាចហួសហេតុ (Phobia) ជាដើម[35]។ បញ្ហាដែលជាប់ពាក់ព័ន្ធទៅនឹងសុខភាពផ្លូវកាយ ត្រូវពិគ្រោះជាមួយគ្រូពេទ្យ ឬត្រូវសុំជំនួយពីពេទ្យចិត្តសាស្ត្រ។ ឧទាហរណ៍ ក្មេងស្រីអាយុ១៧ឆ្នាំម្នាក់ បានបើកឡានទៅបុកនារីម្នាក់ធ្វើឲ្យគ្រោះថ្នាក់ បន្ទាប់មកពេទ្យបានពិនិត្យថា តើអនីតិជននោះមានជាប់ពាក់ព័ន្ធនឹងបញ្ហាស្មារតី ដែលធ្វើឲ្យបាត់បង់សតិបញ្ញាក្នុងការគ្រប់គ្រងខ្លួនដែរឬអត់។ ប្រសិនបើពេទ្យពិនិត្យឃើញថា ក្មេងនោះមានជម្ងឺសរសៃប្រសាទ ជាលទ្ធផលគឺមិនអាចទទួលទោសព្រហ្មទណ្ឌទេ តែបើពិនិត្យថាក្មេងស្រីនោះមិនធ្លាប់មានវិបត្តិជំងឺផ្លូវចិត្តទេ ដែលតាមពិតអំពើនោះកើតឡើងដោយខ្វះការប្រុងប្រយ័ត្ន និងទំនួលខុសត្រូវ ជា

[34] *សូមមើល* គឹម ចាន់ណា, ចិត្តវិទ្យាវ័យជំទង់, ឆ្នាំ២០១០, ទំព័រ ២៥ ដល់ ២៧

[35] *សូមមើល* គឹម ចាន់ណា, ចិត្តវិទ្យាវ័យជំទង់, ឆ្នាំ២០១០, ទំព័រ ៤៣ ដល់ ៤៥

ពិសេសដោយសារអាយុមិនទាន់គ្រប់ដើម្បីបើកបរ ក៏ជាមូលហេតុដែលអនីតិជនគេចមិនផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

## ១.៣ តួអង្គសំខាន់ៗដែលមានវត្តមាន និង វិធានបង្វែរ

### ១.៣.១ តួអង្គសំខាន់ៗចូលរួម

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌលើអនីតិជន យើងសង្កេតឃើញថាមានតួអង្គបីដែលមានវត្តមានជានិច្ច នៅក្នុងដំណាក់កាលនីមួយនៃនីតិវិធីដែលអនុវត្តចំពោះអនីតិជន ។ ប្រសិនបើអវត្តមានតួអង្គណាមួយ ក៏លំហូរនីតិវិធីនោះមិនអាចប្រព្រឹត្តទៅបានដែរ ដូច្នេះហើយតួអង្គទាំងបីនេះមានសារៈសំខាន់ក្នុងការចូលរួមឲ្យការអនុវត្តនីតិវិធីអនុវត្តលើអនីតិជនប្រកបទៅដោយភាពរលូន និងសុក្រឹត្យភាព ជាពិសេសនៅពេលអវត្តមានជនណាមួយ នឹងមានការចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់ពីមូលហេតុនៃការអវត្តមាននេះ។ ម្យ៉ាងវិញទៀត តួអង្គទាំងបីមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយរបស់អនីតិជន និងត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ស្របតាមបទបញ្ញត្តិដែលបានចែង។ តួអង្គទាំងបីរូបដែលយើងនឹងលើកមកសិក្សារួមមាន អ្នកតំណាងកំណត់ដោយច្បាប់ (៣.១.១.១) អ្នកទំនុកបម្រុង (៣.១.១.២) ភ្នាក់ងារសង្គមកិច្ច (៣.១.១.៣) និងមេធាវី (៣.១.១.៤)។

### ១.៣.១.១ អ្នកតំណាងកំណត់ដោយច្បាប់

អ្នកតំណាងកំណត់ដោយច្បាប់ សំដៅទៅលើអ្នកមានអំណាចមេបាដូចជា ឪពុកម្តាយ ឬអ្នកអាណាព្យាបាលទូទៅរបស់អនីតិជន។[36] អ្នកតំណាងកំណត់ដោយច្បាប់មានសិទ្ធិក្នុងការចាត់ចែងទំនុកបម្រុង ថែរក្សា និងការពារអនីតិជនដែលស្ថិតនៅក្រោមបន្ទុករបស់ខ្លួន។ ក្នុងនីតិវិធីនៃការអនុវត្តទៅលើការទទួលខុសត្រូវរបស់អនីតិជនតម្រូវឲ្យមានវត្តមានរបស់អ្នកតំណាងកំណត់ដោយច្បាប់ ដើម្បីមកចូលរួមស្តាប់ចម្លើយរបស់អនីតិជន លើកលែងតែអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ហើយការសម្រេចចិត្តនេះត្រូវឆ្លងកាត់ការពិគ្រោះយោបល់រវាងមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ ករណីអ្នកតំណាងកំណត់ដោយច្បាប់មិនអាចចូលរួមបាន អ្នកទំនុកបម្រុងនឹងចូលរួមជំនួស ដែលជាជនជ្រើសរើសដោយអនីតិជន ឬអាជ្ញាធរមានសមត្ថកិច្ចឆ្លងតាមការយល់ព្រមពីអនីតិជន ដើម្បីទទួលខុសត្រូវអនីតិជនក្នុងនីតិវិធីអនុវត្ត។

[36] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៤

### ១.៣.១.២ ភ្នាក់ងារសង្គមកិច្ច

ដោយឡែកភ្នាក់ងារសង្គមកិច្ចក៏មានវត្តមានសំខាន់នៅក្នុងគ្រប់នីតិវិធីផងដែរ ដោយភ្នាក់ងារសង្គមកិច្ចមានតួនាទីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាជាបន្ទាន់ដល់អនីតិជនក្នុងដំណាក់ការស៊ើបអង្កេត។[37] ភ្នាក់ងារសង្គមកិច្ចត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអនីតិជន ដើម្បីផ្តល់ការលើកទឹកចិត្ត និងសង្គម អនីតិជនត្រូវទទួលសេវាការស្តារនីតិសម្បទា និងកិច្ចការពារថែទាំ ពីសំណាក់ភ្នាក់ងារសង្គមកិច្ច ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ តាមការស្នើសុំរបស់មន្ត្រីនគរបាល ដើម្បីផ្ញើរបាយការណ៍ទទួលអនីតិជនទៅព្រះរាជអាជ្ញា។ ករណីអនីតិជនពុំមានអ្នកតំណាងកំណត់ដោយច្បាប់ ភ្នាក់ងារសង្គមកិច្ចក៏ត្រូវមានភារកិច្ចត្រូវសុំតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននេះ។ ភ្នាក់ងារសង្គមកិច្ច ត្រូវបំពេញតួនាទីក្នុងការប្រមូលផ្តុំព័ត៌មានទាក់ទងនឹងអនីតិជន រួមមានស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តអប់រំ លក្ខខណ្ឌនៃការរស់នៅរបស់អនីតិជនជាដើម ហើយជាចុងក្រោយភ្នាក់ងារសង្គមកិច្ចក៏ត្រូវមានភារកិច្ចក្នុងការ រៀបចំផែនការបង្វែជូនអាជ្ញាធរទទួលបន្ទុកបង្វែរ។

### ១.៣.១.៣ មេធាវី

ច្បាប់បានចែងពីសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដែលអនីតិជនមានសិទ្ធិទទួលបានជំនួយសេវាមេធាវីដោយជ្រើសរើស ឬចាត់តាំងដោយមិនយកកម្រៃនោះទេ។[38] មេធាវីត្រូវតែមានវត្តមានជានិច្ចក្នុងសវនាការ[39] ដើម្បីចូលខ្លួនមកការពារសិទ្ធិ និងផលប្រយោជន៍របស់អនីតិជន នៅគ្រប់ដំណាក់កាលនៃនីតិវិធី ដោយបំពេញតាមវិជ្ជាជីវៈរបស់ខ្លួនឲ្យបានល្អ រក្សាការសម្ងាត់ និងឯកជនភាពរបស់អនីតិជន ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវី។ មេធាវីត្រូវមានការសន្ទនានឹងទំនាក់ទំនងជាមួយអនីតិជន តាមរយៈការប្រើនីតិវិធីកុមារមេត្រី ដើម្បីអាចឲ្យមេធាវីអាចកត់ត្រាកំណត់ហេតុ ស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់ ស្វែងរកភស្តុតាង និងសាក្សីជាសំអាង។ តុលាការនឹងទុកពេលវេលាសមស្រប ដើម្បីអាចឲ្យមេធាវីធ្វើលិខិតចម្លងសំណុំរឿងបាន ដែលសោហ៊ុយសម្រាប់ធ្វើការជាបន្ទុករបស់រដ្ឋ ក្នុងករណីតុលាការជាអ្នកជ្រើសរើស ប៉ុន្តែបើអនីតិជនជាអ្នកជ្រើសរើស នោះជាសោហ៊ុយជាបន្ទុករបស់មេធាវីផ្ទាល់។ មេធាវី ត្រូវធ្វើការសកម្មក្នុងការស្វែងរកភស្តុតាងដើម្បីដោះបន្ទុក ដូចជា ភស្តុតាងបញ្ជាក់ពី

[37] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១១

[38] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦

[39] *សូមមើល* ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥, មាត្រា និង ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៥០

កង្វះធាតុផ្សំបទល្មើស បញ្ជាក់ពីអំពើយុត្តិកម្ម (ការការពារដោយស្របច្បាប់) និងអភ័យឯកសិទ្ធជាដើម ដើម្បីបង្ហាញពីភាពសុចរិតរបស់កូនក្តី និងកាត់បន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ។[40]

**១.៣.២ វិធានការបង្វែរ**

មុនចូលទៅដល់ដំណាក់កាលនៃនីតិវិធីនីមួយៗ យើងសង្កេតឃើញថា វិធានការបង្វែរត្រូវបានយកមកអនុវត្តជានិច្ច។ ការបង្វែរ ជាវិធានការដែលអាចយកមកអនុវត្តបាន ក្នុងករណីអនីតិជនបានសារភាពកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តបទល្មើស ហើយអាជ្ញាធរទទួលបន្ទុកបង្វែរអាចជឿជាក់ថាបានប្រព្រឹត្តបទល្មើសមែន តាមដំណាក់កាលនៃនីតិវិធីនីមួយៗ[41] តែក្នុងករណីបទល្មើសលហុ ឬបទមជ្ឈិមប៉ុណ្ណោះ។ អាជ្ញាធរទទួលបន្ទុកបង្វែររួមមានតំណាងអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សជំនុំជម្រះនៃសាលាឧទ្ធរណ៍។[42]

ការបង្វែរជាវិធានការមួយដែលទំនោរទៅរកការស្តារនូវចិត្តសាស្ត្ររបស់អនីតិជន ដើម្បីផ្តល់ឱកាសក្នុងការកសាងខ្លួនម្តងទៀត ដូចជាលើកទឹកចិត្តឲ្យអនីតិជនទទួលរៀនស្គាល់កំហុសខ្លួន ជំរុញឲ្យអនីតិជនកែប្រែអាកប្បកិរិយាមិនល្អ ចៀសវាងបង្កបទល្មើសជាថ្មី ជំរុញឲ្យមានការសះជារវាងជនប្រព្រឹត្តបទល្មើសជាមួយជនរងគ្រោះ បង្ការការរើសអើងដោយសារប្រវត្តិមិនល្អ និងចៀសចេញពីឈ្មោះក្នុងបញ្ជីថ្កោលទោស។[43]

**១.៣.២.១ លក្ខខណ្ឌនៃការបង្វែរ**

ដើម្បីឈានដល់ការរៀបចំបង្កើតនូវផែនការបង្វែរបាន លុះត្រាតែចាំបាច់បំពេញនូវលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងពិចារណាលើលក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរជាមុនសិន។

**លក្ខខណ្ឌអប្បបរមានៃការបង្វែរ**[44]មានដូចជា៖

- មានភស្តុតាងគ្រប់គ្រាន់ ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន
- អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំទោសជនរងគ្រោះ។
- បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម។

[40] *សូមមើល* សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ, ឆ្នាំ២០១៣-២០១៤ , ទំព័រ១២

[41] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦០

[42] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦១

[43] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦២

[44] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៣

- អនីតិជនយល់ព្រមឲ្យធ្វើការបង្វែរ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះពាល់នៅពេលអនុវត្តវិធានការបង្វែរ។

ដោយឡែកចំពោះ **លក្ខណៈវិនិច្ឆ័យសម្រាប់បង្វែរ** យើងពិចារណាទៅលើកត្តាខាងក្រោមនេះ[45]៖

- កាលៈទេសៈនៃបទល្មើស
- ស្ថានភាពនៃបទល្មើស
- បុគ្គលិកលក្ខណៈអនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត។
- ការទទួលរងឥទ្ធិពលពីគ្រួសារ និងបរិយាកាសជុំវិញការរស់នៅរបស់អនីតិជន
- ព្យសនកម្មរបស់ជនរងគ្រោះ និង
- សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និងសង្គមផងដែរ។

បន្ទាប់ពីការបំពេញនូវលក្ខខណ្ឌអប្បបរមា និងលក្ខណៈវិនិច្ឆ័យសម្រាប់ការបង្វែររួចហើយ អាជ្ញាធរដែលទទួលបន្ទុកបង្វែរត្រូវជ្រើសរើសវិធានការបង្វែរ ដែលត្រូវដាក់ឲ្យអនីតិជនបំពេញតួនាទីមានមួយ រឺច្រើនប្រភេទ ដូចជា[46]៖

- ចំណុចមួយ ឬច្រើនដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌស្តីពីកាតព្វកិច្ចនៃត្រួតពិនិត្យតាមផ្លូវតុលាការ[47]
- ទៅសាលារៀនឲ្យបានទៀតទាត់តាមផែនការ ឬចំណាយពេលជាមួយគ្រួសារ ឬចូលរួមក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវះ ក្នុងថេរវេលាកំណត់មិនឲ្យលើស៦ (ប្រាំមួយ) ខែ
- វិធានការបង្វែនោះ អាចឲ្យអនីតិជនធ្វើការងារសហគមន៍មិនលើស ១០០ (មួយរយ) ម៉ោងសម្រាប់អនីតិជនមានអាយុ១៦ (ដប់ប្រាំមួយ) ឆ្នាំឡើងទៅ ឬចូលរួមកម្មវិធីសហគមន៍ឬ មណ្ឌលដែលមានប្រយោជន៍សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសារជាថ្មី
- អនីតិជនអាចត្រូវបានអាជ្ញាធរទទួលបន្ទុកបង្វែដាក់ឲ្យស្នាក់នៅទីកន្លែងណាមួយក្នុងរយៈពេលកំណត់ជាក់លាក់

[45] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៤ ឆ្នាំ ២០១៦

[46] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៥ ឆ្នាំ ២០១៦

[47] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ, ឆ្នាំ២០០៧, មាត្រា ២២៣ ដល់មាត្រា ២៣០ និង សារាចរស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវជនជាប់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

- ជុសជុលសំណងការខូចខាតជូនទៅជនរងគ្រោះវិញ និង
- រួមទាំងវិធានបង្វែរផ្សេងៗទៀត ដែលបំពេញគោលបំណងនៃការបង្វែរ។

**១.៣.២.២ ការអនុវត្តផែនការបង្វែរ**

ការរៀបចំផែនការបង្វែរនេះជាបន្ទុករបស់ភ្នាក់ងារសង្គមកិច្ច ត្រូវធ្វើឡើងក្នុងរយៈពេល១ (មួយ) ខែ បន្ទាប់ពីទទួលបានដំណឹងអំពីដីការសម្រេចបង្វែរពីអាជ្ញាធរទទួលបន្ទុកបង្វែរ លើកលែងតែមានស្ថានភាពពិសេសពុំអាចជម្នះបាន។[48] ជំហានបន្ទាប់ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរដែលទទួលបន្ទុកបង្វែរ ពិនិត្យ និងសម្រេច ហើយប្រសិនអាជ្ញាធរនោះយល់ស្រប នឹងមានការចេញដីការសម្រេចឲ្យអនុវត្តផែនការបង្វែរ តែបើមិនសម្រេចនោះទេ នឹងមានការបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំផែនការជាថ្មី ដែលមានរយៈពេល ១ ខែ ដូចគ្នា។[49] ក្នុងអំឡុងពេលនៃការសម្រេចនេះ ភ្នាក់ងារសង្គមកិច្ចត្រូវសម្រេចលើកត្តាដូចជា៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្វែរដែលត្រូវបានស្នើឡើង
- សាវតា វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម ក្រៅពីនេះក៏ត្រូវពិចារណាទៅលើ
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជនផងដែរ។

បន្ទាប់មក ផែនការបង្វែរនឹងត្រូវអនុវត្តលើអនីតិជន ដោយត្រូវបានរ៉ាប់រងដោយភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែ ដើម្បីតាមដានពីវឌ្ឍនភាពនៃការរីកចម្រើនរបស់អនីតិជន រួចបញ្ជូនរបាយការណ៍នេះទៅអាជ្ញាធរទទួលបន្ទុក និងចម្លងជូនមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ច។[50] កាលដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចក្នុងផែនការបង្វែរទេ នោះនាំឲ្យមានការបរាជ័យនៃការអនុវត្តផែនការនេះ ដែលនាំឲ្យអាជ្ញាធរទទួលបន្ទុកបង្វែរបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌ។[51]

---

[48] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៦

[49] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៨

[50] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៦៩

[51] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ៧១

# ជំពូកទី២
# ដំណាក់កាលនីតិវិធីនៃការអនុវត្តចំពោះអនីតិជន

នីតិវិធីអនុវត្តចំពោះអនីតិជនមានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីដែលអនុវត្តចំពោះនីតិជនដែរ ប៉ុន្តែដោយសារតែសមត្ថភាពនៃការយល់ដឹងរបស់អនីតិជននៅមានកម្រិត ដូច្នេះទើបតម្រូវឲ្យមានការអនុវត្តនូវនីតិវិធីពិសេសមួយចំនួនចំពោះអនីតិជន។ នីតិវិធីទាំងអស់នេះ ត្រូវធ្វើតាមដំណាក់កាលដូចជា ដំណាក់កាលនៃការស៊ើបអង្កេត និងការចោទប្រកាន់ (២.១) ព្រមទាំង ដំណាក់កាលនៃការស៊ើបសួរ និងការជំនុំជម្រះ (២.២)។

## ២.១ ដំណាក់កាលនៃការស៊ើបអង្កេត និងការចោទប្រកាន់

នៅក្នុងរឿងក្តីព្រហ្មទណ្ឌ តែងតែមានការចាប់ផ្តើមឡើងនូវនីតិវិធីនៃការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ក្នុងគោលបំណងនៃការស្វែងរកភស្តុតាង ក្នុងការវិនិច្ឆ័យរកបទល្មើសនៃអង្គហេតុ។ ការស៊ើបអង្កេតជាដំណាក់កាលត្រៀមនៃរឿងព្រហ្មទណ្ឌ មុនពេលចាប់ផ្តើមនូវការចោទប្រកាន់។ បន្ទាប់ពីបញ្ចប់នៃការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅកាន់ស្ថាប័នអយ្យការដើម្បីមានចំណាត់ការបន្តដោយយោងទៅតាមភាពជាក់ស្តែង និងស្ថានភាពដែលប្រមូលបាន[52]។ ហេតុដូចនេះ ទើបមានដំណាក់ការស៊ើបអង្កេតដែលធ្វើឡើងដោយនគរបាលយុត្តិធម៌ (២.១.១) និងដំណាក់កាលចោទប្រកាន់ដោយអង្គការអយ្យការ (២.១.២)។

### ២.១.១ ដំណាក់ការស៊ើបអង្កេតដោយនគរបាលយុត្តិធម៌

រឿងក្តីព្រហ្មទណ្ឌ ត្រូវធ្វើឡើងដំបូងដោយមានការស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីស្វែងរកនូវអង្គហេតុមួយចំនួនក្នុងការចាត់ទុកជាបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចក្នុងការត្រួតពិនិត្យទៅលើបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ពាក់ព័ន្ធទៅនឹងជនសង្ស័យដែលជាអនីតិជន។ នគរបាលយុត្តិធម៌មានតួនាទីក្នុងការកំណត់នូវអត្តសញ្ញាណ ប្រមូលភស្តុតាង ដើម្បីធ្វើការឃាត់ខ្លួន ឬចាប់ខ្លួនអនីតិជនក្នុងករណីចាំបាច់ ហើយបញ្ជូន ឬប្រគល់របាយការណ៍ និងកំណត់ហេតុលំអិតនៃការចាប់ខ្លួន ឬឃាត់ខ្លួនទៅដល់អង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ពីព្រោះការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងអនីតិជនគឺត្រូវធ្វើឡើងដោយមន្ត្រីជំនាញ ឬមានការជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានការបណ្តុះបណ្តាលស្តីពីយុត្តិធម៌អនីតិជន[53]។ លើសពីនេះទៅទៀត ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទ

[52] *សូមមើល* មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ ២០០៨

[53] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១២ ឆ្នាំ២០១៦

លហុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការអប់រំ ណែនាំ ព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយប្រគល់អនីតិជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់។ ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើសដែលជាបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ ដើម្បីបញ្ចប់វិវាទ។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវធ្វើរបាយការណ៍ ព្រមទាំងបញ្ជូនសំណុំរឿងនោះទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់[54]។ ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ហើយបានប្រព្រឹត្តបទល្មើស គឺពុំត្រូវអាចឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់[55]។ លើសពីនេះទៅទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជនទៅកាន់មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំដែលទាក់ទងទៅនឹងសុខុមាលភាពព្រមទាំងស្ថានភាពសង្គមរបស់អនីតិជន ហើយមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ជូនទៅព្រះរាជអាជ្ញា[56]។

➢ **ការចាប់ខ្លួន**

បន្ទាប់ពីសង្កេតឃើញថា អនីតិជនបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចាប់ខ្លួនអនីតិជន និងរាយការណ៍ភ្លាមទៅកាន់ព្រះរាជអាជ្ញា ដើម្បីធ្វើការចាប់ខ្លួនអនីតិជននោះក្នុងគោលបំណងធ្វើការសាកសួរថាតើជននោះបានប្រព្រឹត្តបទល្មើស ឬមានជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដែររឺទេ។ លក្ខណៈពិសេសនៃការចាប់ខ្លួនអនីតិជន គឺមន្ត្រីនគរបាលយុត្តិធម៌អាចចាប់ខ្លួនបានចំពោះអនីតិជនដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំ រហូតដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងករណីអនីតិជនបានប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំវិញ ការចាប់ខ្លួននោះនឹងប្រព្រឹត្តទៅបានក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទមជ្ឈិមដោយចេតនា។ លើសពីនេះទៅទៀត ការចាប់ខ្លួនទាំងអស់ត្រូវតែធ្វើការរាយការណ៍ទៅដល់ព្រះរាជអាជ្ញាភ្លាម[57]។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជៀសវាងការធ្វើអោយអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន។ មិនតែប៉ុណ្ណោះ មន្ត្រី

[54] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៣ ឆ្នាំ២០១៦

[55] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៤ ឆ្នាំ២០១៦

[56] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៣ ឆ្នាំ២០១៦

[57] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៥ ឆ្នាំ២០១៦

នគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរទៅលើអនីតិជនបាន ប៉ុន្តែក្នុងករណីដែលគ្មានជម្រើស មន្ត្រីនគរបាលយុត្តិធម៌អាចអនុញ្ញាត និងចាត់តាំងឱ្យនីតិជនដែលមានភេទដូចគ្នាធ្វើការឆែកឆេរខ្លួនអនីតិជនដែលមានភេទដូចគ្នា ហើយត្រូវប្រាកដថាអ្នកឆែកឆេរនោះមិនជាប់ពាក់ព័ន្ធជាមួយបទល្មើស ឬពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជាមួយអនីតិជននោះឡើយ[58]។ ក្នុងសកម្មភាពនៃការចាប់ខ្លួននេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន ប៉ុន្តែប្រសិនបើមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់នោះទេ ត្រូវជូនដំណឹងទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ដែលទាក់ទងទៅនឹងមូលហេតុនៃការចាប់ខ្លួន ប្រភេទនៃបទល្មើស ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ ព្រមទាំងសិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅអង្គភាពនគរបាល។ ក្នុងករណីដែលមិនអាចទាក់ទងជាមួយនឹងអ្នកតំណាងដែលច្បាប់បានកំណត់បាននោះទេ នគរបាលយុត្តិធម៌ត្រូវតែប្រឹងប្រែងក្នុងការរកអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយនគរបាលយុត្តិធម៌ដែលមានការយល់ព្រមពីសំណាក់អនីតិជន។ លើសពីនេះទៅទៀតមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងទៅកាន់ភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាកម្មគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជន។ បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវជូនដំណឹងភ្លាមៗទៅកាន់មេធាវីរបស់អនីតិជនប្រសិនបើមាន ប៉ុន្តែក្នុងករណីដែលគ្មាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដែលមិនយកកម្រៃអនីតិជនឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះសម្រាប់អនីតិជនធ្វើការជ្រើសរើស និងតម្រូវឱ្យមានការបកប្រែភាសាដោយមិនយកកម្រៃចំពោះអនីតិជនដែលជាជនបរទេស[59]។ មិនតែប៉ុណ្ណោះ ក្រោយពេលដែលចាប់ខ្លួនអនីតិជន នគរបាលយុត្តិធម៌ត្រូវប្រាប់អនីតិជនពីសិទ្ធិមួយចំនួនដែលជាមូលដ្ឋាននៅក្នុងនីតិវិធីរបស់ខ្លួន[60] ព្រមទាំងធ្វើកំណត់ហេតុស្តីពីការចាប់ខ្លួន និងចម្លងច្បាប់នោះទៅឲ្យមេធាវីតាមការស្នើសុំ។

➢ **ការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនទៅលើអនីតិជនបាន ប្រសិនបើគេជឿជាក់ថា អនីតិជននោះអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬមានបំណងក្នុងការការពារសុវត្ថិភាពអនីតិជននោះ។ ប៉ុន្តែការឃាត់ខ្លួននេះ គឺត្រូវអាចប្រព្រឹត្តបានចំពោះអនីតិជនដែល

[58] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៦ ឆ្នាំ២០១៦

[59] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៨ ឆ្នាំ២០១៦

[60] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៦ ឆ្នាំ២០១៦

មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ រហូតដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំប៉ុណ្ណោះ។ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចប្រព្រឹត្តទៅបានប្រសិនបើអនីតិជននោះបានប្រព្រឹត្តបទមជ្ឈិមដោយចេតនាតែប៉ុណ្ណោះ ហើយការឃាត់ខ្លួនទាំងអស់នេះ ត្រូវធ្វើការរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម (ការឃាត់ខ្លួនគឺសម្រាប់វិធានការចុងក្រោយប៉ុណ្ណោះ)[61]។ ចំពោះការជូនដំណឹងបន្ទាប់ពីឃុំខ្លួន អនីតិជនគឺត្រូវមាននីតិវិធីដូចនឹងការចាប់ខ្លួនរបស់អនីតិជនផងដែរ[62]។

លក្ខណៈពិសេសនៃការអនុវត្តការឃាត់ខ្លួនទៅលើអនីតិជននេះ គឺមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើយ ក្នុងករណីដែលគ្មានការយល់ព្រមជាមុនពីអនីតិជន ឬចាំបាច់ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី និងអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជននោះជាមុន។ ប្រសិនបើអនីតិជនមានការយល់ព្រម ត្រូវតែមាននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ ព្រមទាំងផ្តិតម្រាមដៃពីសំណាក់អនីតិជនផងដែរ។ ការឃាត់ខ្លួននេះ អនីតិជនត្រូវតែដាក់ដោយឡែកពីនីតិជន និងតាមភេទ ហើយមិនត្រូវទទួលរងនូវទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង សម្លុតបំភិតបំភ័យ ឬទង្វើដែលធ្វើឲ្យមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬអំពើអមនុស្សធម៌ណាមួយ ដោយត្រូវស្របទៅតាមគោលការណ៍នៃសន្ធិសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងលិខិតុបករណ៍នានា។ បើមិនដូច្នេះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី[63]។ មិនតែប៉ុណ្ណោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ចប់នូវការស៊ើបអង្កេតរបស់ខ្លួនអោយបានឆាប់រហ័ស និងលឿនបំផុតតាមដែលអាចធ្វើទៅបានដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន ដែលរយៈពេលនៃការឃាត់ខ្លួន គឺត្រូវអាស្រ័យទៅតាមអាយុ និងប្រភេទនៃបទល្មើស (បទឧក្រិដ្ឋ ឬបទមជ្ឈិម) ។ ចំពោះអនីតិជនដែលមានអាយុ ១៤ ឆ្នាំ ដល់ក្រោម១៦ ឆ្នាំ ដែលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៣៦ ម៉ោងឡើយ ។ ចំពោះអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ដែលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៤៨ ម៉ោងឡើយ ។ ចំពោះអនីតិជនដែលមានអាយុ ១៤ ឆ្នាំ ដល់ក្រោម១៦ ឆ្នាំ ដែលប្រព្រឹត្តបទមជ្ឈិម មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ២៤ ម៉ោងឡើយ។ ចំពោះអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ដែលប្រព្រឹត្តបទមជ្ឈិម មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៣៦ ម៉ោងឡើយ ។ ចំពោះ

[61] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៧ ឆ្នាំ២០១៦

[62] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ១៨ ឆ្នាំ២០១៦

[63] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៣ ឆ្នាំ២០១៦

អនីតិជនដែលមានអាយុក្រោម១៤ ឆ្នាំ ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ[64]។ ប្រសិនបើគ្មានតម្រុយនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្តទេ នគរបាលយុត្តិធម៌មិនអាចបន្តនូវរយៈពេលនៃការឃាត់ខ្លួនបាននោះទេ ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការដោះលែងអនីតិជននោះទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាល ឬនីតិជនដែលទទួលខុសត្រូវលើអនីតិជន ដោយបញ្ជាក់នូវលក្ខខណ្ឌមួយចំនួនមុនការដោះលែងដូចជា តម្រូវអនីតិជននៅក្នុងផ្ទះក្នុងរយៈពេលណាមួយ តម្រូវឱ្យរាយការណ៍ដល់នគរបាលនូវពេលវេលាជាក់លាក់ណាមួយ ព្រមទាំងហាមមិនឲ្យអនីតិជនសេពគ្រឿងស្រវឹងផ្សេងៗ រួមបញ្ចូលទាំងហាមមិនឲ្យជួបជនរងគ្រោះ មិនឲ្យធ្វើដំណើរទៅកន្លែងណាមួយ ឬលក្ខខណ្ឌដែលសមស្របតាមស្ថានភាពមួយ។

➢ **ការស្តាប់ចម្លើយ[65]**

មុនពេលចាប់ផ្តើមនូវការស្តាប់ចម្លើយ ប្រសិនបើមានការស្នើរសុំ អនីតិជនអាចធ្វើការសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវី ជាលក្ខណៈឯកជន និងសម្ងាត់ ដែលមានរយៈពេល ៣០ (សាមសិប) នាទីមុនពេលស្តាប់ចម្លើយ លើកលែងតែជនទាំងនោះទាក់ទិនក្នុងរឿងជាមួយគ្នា[66]។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រាប់ដល់អនីតិជនអំពីសិទ្ធិមូលដ្ឋានក្នុងនីតិវិធីដូចដែលមានចែងក្នុងមាត្រា ៦ ដល់អនីតិជន ជាពិសេសគឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី។ លើសពីនេះទៅទៀត ការស្តាប់ចម្លើយត្រូវប្រព្រឹត្តទៅដោយមានវត្តមានមេធាវីដោយប្រើប្រាស់នីតិវិធីកុមារមេត្រីដែលមានលក្ខណៈឯកជន និងជាការសម្ងាត់។ រីឯអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចមានសិទ្ធិក្នុងការផ្តល់ជំនួយដល់អនីតិជន និងចូលរួមស្តាប់ចម្លើយរបស់អនីតិជនផងដែរ។ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចបដិសេធចំពោះការចូលរួមអ្នកទាំងនោះបានទេ ប្រសិនបើយល់ឃើញថាវត្តមានរបស់ពួកគេអាចធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន ហើយការបដិសេធនេះគឺត្រូវមានការពិគ្រោះយោបល់ជាមួយនឹងមេធាវីភ្នាក់ងារសង្គមកិច្ច ឬអនីតិជនផ្ទាល់។ បន្ទាប់ពីបញ្ចប់នូវការស្តាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុនៃចម្លើយបាន។ លើសពីនេះទៅទៀត អនីតិជនក៏អាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ។ មិនតែប៉ុណ្ណោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គម

[64] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៩៦ ឆ្នាំ ២០០៧

[65] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២២ ឆ្នាំ២០១៦

[66] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២១ ឆ្នាំ២០១៦

កិច្ចដែលវត្តមានត្រូវចុះហត្ថលេខា និងផ្តិតស្រាមដៃលើកំណត់ហេតុផងដែរ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះត្រូវមានលក្ខណៈដាច់ខាត ដោយត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានការមោឃភាពនៃនីតិវិធីនេះ។ បន្ទាប់ពីបានធ្វើកំណត់ហេតុ និងពិនិត្យផ្ទៀងផ្ទាត់ដោយអនីតិជនរួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ជំនាញបញ្ចប់នីតិវិធីរបស់ខ្លួន រួចបញ្ជូនសំណុំរឿងបន្តទៅតំណាងអយ្យការ ដើម្បីពិនិត្យ និងធ្វើចំណាត់ការបន្ត។

**២.១.២ ដំណាក់កាលចោទប្រកាន់ដោយអង្គការអយ្យការ**

នៅពេលដែលទទួលបានសំណុំរឿងបន្តពីមន្ត្រីនគរបាលយុត្តិធម៌ហើយ តំណាងអយ្យការត្រូវត្រួតពិនិត្យសំណុំឯកសារ និងបណ្តឹងដែលបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុពិតប្រាកដរបស់អនីតិជន មុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ។ ក្នុងករណីដែលមានវិមតិសង្ស័យចំពោះអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមអោយបានឆាប់បំផុត ដើម្បីស្វែងរកនូវអាយុពិតប្រាកដរបស់អនីតិជន។ ក្នុងករណីដែលការស៊ើបអង្កេតបឋមនោះមិនឈានដល់ការសន្និដ្ឋានអំពីអាយុពិតរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ[67]។ បណ្តឹងអាជ្ញាត្រូវអនុវត្តដោយអយ្យការក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន ហើយតំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងទៅនឹងយុត្តិធម៌អនីតិជន[68]។

ចំពោះនីតិវិធីនៃការស្តាប់ចម្លើយរបស់ព្រះរាជអាជ្ញា គឺមិនមានលក្ខណៈខុសប្លែកពីនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌នោះទេ ដោយព្រះរាជអាជ្ញាធ្វើការស្តាប់ចម្លើយរបស់អនីតិជន និងធ្វើការសន្និដ្ឋានទៅលើសំណុំរឿងនោះតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ចំពោះអនីតិជន ពោលគឺមុនពេលនៃការស្តាប់ចម្លើយព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមអំពីសិទ្ធិដែលមានចែងក្នុងមាត្រា ៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជន។ មិនតែប៉ុណ្ណោះការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រីដែលត្រូវមានវត្តមានរបស់មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងរបស់អនីតិជន។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឱ្យអ្នក

[67] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៥ ឆ្នាំ២០១៦

[68] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៤ ឆ្នាំ២០១៦

តំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់បាន ប្រសិនបើវត្តមានរបស់អ្នកទាំងនោះប៉ះពាល់ឧត្តមប្រយោជន៍របស់អនីតិជន ប៉ុន្តែត្រូវតែមានការពិគ្រោះជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជនជាមុនសិន។ ក្នុងករណីអវត្តមានជនណាមួយ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ហើយបញ្ជាក់អំពីមូលហេតុ។ បន្ទាប់ពីបញ្ចប់នូវការស្តាប់ចម្លើយភ្លាម អនីតិជន មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច អាចធ្វើការអាននូវកំណត់ហេតុស្តាប់ចម្លើយបាន។ ប្រសិនបើពួកគេមិនអាចអានបាននោះទេ ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុឱ្យពួកគាត់ស្តាប់។ អនីតិជនអាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយទៅលើកំណត់ហេតុស្តាប់ចម្លើយបាន។ បន្ទាប់មក ជនទាំងនោះត្រូវធ្វើការចុះហត្ថលេខា និងផ្តិតម្រាមដៃ ប៉ុន្តែក្នុងករណីដែលពួកគេមិនព្រមក្នុងការចុះហត្ថលេខាលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ[69]។

ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងបញ្ជូនអនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាលវិញ។ លើសពីនេះទៅទៀត ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជនទៅកាន់មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីនេះ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន[70]។

តំណាងអយ្យការក៏មានអំណាចក្នុងការបង្វែរ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ដោយការបង្វែរនេះ ព្រះរាជអាជ្ញាត្រូវពិចារណាទៅលើការបង្វែរក្នុងជំពូកទី១០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងយកបទប្បញ្ញត្តិទាំងនោះមកអនុវត្ត។ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ហើយបង្គាប់ប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលការគ្រប់គ្រងថែរក្សា។ ចំពោះករណីនេះ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន។ ព្រះរាជអាជ្ញាត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជន ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកទៅលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួល

[69] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៦ ឆ្នាំ២០១៦

[70] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៧ ឆ្នាំ២០១៦

បន្ទុកអនុវត្តផែនការបង្វែរ។ ប៉ុន្តែក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំអោយមានការបរាជ័យចំពោះការអនុវត្តផែនការបង្វែរនេះ និងពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី[71]។

ចំពោះការឲ្យដំណឹងអំពីការចោទប្រកាន់ ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅកាន់អនីតិជន ហើយប្រសិនបើសមស្រប ត្រូវជូនដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីឲ្យធ្វើការរៀបចំមធ្យោបាយការពារអនីតិជននោះ[72]។ ដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបញ្ញត្តិថា ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថាអ្នកប្រព្រឹត្ត នោះមានសហការី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញនូវដីកានៃការបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នាផងដែរ។

## ២.២ ដំណាក់កាលនៃការស៊ើបសួរ និងការជំនុំជម្រះ

នីតិវិធីបន្ទាប់ដែលអនុវត្តចំពោះអនីតិជន ត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរដើម្បីប្រមូលធាតុផ្សំសម្រាប់កាត់សេចក្តី និងសម្រេចចំពោះការចោទប្រកាន់ ពោលគឺចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចស៊ើបសួរ ដើម្បីបង្ហាញឲ្យឃើញការពិតសម្រាប់ដាក់បន្ទុក និងដោះបន្ទុក។ បន្ទាប់មកចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមជំនុំជម្រះ ដើម្បីធ្វើការជំនុំជម្រះ។ ហេតុដូចនេះទើបមានការបកស្រាយទៅលើ ដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ (២.២.១) និងដំណាក់កាលជំនុំជម្រះដោយសាលាដំបូង និងតុលាការជាន់ខ្ពស់ (២.២.២)។

### ២.២.១ ដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ

បន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីតំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម និងត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ហើយវាជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរដែលមានជំនាញទាក់ទងទៅនឹងអនីតិជន។

ការស៊ើបសួរ គឺជាតួនាទីរបស់ចៅក្រមស៊ើបសួរក្នុងការប្រមូលផ្តុំធាតុផ្សំចាំបាច់សម្រាប់កាត់សេចក្តី និងសម្រេចក្នុងការចោទប្រកាន់។ យោងតាមមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញ

[71] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៨ ឆ្នាំ២០១៦

[72] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ២៩ ឆ្នាំ២០១៦

ការពិតដែលអនុលោមតាមច្បាប់[73]។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរមានករណីកិច្ចក្នុងការដាក់បន្ទុក និងដោះបន្ទុកថែមទៀតផង។ ជនត្រូវចោទជាអនីតិជនត្រូវមានវត្តមានមេធាវីអមជានិច្ចក្នុងពេលស្តាប់ចម្លើយនៅចំពោះមុខ ហើយចៅក្រមស៊ើបសួរត្រូវទុកពេលវេលាសមស្របដល់មេធាវីក្នុងការពិនិត្យសំណុំរឿង និងពិភាក្សាជាមួយអនីតិជនមុននឹងចាប់ផ្តើមសួរចម្លើយ។ នៅពេលដែលអនីតិជនបានបង្ហាញខ្លួនដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានដែលទាក់ទងទៅនឹងដំណាក់កាលនៃការស៊ើបសួរដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ហើយចៅក្រមស៊ើបសួរត្រូវប្រាប់អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់។

ចំពោះនីតិវិធីនៃការស្តាប់ចម្លើយរបស់អនីតិជនគឺមិនមានលក្ខណៈខុសប្លែកពីនីតិវិធីនៃការស្តាប់ចម្លើយរបស់ព្រះរាជអាជ្ញា និងនគរបាលយុត្តិធម៌នោះទេ ប៉ុន្តែក្នុងករណីនេះក៏មានវត្តមានរបស់ក្រឡាបញ្ជីដែលជាជំនួយការ និងត្រូវតែមានការស្តាប់ចម្លើយផ្ទាល់ពីសំណាក់ចៅក្រមស៊ើបសួរ។ ការស្តាប់ចម្លើយនេះត្រូវធ្វើជាលក្ខណៈសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី។ ចៅក្រមស៊ើបសួរត្រូវទុកពេលវេលាសមស្របឱ្យមេធាវីពិនិត្យមើលសំណុំរឿង និងពិភាក្សាជាមួយអនីតិជន មុនពេលចាប់ផ្តើមសួរចម្លើយ។ ក្នុងករណីអវត្តមានមេធាវី ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវី ដើម្បីចូលរួមក្នុងការស្តាប់ចម្លើយលើកលែងតែ ក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់តម្រុយនៃភស្តុតាង។ ប្រភេទនៃការបន្ទាន់នេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ពិសេសវត្តមាន ឬអវត្តមានរបស់មេធាវី មិនរាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្នចំពោះអនីតិជនឡើយ។

ចំពោះការព្យួរការសិក្សា និងការងារសម្រាប់អនីតិជនវិញ ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជកមិនឱ្យព្យួរការសិក្សា ឬការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ ប៉ុន្តែក្នុងករណីដែលអនីតិជនបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរ គ្រឹះស្ថាន ឬនិយោជកអាចព្យួរការងារ ឬនយោជកអាចព្យួរការសិក្សារហូតដល់មានសេចក្តីសម្រេចរបស់តុលាការជាស្ថាពរ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលទៅធ្វើការ ឬសិក្សាជាធម្មតាវិញ[74]។

[73] *សូមមើល* មេរៀននីតិវិធីព្រហ្មទណ្ឌ, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨

[74] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៣៧ ឆ្នាំ២០១៦

លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការអនុវត្តផែនការបង្វែរដោយក្នុងករណីដែលអនីតិជនត្រូវបានចោទប្រកាន់ថាប្រព្រឹត្តបទមជ្ឈិម ឬបទមជ្ឈិមដែលមានស្ថានទម្ងន់ទោស។ ដូច្នេះចៅក្រមស៊ើបសួរត្រូវតែធ្វើការពិចារណាជាបឋមទៅលើការបង្វែរមុននឹងប្រើនូវវិធានការផ្សេងទៀត។ នៅពេលទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរហើយ អនីតិជនដែលមានអាយុពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលតំណាងអង្គការអយ្យការចោទប្រកាន់ថាបានប្រព្រឹត្តល្មើស ចៅក្រមស៊ើបសួរត្រូវគិតជាបឋមពីការបង្វែរ ពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណស្ថានភាពអនីតិជន និងត្រូវពិនិត្យលើលក្ខខណ្ឌអប្បបរមានៃការបង្វែរ។ រាល់បទមជ្ឈិមដែលមានស្ថានទម្ងន់ទោសដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចពិចារណាពីការបង្វែរបានដោយមានលក្ខខណ្ឌទាំងបីដូចខាងក្រោម៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុល
- អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ។

ក្នុងករណីដែលបានបំពេញនូវលក្ខខណ្ឌអប្បបរមានៃការបង្វែរគ្រប់គ្រាន់ហើយ ចៅក្រមស៊ើបសួរនឹងសម្រេចថាគួរតែបង្វែរ ឬមិនបង្វែរនូវរឿងក្តីនេះ។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឲ្យបង្វែរ នីតិវិធីនៃការស៊ើបសួរត្រូវបានផ្អាកដោយដីកាសម្រេច និងបង្គាប់ឱ្យដោះលែងអនីតិជនដែលបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីធ្វើការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីជាផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ។ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះអំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ។ ហេតុដូច្នេះជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះអាចធ្វើការប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន។ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបានបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ ក្នុងករណីដែលអនីតិជនអនុវត្តការងារដោយមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ និងពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី។

លើសពីនេះទៅទៀត ការឃុំខ្លួនអនីតិជនជាបណ្តោះអាសន្នត្រូវតែជាវិធានការចុងក្រោយបំផុតក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា អនីតិជនទំនាស់នឹងច្បាប់អាចបង្កភាពចលាចលក្នុងពេលធ្វើការអង្កេត។ ប៉ុន្តែ

ចៅក្រមស៊ើបសួរត្រូវតែពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរ។ ចៅក្រមស៊ើបសួរអាចដាក់អនីតិជនដែលជាជនត្រូវចោទឱ្យនៅក្រោមការត្រួតពិនិត្យរបស់ផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនជាបណ្ដោះអាសន្ន ប្រសិនបើអ្នកជាជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ។ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ហើយការឃុំខ្លួនបណ្ដោះអាសន្ននេះអាចធ្វើបាននៅក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានកំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ។

ចៅក្រមស៊ើបសួរអាចបង្គាប់ដោះលែងអនីតិជនអោយនៅក្រៅឃុំបានគ្រប់ពេលវេលាដោយគំនិតផ្ដួចផ្ដើមរបស់ខ្លួនដោយមានលក្ខខណ្ឌមួយចំនួនដូចជា៖

- ដាក់អនីតិជនអោយស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកទំនុកបម្រុងរបស់អនីតិជន
- ដាក់អនីតិជនអោយស្ថិតក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនដើរហួសម៉ោង ឬសេពគ្រឿងស្រវឹង
- បង្គាប់ឲ្យអនីតិជនចូលបង្ហាញខ្លួនតាមការកំណត់នៃអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលត្រូវចាត់តាំងដោយចៅក្រមស៊ើបសួរ
- ឆ្លើយតបនឹងកោះហៅពីបុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ
- មិនត្រូវកាន់កាប់អាវុធគ្រប់ប្រភេទតាមខ្លួន

ប្រសិនបើអនីតិជនធ្វើការគេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនអនីតិជននោះជាបណ្ដោះអាសន្នបានដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ប្រសិនបើមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្ដល់របាយការណ៍បន្ថែមនៅក្នុងរយៈពេលខ្លីបំផុតតាមដែលអាចធ្វើទៅបាន

ដោយមិនឱ្យលើសរយៈពេល ១០ (ដប់) ថ្ងៃនៃការធ្វើការ[75]។ ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងចោទប្រកាន់ក្នុងករណី

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- អនីតិជនដែលបានប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើអនីតិជនត្រូវចោទ

ដីកាដំណោះស្រាយលើកលែងចោទប្រកាន់មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ចៅក្រមស៊ើបសួរត្រូវបង្គាប់ប្រគល់អនីតិជនទៅឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន។ បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញសេចក្តីសម្រេចរបស់ខ្លួនរួចមក ព្រះរាជអាជ្ញាអាចធ្វើការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍បាន ចំពោះដីកាលើកលែងការចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដោយការបង្វែរ ដែលសម្រេចដោយចៅក្រមស៊ើបសួរក្នុងការដែលយល់ឃើញថា សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរមិនសមស្រប ដោយពិចារណាជាចម្បងឧត្តមប្រយោជន៍របស់អនីតិជន។ កាលណាមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរត្រូវរៀបចំបែបបទបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃទទួលបណ្តឹងឧទ្ធរណ៍លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជំនះបាន។

### ២.២.២ ដំណាក់កាលជំនុំជម្រះដោយសាលាដំបូង និងតុលាការជាន់ខ្ពស់

រឿងក្តីអាចបញ្ចប់លុះត្រាតែបានឆ្លងកាត់នូវការជំនុំជម្រះដែលធ្វើឡើងក្នុងសវនាការ រួមទាំងប្រកាសសាលក្រមផងដែរ។ ការជំនុំជម្រះរឿងក្តីអនីតិជនត្រូវធ្វើឡើងដោយចៅក្រមជំនុំជម្រះដោយមានជំនាញទាក់ទងទៅនឹងអនីតិជន។

- **សមត្ថកិច្ចរបស់សាលាដំបូង**

ចំពោះបទឧក្រិដ្ឋព្រមទាំងបទមជ្ឈឹម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិមត្រូវមានសមាសភាពចៅក្រមជំនុំជំរះចំនួន ៣ (បី) រូប ធ្វើការពិភាក្សា និងសម្រេចថានីតិជនមាន ឬគ្មានទោស។ ចំពោះបទលហុនៃអនីតិជន គឺមានតែចៅក្រមម្នាក់ដែលធ្វើការសម្រេចសេចក្តី។ តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនជាអាទិភាព ជាពិសេសរឿងដែលអនីតិជនកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន។ លើសពីនេះទៅទៀតការពិភាក្សាដេញ

[75] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤២ ឆ្នាំ២០១៦

ដោល និងប្រកាសសាលក្រមរបស់អនីតិជនត្រូវធ្វើនៅក្នុងសវនាការជាអសាធារណៈ ហើយមានតែបុគ្គលមានសិទ្ធិ និងកាតព្វកិច្ចពីផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីតែប៉ុណ្ណោះដែលមានសិទ្ធិក្នុងការចូលរួមក្នុងសវនាការបាន។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានការសំណូមពររបស់អនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាបុគ្គលទាំងនោះមិនបំពើឲ្យឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលសវនាការ។ តុលាការត្រូវប្រើនីតិវិធីកុមារមេត្រី ហើយក្នុងកាលៈទេសៈពិសេស មេធាវីរបស់អនីតិជន ភ្នាក់ងារសង្គមកិច្ច ឬព្រះរាជអាជ្ញាអាចស្នើសុំឱ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការស្តាប់ចម្លើយ។

ចំពោះការឲ្យរួចផុតពីបទចោទ ក្នុងករណីដែលតុលាការរកឃើញថាអនីតិជនជាប់ចោទមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ និងដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីជាមានការប្តឹងពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់ទៅឱ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់នីតិជន។ ដូច្នេះ ក្នុងករណីតុលាការរកឃើញថាអនីតិជនបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីដែលតុលាការឃើញថា អំពើដែលចោទប្រកាន់លើអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់គ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ទោះបីជាមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់ ប្រសិនបានយុវជននោះមិនត្រូវជាប់ឃុំពីបទល្មើសផ្សេងទៀត[76]។

ជាមួយគ្នានេះ ជំនួយរបស់មេធាវីត្រូវតែមានជាដាច់ខាតក្នុងពេលសវនាការ។ ក្នុងករណីគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ នៅពេលដែលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បានហើយប្រាប់អំពីសិទ្ធិដែលមានដូចជា[77]៖

- សិទ្ធិទាក់ទងនឹងដំណាក់កាលនៃជំនុំជំរះដូចមានចែងក្នុងមាត្រា ៦ (សិទ្ធជាមូលដ្ឋានក្នុងនីតិវិធី)
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្យ

[76] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៤៩ ឆ្នាំ២០១៦

[77] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៥១ ឆ្នាំ២០១៦

- សិទ្ធិប្ដឹងជិតចិត្តចៅក្រមជំនុំជម្រះ
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្ដឹងឧទ្ធរណ៍

វិធានការបង្វែរ គឺត្រូវបានយកមកពិចារណាក្នុងដំណាក់កាលនៃការជំនុំជម្រះដោយមានលក្ខណៈដូចទៅនឹងដំណាក់កាលនៃព្រះរាជអាជ្ញា និងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ។ ចៅក្រមអាចធ្វើវិធានការបង្វែរចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ ១៨ (ដប់ប្រាំបី) ឆ្នាំដែលជាប់ពីបទលហុ បទមជ្ឈឹម និងបទមជ្ឈិមមានស្ថានទម្ងន់ទោស ដូចដែលមានចែងក្នុងជំពូកទី ១០ ការបង្វែរនៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។

ប្រសិនបើអនីតិជនអាចសារភាពនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តពេលជំនុំជម្រះ តុលាការត្រូវពិនិត្យថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពដែលទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង គ្មានការបង្ខិតបង្ខំណាមួយ។ ប្រសិនបើចម្លើយសារភាពរបស់អនីតិជនផ្ទុយទៅនឹងបញ្ញត្តិខាងលើនេះ គឺមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ ចំពោះការសារភាពទទួលយកផែនការបង្វែរមិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាពក្នុងបទល្មើសដទៃដែលសម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់ឡើយ[78] ។ ក្នុងពេលសវនាការ តុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស។

សាលក្រមអាចធ្វើការប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ដែលការប្រកាសនេះត្រូវធ្វើឡើងជាអសាធារណៈ នៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ឬភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្ដី។ មិនតែប៉ុណ្ណោះ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខ ធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន។

- **សមត្ថកិច្ចរបស់តុលាការជាន់ខ្ពស់**

តុលាការជាន់ខ្ពស់ជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងសារទុក្ខ ដែលការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធទៅនឹងរឿងអនីតិជន គឺសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍ រីឯការជំនុំជម្រះលើបណ្ដឹងសារទុក្ខដែលពាក់ព័ន្ធទៅនឹងរឿងក្ដីអនីតិជនគឺជាសមត្ថកិច្ចរបស់តុលាការកំពូល។

[78] *សូមមើល* ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ៥៣ ឆ្នាំ២០១៦

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពចៅក្រមជំនាញទាក់ទងនឹងអនីតិជនយ៉ាងតិច ១ (មួយ) រូប ហើយតុលាការត្រូវតែផ្តល់អាទិភាពពិសេសដល់រឿងក្តីដែលមានអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន។ ការជំនុំជម្រះនេះ គឺត្រូវធ្វើក្នុងអំឡុងពេល ៣ (បី) ខែយ៉ាងយូរ គិតពីថ្ងៃទទួលសំណុំរឿង លើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន[79]។ លើសពីនេះទៅទៀត ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលជំនុំជម្រះ សាលាឧទ្ធរណ៍ និងតុលាការកំពូល គប្បីពិចារណាអំពីការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន និងមានសេរីភាព។ ចំពោះអនីតិជនតុលាការជាន់ខ្ពស់ក៏មានអំណាចក្នុងការបង្វែរ ក្នុងករណី៖

- ភាពចលាចលដល់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបានបញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួច
- អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលរួមរស់នៅក្នុងសង្គមវិញ

តុលាការជាន់ខ្ពស់ត្រូវសម្រេចសេចក្តីឱ្យបង្វែរ និងបង្គាប់ឲ្យដោះលែងអនីតិជនដែលកំពុងជាប់ឃុំនោះភ្លាម ទោះបីជាមានបណ្តឹងសារទុក្ខពីព្រះរាជអាជ្ញាក៏ដោយ។ ចំពោះនីតិវិធីរបស់តុលាការជាន់ខ្ពស់ គឺត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី និងត្រូវមានមេធាវីការពារជានិច្ច ព្រមទាំងពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ ប្រសិនបើអនីតិជនមិនមានលទ្ធភាពពឹងពាក់មេធាវីបានទេ តុលាការត្រូវចាត់វិធានការឱ្យអនីតិជននោះ ហើយចំពោះការពិភាក្សាដេញដោល និងប្រកាសដីការឿងក្តីអនីតិជនត្រូវធ្វើក្នុងសវនាការជាសម្ងាត់។

[79] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៥៧ ឆ្នាំ២០១៦

# ជំពូកទី៣
# ការអនុវត្តទោសចំពោះអនីតិជន

បន្ទាប់ពីតុលាការធ្វើការវិនិច្ឆ័យសម្រេចសេចក្តីទៅលើភស្តុតាង មូលទោស និងការស្តាប់ចម្លើយរបស់អនីតិជន ដែលអាស្រ័យទៅលើការប្រព្រឹត្តបទល្មើសជាបទលហុ បទមជ្ឈឹម ឬបទឧក្រិដ្ឋហើយ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈ បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ឬប្រើនូវទណ្ឌកម្មផ្សេងទៀតមួយចំនួនដែលច្បាប់បានកំណត់ជាក់លាក់នៅក្នុងការអនុវត្តទៅលើអនីតិជន។ អនុសញ្ញាស្តីពីសិទ្ធិកុមារបានចែងថា ទោះបីកុមារបានទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក្តី ការធ្វើខុសបែបនេះត្រូវធ្វើក្នុងលក្ខណៈមួយដែលលើកកម្ពស់ដល់ការធ្វើសមាហរណកម្មកុមារចូលទៅក្នុងសង្គមជាតិវិញ ដោយវិធីសាស្ត្រនៃការដាក់ទណ្ឌកម្មត្រូវហាមឃាត់ ហើយការដាក់ទណ្ឌកម្មណាមួយត្រូវតែសមាមាត្រ មិនត្រឹមតែចំពោះបទល្មើសប៉ុណ្ណោះទេ ថែមទាំងសមាមាត្រទៅនឹងប្រវត្តិ និងកាលៈទេសៈរបស់កុមារម្នាក់ៗទៀតផង។

យោងតាមស្មារតីនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ការអនុវត្តទោសចំពោះអនីតិជនគឺធ្វើឡើងក្នុងគោលបំណងដើម្បីស្តារនីតិសម្បទាដល់អនីតិជនតែប៉ុណ្ណោះ ដែលមានគោលបំណងក្នុងការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយឱ្យអនីតិជនក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ។ អនីតិជនក៏អាចទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌដូចនីតិជនផងដែរ ប៉ុន្តែអ្វីដែលខុសគ្នានោះគឺរបបនៃទោសដែលត្រូវលើកយកមកអនុវត្តចំពោះអនីតិជន គឺមិនដូចគ្នាទៅនឹងរបបនៃទោសដែលអនុវត្តចំពោះនីតិជនឡើយ ដោយអនីតិជនមានរបបគតិយុត្តិពិសេសមួយដាច់ដោយឡែកពីនីតិជនដែលរបស់ទាំងនេះគឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីបញ្ញត្តិនៃមាត្រា ១៦០ ដល់មាត្រា ១៦៦ ផ្ទាល់តែម្តង។ ការផ្តន្ទាទោសចំពោះអនីតិជនជាទូទៅ រួមទាំងប្រភេទនៃទោសដែលអាចអនុវត្តបានមានដូចជាការផាកពិន័យ (៣.១) ការដាក់ក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា (៣.២) ព្រមទាំងការផ្តល់ ការមាននីតិសម្បទាឡើងវិញ និងការដោះលែងដោយមានលក្ខខណ្ឌ (៣.៣)។

### ៣.១ ការពិន័យចំពោះអនីតិជន

ការអនុវត្តទោសពិន័យចំពោះអនីតិជន គឺជាទោសព្រហ្មទណ្ឌមួយប្រភេទ ដែលស្ថិតនៅក្នុងឋានៈជាមូលទោស ហើយខុសពីទណ្ឌកម្មផ្សេងៗទៀតដែលចៅក្រមបានធ្វើការប្រកាសផ្តន្ទាទោស ពោលគឺសំដៅលើទោសមួយប្រភេទដែលមានគោលដៅធ្វើឲ្យជនល្មើសនោះមានការរាងចាលតែម្តង[80]។ ក្នុងករណីអនីតិជនម្នាក់បានប្រព្រឹត្តបទល្មើស ចៅក្រមអាចប្រកាសឲ្យអនីតិជននោះបង់សំណងចូលថវិការដ្ឋផង និងសម្រេចឱ្យបង់សំណងរដ្ឋប្បវេណីទៅជនរងគ្រោះថែមទៀតផង។ ដើម្បីធានានូវការបង់ប្រាក់ពិន័យ វិធានការជាទូទៅដែលត្រូវយកមកអនុវត្តចំពោះទណ្ឌិតដែលជាអនីតិជន គឺការដាស់តឿនឱ្យបង់ប្រាក់ពិន័យ (៣.១.១) ដែលធ្វើឡើងដោយអាជ្ញាធរតុលាការ ហើយក្នុងករណីអនីតិជនមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជន (៣.១.២) នោះឡើយ ។

#### ៣.១.១ ការដាស់តឿនឱ្យបង់ប្រាក់ពិន័យ[81]

ក្នុងករណីដល់ការកំណត់ដែលត្រូវបង់ប្រាក់ពិន័យ ហើយទណ្ឌិតមិនបានបង់នោះទេ អង្គភាពរតនាគារត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអមនៃអយ្យការអមសាលាដំបូង ហើយព្រះរាជអាជ្ញាត្រូវកំណត់រយៈពេលចុងក្រោយបង្អស់សម្រាប់ឱ្យទណ្ឌិតដែលជាអនីតិជនទៅធ្វើការបង់ប្រាក់ពិន័យ។ ចំពោះរយៈពេលដែលបានកំណត់ គឺមិនអាចតិចជាង ១០ ថ្ងៃឡើយ ហើយការជូនដំណឹងនេះ គឺចាំបាច់ត្រូវតែធ្វើដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលវាត្រូវធ្វើឡើងជាកំណត់ហេតុ ហើយត្រូវចុះហត្ថលេខាដោយទណ្ឌិត ឬផ្តិតម្រាមដៃ (ទណ្ឌិតមិនចេះចុះហត្ថលេខា)។ ទោះបីជាមានការជូនដំណឹងដោយព្រះរាជអាជ្ញា អំពីការដាស់តឿនឲ្យទណ្ឌិតដែលជាអនីតិជនបង់ប្រាក់បែបនេះក៏ដោយ ក្នុងករណីដែលអនីតិជននោះនៅតែមិនព្រមបង់ប្រាក់ពិន័យទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តវិធានការបង្ខំដល់រូបកាយចំពោះអនីតិជននោះឡើយ។

#### ៣.១.២ ការរួចខ្លួនពីការបង្ខំដល់រូបកាយ

ដើម្បីធានាដល់ការបង់ប្រាក់ពិន័យ គឺត្រូវតម្រូវឲ្យមានវិធានការពីរ ដែលលើកមកអនុវត្តគឺ ការរឹបអូស និងការបង្ខំដល់រូបកាយ ដែលការដកហូតទ្រព្យសម្បត្តិ គឺត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ចំណែកឯការបង្ខំដល់រូបរាងកាយ ត្រូវអនុវត្តតាមបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ៥២៣ រហូតដល់មាត្រា ៥៣៣។ លើសពីនេះទៅទៀត ការបង្ខំដល់រូបរាងកាយទៀតសោត ត្រូវតែអាចធ្វើបាន លុះត្រាតែទណ្ឌិតនោះ

[80] *សូមមើល* ទោសព្រហ្មទណ្ឌ, លោក កៅសីហា ទំព័រ ៨៤

[81] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥២៥ ឆ្នាំ ២០០៧

មានចេតនាគេចវេសមិនព្រមបង់ប្រាក់ពិន័យ ដែលឈានរហូតដល់ការបង្ខំដល់រូបរាងកាយ ដើម្បីទាមទារប្រាក់ពិន័យបើទោះបីជាទណ្ឌិតលើកសំអាងថាខ្លួនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ពិន័យក៏ដោយ[82]។ ការបកស្រាយបែបនេះ ធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់បុគ្គលដែលមានជីវភាពក្រីក្រដែលមិនមានលទ្ធភាពបង់ប្រាក់ពិន័យប្រាកដមែន ដែលអាចទទួលរងនូវការចាប់ដាក់ពន្ធនាគារដោយសារតែមូលហេតុនេះ។ ដូច្នេះថ្វីត្បិតតែក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងជាក់លាក់តម្រូវឲ្យមានការគេចវេសដោយចេតនាក្នុងការបង់ប្រាក់ពិន័យ ដើម្បីអាចបង្ខំដល់រូបរាងកាយក៏ដោយ ក៏គួរគប្បីកំណត់យុទ្ធសាស្ត្រនូវលក្ខខណ្ឌនេះ ដើម្បីធានាឲ្យមានការគោរពសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់បុគ្គលដែរ[83]។

យ៉ាងណាមិញ ច្បាប់ក៏បានបញ្ញត្តិជាក់លាក់ផងដែរថា ការបង្ខំដល់រូបរាងកាយគឺមិនអាចអនុវត្តទៅលើទណ្ឌិតជាអនីតិជនបានឡើយ[84] ដោយសារតែអនីតិជនជាជនដែលស្ថិតក្នុងវ័យមួយកំពុងមានការលូតលាស់នៅឡើយ ប្រសិនបើមានការអនុវត្តបង្ខំដល់រូបកាយ នោះនឹងបង្កឲ្យមានការប៉ះពាល់ដល់ការវិវឌ្ឍរបស់ពួកគេជាមិនខានឬអាចធ្វើឱ្យមាននូវស្លាកស្នាមអាក្រក់ នៅក្នុងអារម្មណ៍ដែលអាចនឹងជះឥទ្ធិពលដល់ការរស់ និងការវិវត្តរបស់ពួកគេនៅថ្ងៃអនាគតថែមទៀតផង។

### ៣.២ ការអនុវត្តទោសក្នុងពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា

ការដាក់ពន្ធនាគារចំពោះអនីតិជនដែលរកឃើញថាល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ត្រូវតែជាវិធានការចុងក្រោយបង្អស់ដែលត្រូវបានប្រើតែក្នុងករណីពិសេសតែប៉ុណ្ណោះ។ ក្នុងនេះពន្ធនាគារ គឺសំដៅទៅដល់ការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ។ គោលបំណងចម្បងនៃការអនុវត្តទោសចំពោះអនីតិជនក្នុងពន្ធនាគារគឺ ដើម្បីធ្វើការអប់រំ កែប្រែ បណ្តុះបណ្តាលវិជ្ជាជីវៈ និងស្តារនីតិសម្បទាដល់ទណ្ឌិតដែលជាអនីតិជននោះតែប៉ុណ្ណោះ ហើយក្រោយពីការអនុវត្តទោសត្រូវបានបញ្ចប់រួច អនីតិជននោះចូលមករួមរស់នៅក្នុងសង្គមដូចដើមវិញ។ គេសង្កេតឃើញថា ការអនុវត្តចំពោះអនីតិជន គឺមានការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ (៣.២.១) និងការឃុំខ្លួនអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា (៣.២.២) ដោយយោងទៅតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

---

[82] *សូមមើល* នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៥១

[83] *សូមមើល* នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ ទំព័រ ៤៤៨

[84] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ, មាត្រា ៥៣១ ឆ្នាំ២០០៧

### ៣.២.១ ការឃុំឃាំងអនីតិជនក្នុងពន្ធនាគារ

ការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ គឺជានីតិវិធីមួយដែលធ្វើការឃុំអនីតិជនដែលជាជនជាប់ឃុំក្នុងបន្ទប់ឃុំឃាំង និងត្រូវបែងចែកទៅតាមប្រភេទនៃជនជាប់ឃុំនីមួយៗផងដែរ។ ជនជាប់ឃុំ គឺសំដៅដល់ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំនៅក្នុងពន្ធនាគារតាមលិខិតឃុំខ្លួនដែលចេញដោយអាជ្ញាធរតុលាការ[85]។ ជនជាប់ឃុំជាអនីតិជនត្រូវបំបែកពីជនជាប់ឃុំដែលជានីតិជន ហើយជនជាប់ឃុំដែលជាជនត្រូវចោទ ជនជាប់ចោទ និងពិរុទ្ធជនត្រូវដាក់បំបែកពីជនជាប់ឃុំជាទណ្ឌិត[86]។ ក្រៅពីនេះជនជាប់ឃុំជាស្ត្រី ត្រូវដាក់បំបែកជាជនជាប់ឃុំជាបុរស។ ចំពោះជនជាប់ឃុំដែលមានជំងឺឆ្លងត្រូវដាក់បំបែកដាច់ដោយឡែកពីជនជាប់ឃុំដទៃទៀតផងដែរ។

យោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ នៃព្រះរាជាណាចក្រកម្ពុជាបានចែងថា ក្នុងករណីដែលតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចជា៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។ ឧទាហរណ៍ក្នុងករណីបទឃាតកម្មធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ប៉ុន្តែចំពោះជនល្មើសជាអនីតិជនដែលមានអាយុចន្លោះពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ការដាក់ទោសពន្ធនាគារគឺត្រូវបន្ថយពាក់កណ្តាលមកត្រឹមតែ ៥ ឆ្នាំ ទៅ ៧ ឆ្នាំកន្លះវិញ។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺដាក់ទោសពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។

៣. ចំពោះអប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ចំណែកឯការត្រួតពិនិត្យការអនុវត្តទោសក្នុងពន្ធនាគារ ជាភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធនាគារចំណុះឲ្យក្រសួងមហាផ្ទៃ និងពន្ធនាគាររាជធានី-ខេត្ត។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចពន្ធនាគារស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ យន្តការថ្នាក់ជាតិត្រូវបាន

[85] *សូមមើល* ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៤ ចំណុច ៣ ឆ្នាំ ២០១១

[86] *សូមមើល* ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ២៦ ឆ្នាំ ២០១១

អនុញ្ញាតឲ្យចូលទៅទស្សនៈកិច្ចពន្ធនាគារផងដែរ ដើម្បីធ្វើការពិនិត្យលើលក្ខខណ្ឌនៃការឃុំខ្លួន និងការប្រព្រឹត្តចំពោះជនជាប់ឃុំ និងប្រើអនុសាសន៍បន្ថែមដើម្បីកែលម្អការប្រព្រឹត្តទៅរបស់ពន្ធនាគារឲ្យមានភាពល្អប្រសើរ[87]។ ការដាក់ពន្ធនាគារ គឺត្រូវតែស្របទៅតាមច្បាប់ស្តីពីពន្ធនាគារ និងប្រកាសស្តីពីការគ្រប់គ្រងពន្ធនាគារ។ ក្រសួងមហាផ្ទៃជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងពន្ធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានអគ្គនាយកដ្ឋានពន្ធនាគារជាសេនាធិការក្នុងការគ្រប់គ្រងពន្ធនាគារ[88]។

ពន្ធនាគារត្រូវគ្រប់គ្រងដោយប្រធានពន្ធនាគារមួយរូប ហើយមានអនុប្រធានពន្ធនាគារយ៉ាងតិចមួយរូបដែលត្រូវតែតែងតាំងដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ។ ពន្ធនាគារនីមួយៗ ត្រូវមានអ្នកផ្តល់ការថែទាំសុខភាពមួយរូប និងមន្រ្តីអនុរក្សពន្ធនាគារជាច្រើនរូបផ្សេងទៀត ដែលមានតួនាទី និងភារកិច្ចក្នុងការថែរក្សា ព្រមទាំងជំរុញឲ្យការងារពន្ធនាគារដំណើរការប្រកបដោយប្រសិទ្ធភាព[89]។ ប្រធានពន្ធនាគារជាអ្នកទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងពន្ធនាគារតាមនីតិវិធី និងបទបញ្ជាផ្ទៃក្នុង ដែលបង្កើតដោយរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ហើយមន្រ្តីពន្ធនាគារអាចធ្វើការឆែកឆេរជនជាប់ឃុំ និងកន្លែងនានាក្នុងពន្ធនាគារដើម្បីធានាសុខសន្តិសុខ និងសុវត្ថិភាពរបស់ពន្ធនាគារ។ ក្នុងករណីដែលជនជាប់ឃុំបដិសេធមិនឲ្យមន្រ្តីពន្ធនាគារឆែកឆេរ ត្រូវចាត់ទុកជាការល្មើសនឹងបទបញ្ជាផ្ទៃក្នុងពន្ធនាគារ[90]។

### ៣.២.២ ការឃុំខ្លួនអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបង្ហាញថា ការគ្រប់គ្រងអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបានចែកជាបីផ្នែកដាច់ដោយឡែកពីគ្នាដែលមានដូចជា[91]៖

ក. ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន

ខ. ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនិតិសម្បទា

គ. ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

ម្យ៉ាងវិញទៀតក្រៅពីការបែងចែកផ្នែកសម្រាប់គ្រប់គ្រងអនីតិជននេះហើយក៏ត្រូវរក្សាអនីតិជន នៅដោយឡែកពីនីតិជន ពោលគឺត្រូវដាក់នៅក្នុងអគារដាច់ដោយឡែកទៅតាម ភេទផ្សេងៗគ្នា តាមប្រភេទ និងស្ថានភាពនៃ

---

[87] *សូមមើល* ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៥៤ ឆ្នាំ ២០១១

[88] *សូមមើល* ច្បាប់ស្តីពីពន្ធនាគារ, មាត្រា ៥-៦ ឆ្នាំ ២០១១

[89] *សូមមើល* នីតិព្រហ្មទណ្ឌទូទៅ, សាស្រ្តាចារ្យ រុន ពុណ្ណារិទ្ធ ទំព័រ ៤៣៤

[90] *សូមមើល* ច្បាប់ស្តីពីពន្ធនាគារ, ឆ្នាំ ២០១១

[91] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៧៧ ឆ្នាំ២០១៦

បទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់អនីតិជននោះ។ ចំពោះអនីតិជនភេទស្រី ត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា។ ក្នុងករណីអនីតិជនមានជំងឺឆ្លង ត្រូវនៅក្នុងអគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដោយឡែកពីអនីតិជនផ្សេងៗជាកំហិត។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូល ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាននឹងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជនវិញ។ ចំពោះបែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[92]។

មន្ត្រីមណ្ឌលឃុំនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្ដុះបណ្ដាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ហើយមណ្ឌលឃុំនីតិសម្បទានេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ចំណែកឯការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលឃុំនីតិសម្បទាត្រូវកំណត់ដោយអនុក្រឹត្យ។

ចំណែកឯការចុះឈ្មោះអនីតិជនក្នុងបញ្ជី គ្រប់មណ្ឌលឃុំនីតិសម្បទាត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាអោយមានសុវត្ថិភាព។ បញ្ជី និងនីតិវិធីដោយឡែកនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

អនីតិជនដែលជាប់ឃុំនៅក្នុងមណ្ឌលឃុំនីតិសម្បទាទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ[93]៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ថាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ទណ្ឌកម្មរួមមាន ការដាក់អោយនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្នុងគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់នីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច

[92] *សូមមើល* ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ៨២ ឆ្នាំ២០១៦

[93] *សូមមើល* ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, មាត្រា ៨០ ឆ្នាំ២០១៦

- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែង ទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្តល់ដំណឹងដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល សម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ និងមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងការឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន។

➢ **ការធ្វើអធិការកិច្ចមណ្ឌលឃុំនីតិសម្បទា**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលឃុំនីតិសម្បទាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថា លក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួន ត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន។ យន្តការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលឃុំនីតិសម្បទានានាបានគ្រប់ពេល។ លើសពីនេះទៅទៀត អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលឃុំនីតិសម្បទាទាំងអស់ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចជា[94]៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដែលស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ អាយុ របស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡាកម្សាន្ត និងសម្រាកពីការងារ
- សុខភាពផ្លូវកាយ សុខភាពផ្លូវចិត្តឱ្យបានសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យដែលត្រូវការបញ្ចូលទៅក្នុងសំណុំរឿងអនិតិជនជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពីការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត

[94] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៨១ ឆ្នាំ២០១៦

- សេវាផ្សេងៗទៀតដែលលើកស្ទួយសុខភាព និងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានការទទួលខុសត្រូវ អោយមានអាកប្បកិរិយា និងជំនាញ ដែលនឹងជួយអនីតិជនមានការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋម្នាក់ក្នុងសង្គម និងជួយសង្គមឲ្យបានល្អប្រសើរត្រឡប់មកវិញបន្ទាប់ពីមានការដោះលែងរួចហើយ។

## ៣.៣ ការផ្តល់ ការមាននីតិសម្បទាឡើងវិញ និងការដោះលែងដោយមានលក្ខខណ្ឌ

បន្ទាប់ពីអនីតិជនបានទទួលរងទោសក្នុងមណ្ឌលឃុំនីតិសម្បទា ឬបានអនុវត្តទោសរួចចប់សព្វគ្រប់ហើយនោះ ឬពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឲ្យមានលក្ខខណ្ឌនៃការផ្តល់ ការស្តារនីតិសម្បទាឡើងវិញ (៣.៣.១) និងការដោះលែងដោយមានលក្ខខណ្ឌ (៣.៣.២) ចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស។

### ៣.៣.១ ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

បន្ទាប់ពីអនីតិជនបានអនុវត្តទោសរួចចប់សព្វគ្រប់ហើយ ឬនៅពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឲ្យមានការផ្តល់ និងការមាននីតិសម្បទាឡើងវិញចំពោះអនីតិជនដែលអាចមានលក្ខខណ្ឌជា ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ និងការមាននីតិសម្បទាឡើងវិញតាមច្បាប់កំណត់។

- **ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ**

ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឱ្យ ឬមិនត្រូវបានផ្តល់ឱ្យ ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។ យោងតាមមាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៦ បានចែងថា ពាក្យសុំឲ្យមាននីតិសម្បទាឡើងវិញ អាចដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបានដោយទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន ឬធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន។ លក្ខខណ្ឌលើរយៈពេលទាក់ទងទៅនឹងពាក្យសុំឲ្យមានការសុំផ្តល់នីតិសម្បទាឡើងវិញអាចធ្វើទៅបានលុះត្រាតែផុតរយៈពេលដូចតទៅ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល។ លើសពីនេះទៀតការមិនបង់ប្រាក់ពិន័យ ប្រាក់ពាក់ព័ន្ធនៃនីតិវិធី ឬប្រាក់សំណង និងជំងឺចិត្តមិនមែនជាឧបសគ្គដល់ការឱ្យមាន

នីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតផ្តល់ជូនភស្តុតាងថាខ្លួនស្ថិតនៅភាពអសាធនី[95]។ អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចដែនដី ហើយត្រូចង្អុលបង្ហាញប្រភេទទណ្ឌកម្មដែលខ្លួនបានរង បញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ។ បន្ទាប់ពីទទួលបានពាក្យសុំហើយ ព្រះរាជអាជ្ញាចាប់ផ្តើមធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតជាអនីតិជនធ្លាប់បានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែង។ ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងដែលមានយោបល់ និងសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាប្តឹងទៅសុភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ហើយជូនដំណឹងអំពីការបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសុំ និងមេធាវី។ បន្ទាប់ពីទទួលពាក្យប្តឹងបណ្តឹងពីអគ្គព្រះរាជអាជ្ញា តុលាការត្រូវសម្រេចនៅពេលសម្រាកសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា[96]។ ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុតរយៈពេល២ (ពីរ) ឆ្នាំ បានឡើយ។ ប្រសិនបើពាក្យសុំលើកទីមួយត្រូវតុលាការបដិសេធដោយសារការមិនគ្រប់រយៈពេលដែលមានចែងក្នុងមាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពាក្យសុំអាចធ្វើថ្មីបានចាប់ពីការផុតកំណត់ផុតរយៈពេលនោះ។

➢ **ការមាននីតិសម្បទាឡើងវិញតាមច្បាប់កំណត់**

យោងតាមមាត្រា ៧៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានបញ្ញត្តិថា ការមាននីតិសម្បទាឡើងវិញតាមច្បាប់កំណត់គឺនៅពេលផុតរយៈពេល៖

- ៣ (បី) ឆ្នាំចំពោះបទឧក្រិដ្ឋ
- ១ (មួយ) ឆ្នាំចំពោះបទមជ្ឈិម
- ៣ (បី) ខែចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវបានផុតអាជ្ញាយុកាល។ អនីតិជនដែលទទួលបាននីតិសម្បទាឡើងវិញ ត្រូវបានលុបលាងចោលទណ្ឌកម្មព្រហ្មទណ្ឌទាំងអស់ ហើយត្រូវបានគេលុបចេញពីបញ្ជីថ្កោលទោស។ កំណត់ហេតុ និងសំណុំរឿងឯកសារដទៃទៀតរបស់អនីតិជនត្រូវបានរក្សាជាសម្ងាត់។

---

[95] *សូមមើល* មាត្រា ៥៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[96] *សូមមើល* មាត្រា ៥៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

### ៣.៣.២ ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលឃុំនីតិសម្បទា។ ដើម្បីលើកទឹកចិត្តឲ្យមានការដោះលែងដោយមានលក្ខខណ្ឌនេះយកមកអនុវត្តបាន ច្បាប់បានកំណត់ដោយឲ្យបុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌលឃុំនីតិសម្បទា ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ឬបេសកកម្មទូត ឬកុងស៊ុលបរទេសក្នុងករណីអនីតិជនជាជនបរទេស[97]។ លើសពីនេះទៅទៀត គ្រប់ទណ្ឌិតដែលទទួលរងទោសដាក់ពន្ធនាគារ អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមាននីតិសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ ការដោះលែងដោយមានលក្ខខណ្ឌអាចផ្តល់ទៅឲ្យទណ្ឌិតជាអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលឃុំនីតិសម្បទាដោយ

- ទណ្ឌិតបានបំពេញទោសចំនួនមួយភាគបីនៃទោសរបស់ខ្លួនដែលតុលាការបានផ្តន្ទាទោស ប្រសិនបើទោសតិចជាង ឬស្មើមួយឆ្នាំ
- ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ឬករណីអនីតិជនដែលទាក់ទងទៅនឹងសុខភាពរបស់អនីតិជន។

ការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវផ្តល់ដោយប្រធានតុលាការជាន់ដំបូងនៃកន្លែងឃុំខ្លួន ហើយបន្ទាប់ពីទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងត្រូវបញ្ជូនទៅគណៈកម្មការជាតិនូវពាក្យសុំ សាលក្រម ឬសាលដីកាផ្តន្ទាទោស ជាយថាហេតុ សាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស យោបល់ព្រះរាជអាជ្ញា និងគ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍។ បន្ទាប់មក គណៈកម្មការជាតិត្រូវបញ្ចេញយោបល់របស់ខ្លួនជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុក្នុងរយៈពេលខ្លីបំផុតទៅកាន់ប្រធានតុលាការជាន់ដំបូងភ្លាម។ ប្រធានតុលាការត្រូវសម្រេចដោយមានសំអាងហេតុ ក្រោយពីទទួលបានយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។ រាល់សេចក្តីសម្រេចរបស់ប្រធានតុលាការ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បាន ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយមិនបណ្តឹងតវ៉ានេះអាចឡើងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាសាមីតែប៉ុណ្ណោះ។ នៅពេលប្រធានតុលាការជាន់ដំបូង

[97] *សូមមើល* ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, មាត្រា ៧២ ឆ្នាំ២០១៦

បង្គាប់ឲ្យមានការដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់អំពីការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត ដោយកំណត់រយៈពេលសាកល្បង ដែលមិនអាចលើសពីថេរវេលានៃទោសដែលនៅសល់មិនទាន់ទទួលរងឡើយ។ ផ្ទុយទៅវិញ ក្នុងករណីដែលមានការផ្តន្ទាទោសសារជាថ្មី ឬការមិនគោរពលក្ខខណ្ឌដែលបានកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន ដែលនាំឱ្យទណ្ឌិតត្រូវទទួលទោសដែលនៅសល់។ ប្រសិនបើទណ្ឌិតបានគោរពទៅតាមដីកា ឬមិនបានផ្តន្ទាទោសចំពោះបទល្មើសថ្មីទេ ហើយមិនត្រូវបានដកហូតសេចក្តីសម្រេចក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលនៃការកំណត់នោះ ការដោះលែងនឹងក្លាយជាស្ថាពរ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទ «**ការទទួលខុសត្រូវរបស់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ**» យ៉ាងល្អិតល្អន់រួចមក យើងសង្កេតឃើញថា អនីតិជនមានសិទ្ធិពិសេសការពារធានាដោយច្បាប់ ហើយចំពោះរឿងក្តីលើការទទួលខុសត្រូវរបស់អនីតិជនតែងមានអាទិភាពជានិច្ចក្នុងការយកមកជំនុំជម្រះ។ នៅពេលអនីតិជនបានប្រព្រឹត្តបទល្មើស ពួកគេត្រូវទទួលខុសត្រូវព្រហ្មទណ្ឌលើទង្វើរបស់គេចំពោះមុខច្បាប់ដែលមានលក្ខណៈដូចគ្នាទៅនឹងនីតិជនដែរ។ ប៉ុន្តែដោយសំអាងហេតុថា អនីតិជនគឺជាជនដែលស្ថិតនៅក្នុងដំណាក់កាលកំពុងអភិវឌ្ឍន៍ លូតលាស់ទាំងសរីរាង្គ និងផ្នែកខួរក្បាលរបស់អនីតិជននៅមានកម្រិត ដោយមិនទាន់មានលក្ខណៈពេញលេញនៅឡើយ ដែលធ្វើឲ្យអនីតិជនហ៊ានប្រព្រឹត្តបទល្មើសដោយមិនបានគិតពិចារណាទៅលើផលអវិជ្ជមានដែលអាចកើតមានឡើងចំពោះខ្លួន។ ដូចនេះ ទើបតម្រូវឲ្យមានការចាំបាច់ក្នុងការពិចារណាទៅលើចំណុចមួយចំនួនអំពីលទ្ធភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ដែលទាក់ទងទៅនឹង កត្តាអាយុ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែពិនិត្យ និងពិចារណាទៅលើកត្តាទាំងអស់នេះឲ្យបានច្បាស់លាស់ ដើម្បីធ្វើការសន្និដ្ឋានទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន។ លើសពីនេះទៅទៀត យើងអាចសន្មតបានថា នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ច្បាប់បានតម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ចធ្វើការអនុវត្តដាច់ខាតទៅតាមនីតិវិធីរបស់ខ្លួន ដើម្បីស្រាវជ្រាវ និងពិនិត្យអំពីបទល្មើសដែលបានប្រព្រឹត្តដោយអនីតិជន។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺជាឧបករណ៍គតិយុត្តដ៏មានសារៈសំខាន់ ដែលមិនត្រឹមតែផ្តល់ការយល់ដឹង និងការអនុវត្តឲ្យកាន់តែប្រសើរឡើងរបស់មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ក្នុងកិច្ចការពារ និងការគ្រប់គ្រងវិស័យយុត្តិធម៌ព្រហ្មទណ្ឌរបស់អនីតិជនប៉ុណ្ណោះទេ វាក៏បានគិតគូរពីវិធានការទាំងឡាយដែលទាក់ទងទៅនឹងការស្ទើនីតិសម្បទា និងសមាហរណកម្មពួកគេទៅក្នុងសហគមន៍វិញ ក្នុងគោលបំណងប្រែក្លាយពួកគេទៅជាពលរដ្ឋល្អក្នុងសង្គម។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានផ្តល់អាទិភាព និងមានការការពារចំពោះអនីតិជនរួមមាន សិទ្ធិជាមូលដ្ឋានរបស់អនីតិជនត្រូវបានធានានៅគ្រប់ដំណាក់កាលនៃនីតិវិធី តាំងពីដំណាក់កាលនគរបាលយុត្តិធម៌រហូតដល់ដំណាក់ការជំនុំជម្រះ ដែលសិទ្ធិសំខាន់ៗនោះមានដូចជា នីតិវិធីកុមារមេត្រី ការសន្មត់ថាគ្មានទោសដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការ និងសិទ្ធិមានមេធាវីក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ខ្លួន អមជាមួយភ្នាក់ងារសង្គមកិច្ច ព្រមទាំងការចូលរួមរបស់អ្នកតំណាងកំណត់ដោយច្បាប់ លើកលែងតែការចូលរួមរបស់ពួកគេប៉ះពាល់ដល់ឧត្តមប្រយោជន៍របស់អនីតិជន ។ លើសពីនេះទៅទៀត ច្បាប់នេះបានគិតគូរអំពីឧត្តមប្រយោជន៍របស់អ

នីតិជនឲ្យមានស្របតាមអនុសញ្ញាជាសកលស្តីពីសិទ្ធិកុមារ និងលិខិតគុបករណ៍អន្តរជាតិនានា ដែលវិធានការទាំងនោះអាចជា ការពិន័យជាប្រាក់ ទណ្ឌកម្មព្រហ្មទណ្ឌ និងវិធានការបង្វែរ។ វិធានការបង្វែរ គឺជាវិធានការដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលតម្រូវឲ្យព្រះរាជអាជ្ញា ចៅក្រម ត្រូវពិចារណាទៅលើការបង្វែរអនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះ ចេញពីតុលាការ ប្រគល់អនីតិជនទៅឲ្យអ្នកមានអំណាចមេបា ឬអ្នកដែលមានសម្បទាក្នុងការគ្រប់គ្រងអនីតិជន ដើម្បីឲ្យអនីតិជនអាចស្តារខ្លួន ទទួលកំហុស និងចៀសវាសពីការជាប់ឈ្មោះមិនល្អ និងជៀសវាងការមានប្រវត្តិជាប់ទោសក្នុងបញ្ជីថ្កោលទោស។ ចំណែកឯទណ្ឌកម្មព្រហ្មទណ្ឌ គឺត្រូវជាវិធានការចុងក្រោយដែលអាចយកមកអនុវត្តចំពោះអនីតិជន។

នីតិវិធីដែលអនុវត្តទោសព្រហ្មទណ្ឌចំពោះអនីតិជនត្រូវបានបែងចែកជាដំណាក់កាលសំខាន់ៗដូចជា ដំណាក់កាលនគរបាល ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ លើសពីនេះទៅទៀត ចំពោះនីតិវិធីអនុវត្តលើអនីតិជនត្រូវមានលក្ខណៈជា នីតិវិធីកុមារមេត្រី ហើយចំពោះការអនុវត្តទោសរបស់អនីតិជន គឺមានលក្ខណៈពិសេសខុសពីនីតិជនដោយនៅពេលដែលតុលាការប្រកាសទោសឲ្យជាប់ពន្ធនាគារទោសរបស់អនីតិជនត្រូវស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុតខុសពីនីតិជន ឬត្រូវតែកម្រិតមកត្រឹមពាក់កណ្តាលនៃទោសដែលត្រូវអនុវត្តចំពោះនីតិជន។ មិនតែប៉ុណ្ណោះ ក្នុងករណីដែលអនីតិជនបានដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌហើយ យន្តការផ្សេងទៀតក៏អាចយកមកអនុវត្តដើម្បីជាឧត្តមប្រយោជន៍ចំពោះអនីតិជននោះបានដូចជា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការដោះលែងឲ្យនៅក្រៅឃុំដោយមានការដកហូតនូវសិទ្ធិសេរីភាពមួយចំនួនតូច ដែលត្រូវបានបង្គាប់បញ្ជាដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងដើម្បីការពារនូវប្រយោជន៍របស់អនីតិជន បង្ការកុំឲ្យមានបទល្មើសថ្មីកើតឡើងទៀត និងការពារដល់ផលប្រយោជន៍សង្គមទាំងមូល។ លើសពីនេះទៅទៀត យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងករណីដែលមានមណ្ឌលឃុំនីតិសម្បទា អនីតិជនមិនត្រូវបានដាក់នៅក្នុងពន្ធនាគារនោះទេ ពោលត្រូវយកអនីតិជនទៅរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាដែលមានលក្ខណៈដាច់ដោយឡែកពីនីតិជន ហើយស្ថិតនៅក្នុងអគារដែលមានលក្ខណៈដោយឡែកទៅតាម ភេទ ប្រភេទ ស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជនដើម្បីជាឧត្តមប្រយោជន៍ដល់អនីតិជនក្នុងការចូលមករួមរស់នៅក្នុងសង្គមវិញបាន។

ចំណុចទាំងអស់នេះបង្ហាញពីការយកចិត្តទុកដាក់របស់ប្រព័ន្ធតុលាការចំពោះ សិទ្ធិនិងការលូតលាស់របស់អនីតិជន ដើម្បីផ្តល់ឱកាសឲ្យអនីតិជនម្តងទៀតក្នុងការកសាងខ្លួនជាពលរដ្ឋល្អ កូនល្អ សិស្សល្អ មិត្តល្អ និងធនធានមនុស្សយ៉ាងសំខាន់នៅក្នុងសង្គម។

# អនុសាសន៍

យើងសង្កេតឃើញថា ទោះបីជាតុលាការបានធ្វើការផ្តន្ទាទោសអនីតិជនដោយយោងទៅតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ជាពិសេសគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដើម្បីការពារនូវឧត្តមប្រយោជន៍របស់អនីតិជនយ៉ាងណាក៏ដោយ ក៏ប៉ុន្តែការអនុវត្តទាំងអស់នោះគឺនៅតែមានភាពខ្វះចន្លោះ ឬកង្វះខាតមួយចំនួនផងដែរ។ កង្វះខាតទាំងអស់នោះរួមមាន កត្តាសម្ភារៈ កត្តាធនធានមនុស្ស និងយន្តការក្នុងការអនុវត្តឲ្យមានប្រសិទ្ធភាពទៅលើអនីតិជនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនៅមានកម្រិត។ យើងសង្កេតឃើញថានៅក្នុងនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមន្ត្រីនគរបាលយុត្តិធម៌តែងតែធ្វើការចាប់ខ្លួនអនីតិជន ដោយមិនបានពិនិត្យទៅលើអាយុរបស់អនីតិជន ហើយសកម្មភាពនៃការស៊ើបអង្កេតនេះ គឺតែងតែមិនស្ថិតនៅក្រោមនីតិវិធីកុមារមេត្រីដែលបណ្តាលឲ្យមានមោឃភាពនៃនីតិវិធី។ លើសពីនេះទៅទៀត ដោយយើងសង្កេតឃើញថា យោងទៅតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺតម្រូវឲ្យស្ថាប័នមានសមត្ថកិច្ចធ្វើការអនុវត្តទៅតាមនីតិវិធីដែលបានចែងឱ្យបានហ្មត់ចត់ ដើម្បីកំណត់ឲ្យច្បាស់លាស់នូវអាទិភាពនៃបទល្មើសព្រហ្មទណ្ឌ ដែលបានប្រព្រឹត្តដោយអនីតិជន ដែលនីតិវិធីនេះអាចធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ពេលវេលា និងការសិក្សារបស់អនីតិជនជាប់សង្ស័យឬមិនបានប្រព្រឹត្តបទល្មើស។ ម្យ៉ាងវិញទៀត ការអនុវត្តទោសចំពោះអនីតិជន គេសង្កេតឃើញថាមិនទាន់មានភាពត្រឹមត្រូវ ដែលស្របតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនឡើយ ពោលទាក់ទងទៅនឹងវិធានការនៃការឃុំខ្លួនរបស់អនីតិជនឲ្យដាច់ដោយឡែកពីនីតិជននៅតាមពន្ធនាគារ គឺមិនទាន់មានការបែងចែកច្បាស់លាស់នៅឡើយ ដែលសបញ្ជាក់ឲ្យឃើញពីភាពខ្វះចន្លោះ នៃការអនុវត្តន៍របស់ភ្នាក់ងារសមត្ថកិច្ចទៅលើអនីតិជន។ មិនតែប៉ុណ្ណោះ យើងសង្កេតឃើញថា មណ្ឌលយុវនីតិសម្បទាដែលមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងអនីតិជន ផ្តល់នូវការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំចិត្តសាស្ត្រ ការព្យាបាល ការថែទាំ ការការពារអនីតិជន ដើម្បីមានប្រយោជន៍សម្រាប់សង្គមជាតិនោះ មិនទាន់មានការបង្កើតឡើងនៅតាមរាជធានី-ខេត្តបានគ្រប់គ្រាន់នៅឡើយទេ ដោយមណ្ឌលយុវនីតិសម្បទានេះ គឺទើបបានបញ្ចប់ការសាងសង់រួចក្នុងខែ ឧសភា ឆ្នាំ ២០២១ ដែលមានតែមួយគត់នៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលអាចដែលមានគម្រោងក្នុងការដាក់អនីតិជនល្មើសច្បាប់ចំនួន ៥០០ (ប្រាំរយ) នាក់ និងអាចមានលទ្ធភាពក្នុងការផ្ទុកសរុបចំនួន ២០០០ (ពីរពាន់) នាក់តែប៉ុណ្ណោះ[98]។ ប៉ុន្តែ បើយើងសង្កេតមើលទៅ ចំនួនអនីតិជននៅតាមបណ្តាលរាជធានី-

[98] *សូមមើល* «ឯកឧត្តមរដ្ឋមន្ត្រី វង សូត អញ្ជើញចុះពិនិត្យ សមិទ្ធិផលចំនួន ៣ នៅឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល», ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២៦ ឧសភា ២០២១

ខេត្ត ដែលត្រូវបានផ្តន្ទាទោស គឺមានចំនួនច្រើនលើសពីចំនួនដែលអាចផ្ទុកបាននៅក្នុងមណ្ឌលឃុំនីតិសម្បទា ដែលជាហេតុនាំឲ្យអនីតិជនស្ថិតនៅក្នុងពន្ធនាគារជាមួយនឹងនីតិជនដដែល។

បញ្ហាដែលបានរៀបរាប់ខាងលើនេះ គួរតែមានការដោះស្រាយយ៉ាងល្អប្រសើរ និងហ្មត់ចត់ពីសំណាក់រាជរដ្ឋាភិបាលឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ដើម្បីធ្វើការការពារដល់ឧត្តមប្រយោជន៍របស់អនីតិជន។ បញ្ហាបង្ក្រាប ឬបង្អើតឲ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយអនីតិជននោះ គប្បីមានវិធានការឲ្យបានច្បាស់លាស់ និងជាក់លាក់បំផុតដែលតម្រូវឱ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធមានដូចជា រាជរដ្ឋាភិបាល ស្ថាប័នមានសមត្ថកិច្ច និងប្រជាពលរដ្ឋផ្ទាល់តែម្តង។

ជាដំបូង ទាក់ទងទៅនឹងកត្តាប្រជាពលរដ្ឋដែលផ្តោតសំខាន់ទៅលើ កត្តាគ្រួសារ គឺជាកត្តាមួយដ៏សំខាន់បំផុតក្នុងការទប់ស្កាត់អនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ជាការពិត អនីតិជន ជាទំពាំងស្នងឬស្សី កាលណាឫស្សីល្អ នោះទំពាំងក៏ល្អដែរ។ អនីតិជនងាយទទួលឥទ្ធិពលពីមជ្ឈដ្ឋានជុំវិញខ្លួនណាស់ពីព្រោះការយល់ដឹងរបស់អនីតិជននៅមានកម្រិត ដូច្នេះហើយទើបអនីតិជនត្រូវការការយកចិត្តទុកដាក់ ទទួលបានការអប់រំ ទទួលបានការទំនុកបម្រុងគ្រប់គ្រាន់ ដើម្បីសុខុមាលភាពកុមារដែលសមប្រពៃមួយ។ កាលណាអនីតិជន បានការយកចិត្តទុកដាក់ពីឪពុកម្តាយ គ្រូបង្រៀន មិត្តភក្តិ និងសង្គម នោះអនីតិជនមិនអាចយកខ្លួនទៅប្រព្រឹត្តបទល្មើសដែលសង្គមស្អប់ខ្ពើមនោះទេ។ សមាជិកគ្រួសារ ឬឪពុកម្តាយ អាណាព្យាបាល គួរតែបង្ហាត់បង្រៀន និងពន្យល់អនីតិជនអំពីបញ្ហាផ្លូវច្បាប់មួយចំនួនដើម្បីឱ្យពួកគេមានការយល់ដឹងអំពីសកម្មភាពដែលខុស ត្រូវ ល្អ អាក្រក់ ឬសកម្មភាពណាមួយដែលច្បាប់បានហាមឃាត់ដែលអាចឈានទៅដល់ទណ្ឌកម្មខាងផ្នែកព្រហ្មទណ្ឌទៅដល់អនីតិជន។

ចំពោះស្ថាប័នពាក់ព័ន្ធ ជាពិសេសស្ថាប័នតុលាការដែលជាស្ថាប័នមួយក្នុងការកំណត់នូវបទល្មើស ពិរុទ្ធភាពនៃបទល្មើស តាមនីតិវិធីដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌ ព្រមទាំងច្បាប់ស្តីពីយុត្តិធម៌អនីតិជន គួរតែធ្វើការអនុវត្តន៍ឲ្យបានត្រឹមត្រូវ ស្របតាមការអនុលោមនៃច្បាប់អោយបានល្អប្រសើរនិងពេញលេញ។ យើងសង្កេតឃើញថាការអនុវត្តចំពោះអនីតិជន ពុំបានអនុវត្តន៍ត្រឹមត្រូវ និងពេញលេញទៅតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជននៅឡើងទេ ដែលជាហេតុនាំឲ្យច្បាប់នេះពុំសូវមានប្រសិទ្ធភាព។ ការអនុវត្តទាំងនោះគប្បីត្រូវតែជំនុំជម្រះអនីតិជនជាអសាធារណៈ មាននីតិវិធីនៃការបង្វែរឲ្យបានត្រឹមត្រូវ និងប្រកបដោយនីតិវិធីកុមារមេត្រី ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន។

ជាចុងក្រោយ រាជរដ្ឋាភិបាលដែលជានីតិប្រតិបត្តិ និងជាស្ថាប័នមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងដឹកនាំប្រទេសជាតិ គប្បីស្វែងរកដំណោះស្រាយ និងអនុវត្តឲ្យមានប្រសិទ្ធភាពចំពោះអនីតិជន។ រាជរដ្ឋាភិបាល គួរធ្វើការ

ផ្សព្វផ្សាយច្បាប់ ដែលពាក់ព័ន្ធទៅនឹងអនីតិជនឲ្យបានទូលំទូលាយទៅដល់គ្រប់មជ្ឈដ្ឋានទាំងអស់ ទាំងអាជ្ញាធរ អង្គការក្នុងស្រុកនានា និងប្រជាពលរដ្ឋ ដើម្បីឱ្យមានការយល់ដឹង។ ការផ្សព្វផ្សាយអំពីបញ្ហាផ្លូវច្បាប់ទាំងអស់នោះគួរស្ថិតនៅក្នុងទម្រង់ កាសែត ទស្សនាវដ្តី ទូរទស្សន៍ បណ្តាញសង្គម ព្រមទាំងសកម្មភាពយុវជនស្ម័គ្រចិត្តនៅតាមតំបន់ដាច់ស្រយាលដើម្បីឱ្យប្រជាជនធ្វើការយល់ដឹងអំពីច្បាប់ និងទប់ស្កាត់នូវការកើតឡើងបទល្មើស។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលគួរមានកម្មវិធីអប់រំអំពីសិទ្ធិរបស់កុមារក្នុងប្រព័ន្ធអប់រំ ដើម្បីឲ្យពួកគេមានការយល់ដឹងអំពីសិទ្ធិ និងកម្រិតនៃបទល្មើស ដែលអនីតិជនអាចនឹងទទួល ក្នុងករណីដែលពួកគេបានប្រព្រឹត្តនូវកំហុសព្រហ្មទណ្ឌ។ ដូច្នេះពួកគេនឹងមានការយល់ដឹង គេចចេញពីការប្រើប្រាស់សិទ្ធិហួសដែនកំណត់ និងចៀសវាងការប្រព្រឹត្តបទល្មើសដែលនាំឲ្យមានព្យសនកម្មដល់ខ្លួនឯង និងសង្គម។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាល គប្បីធ្វើការពង្រឹងសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ឲ្យធ្វើការអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទៅតាមការកំណត់នៃច្បាប់ ជាពិសេសនីតិវិធីនៃការឃាត់ខ្លួន ការចាប់ខ្លួន ការឃុំខ្លួន ការសួរចម្លើយ ដែលត្រូវស្របទៅតាមនីតិវិធីកុមារមេត្រី។ លើសពីនេះទៅទៀត រាជរដ្ឋាភិបាលគប្បីជំរុញឲ្យមានការបង្កើតមណ្ឌលឃុំនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត ឲ្យបានគ្រប់គ្រាន់ និងឆាប់រហ័សបំផុតតាមដែលខ្លួនអាចធ្វើទៅបាន ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលគួរតែធ្វើការពង្រឹងវិន័យនៅក្នុងពន្ធនាគារ ដោយណែនាំមន្ត្រីពន្ធនាគារនៅក្នុងតំបន់សមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ចំពោះការដាក់ជនជាប់ចោទដែលជាអនីតិជនដាច់ដោយឡែកពីនីតិជន ដោយមានការយកចិត្តទុកដាក់បំផុត និងស្របតាមនីតិវិធីកុមារមេត្រី។ ការអនុវត្តនីតិវិធីនៅគ្រប់ដំណាក់កាល ត្រូវប្រាកដថានីតិវិធីដែលប្រព្រឹត្តទៅលើអនីតិជននោះ ត្រូវតែមានលក្ខណៈជានីតិវិធីកុមារមេត្រី ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន។

ដូច្នេះ ដើម្បីធ្វើការកាត់បន្ថយបទល្មើស បង្កើននូវសណ្តាប់ធ្នាប់ សុវត្ថិភាពនៅក្នុងសង្គម ព្រមទាំងបង្កើតឲ្យមានប្រសិទ្ធភាពនៃការអនុវត្តច្បាប់ទូទាំងប្រទេស គប្បីត្រូវតែមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ស្ថាប័នពាក់ព័ន្ធ និងរាជរដ្ឋាភិបាលឲ្យបានខ្ជាប់ខ្ជួន។ កាលណាអនីតិជន បានការយកចិត្តទុកដាក់ពីឪពុកម្តាយ គ្រូបង្រៀន មិត្តភក្តិ និងសង្គម នោះអនីតិជននឹងក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ នៅក្នុងសង្គម ហើយមិនអាចយកខ្លួនទៅប្រព្រឹត្តបទល្មើសដែលសង្គមស្អប់ខ្ពើមនោះទេ។

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រកាសឲ្យប្រើ ក្រមព្រហ្មទណ្ឌ។

៣. ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤. ព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ប្រកាសឲ្យប្រើ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

៥. ព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ប្រកាសឲ្យប្រើ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

៦. ព្រះរាជក្រមលេខ នស/រកម/០៥០០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ប្រកាសឲ្យប្រើ ច្បាប់ស្តីពីជលផល។

៧. ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ប្រកាសឲ្យប្រើ ច្បាប់ស្តីពីពន្ធនាគារ

៨. អនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន។

៩. សារាចរលេខ០១គយ.សរ/១៤ ស្តីពីការអនុវត្តបទប្បញ្ញត្តិដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤

១០. អនុសញ្ញាស្តីពី សិទ្ធិកុមារ អនុម័តដោយអង្គការសហប្រជាជាតិ ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ១៩៨៩។

១១. អនុសញ្ញាស្តីពី សិទ្ធិកុមារ និងពិធីសារបន្ថែម, បោះពុម្ពដោយមូលនីធិសហប្រជាជាតិដើម្បីកុមារ (យូនីសេហ្វ) និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, ខែមិថុនា ឆ្នាំ២០០៩។


## ខ. ឯកសារជាសៀវភៅ និងអត្ថបទផ្សេងៗ


១. លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត**, *នីតិវិធីព្រហ្មទណ្ឌទណ្ឌ*, ឆ្នាំ២០១៣-២០១៤។

២. លោកសាស្ត្រាចារ្យ **ហ៊ី សោភា**, *នីតិព្រហ្មទណ្ឌទូទៅ។*

៣. លោកសាស្ត្រាចារ្យ **កៅ សីហា**, *ទោសព្រហ្មទណ្ឌ*, ឆ្នាំ ២០១១។

៤. លោក **គឹម ចាន់ណា**, *ចិត្តវិទ្យាវ័យជំទង់*, បោះពុម្ពលើកទី២, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០។

៥. គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិរដ្ឋប្បវេណី*, បោះផ្សាយដោយ ទីស្ដីការគណៈរដ្ឋមន្ត្រី, បោះពុម្ពលើកទី១, ឆ្នាំ២០០៧។

៦. «ឯកឧត្តមរដ្ឋមន្ត្រី វង សូត អញ្ជើញចុះពិនិត្យ សមិទ្ធិផលចំនួន ៣ នៅឃុំបារគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល», ក្រសួងសង្គមកិច្ច អតតិតយុទ្ធជន និងយុវនីតិសម្បទា, ២៦ ឧសភា ២០២១។

៧. រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *មេរៀននីតិវិធីព្រហ្មទណ្ឌ*, ឆ្នាំ២០០៨។

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត រាជធានី

សំណុំរឿងព្រហ្មទណ្ឌលេខ............

ចុះថ្ងៃទី..........................................

សំណុំរឿងស៊ើបសួរលេខ...................

ចុះថ្ងៃទី........................................

លេខ[1]..........................................

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

យើង........................................ចៅក្រមស៊ើបសួរនៃសាលាដំបូង...........................អមដោយ លោក/លោកស្រី..............................................ជាក្រឡាបញ្ជី។

- បានឃើញមាត្រា២០៣ ដល់មាត្រា២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ............ចុះថ្ងៃទី........ខែ.........ឆ្នាំ............ ដែលបានបើកការស៊ើបសួរលើ

ឈ្មោះ................................ឈ្មោះហៅក្រៅ.......................ភេទ........ថ្ងៃខែឆ្នាំកំណើត........................

សញ្ជាតិ...................មុខរបរ.........................មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ.....................

កំរិតវប្បធម៌................................ទីកន្លែងកំណើតនៅភូមិ.............................ឃុំ/សង្កាត់......................

ស្រុក/ខណ្ឌ...........................ខេត្ត/រាជធានី...................................។

ទីលំនៅផ្ទះលេខ.......................ផ្លូវលេខ.................ភូមិ.........................ឃុំ/សង្កាត់.......................

ស្រុក/ខណ្ឌ......................រាជធានី/ខេត្ត................។

ឪពុកឈ្មោះ.......................................រ☐ ស☐ ម្តាយឈ្មោះ......................................រ☐ ស☐

ប្តី/ប្រពន្ធឈ្មោះ...............................រ☐ ស☐ មានកូន.......នាក់ ឬនៅលីវ☐ នីតិជន☐ អនីតិជន☐។

មុខរបរ.............................................

[1] លេខរបស់ដីកាសម្រេច

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ..............................................................................។
ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ.....................................តាមមាត្រា...............................
នៃក្រមព្រហ្មទណ្ឌ/ច្បាប់...............................................................................................។

ប្រព្រឹត្តនៅផ្ទះលេខ...............................ផ្លូវលេខ...............ភូមិ..........................ឃុំ/សង្កាត់..................
ស្រុក/ខណ្ឌ...................................ខេត្ត/រាជធានី.........................................................................
កាលពីថ្ងៃទី.................ខែ.................ឆ្នាំ.............។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង
បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១ ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ ..........................ត្រូវចោទពីបទ..............................
(បញ្ចូលបទល្មើសដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ............)

២. ប្រព្រឹត្តិនៅ..................................................................................................................
(សង្ខេបអង្គហេតុនៃរឿង)

៣. តំណាងអយ្យការ បានស្នើឲ្យឃុំខ្លួន□ មិនឲ្យឃុំខ្លួន□ បណ្ដោះអាសន្នលើជនត្រូវចោទ ឈ្មោះ.......................................ផ្អែកលើសំអាងហេតុដូចតទៅ..........................................
.........................................................................................................................
.........................................................................................................................
.........................................................................................................................

៤. ជនត្រូវចោទឈ្មោះ .......................................ឬមេធាវីការពារ ស្នើសុំ(កុំឲ្យ)នៅក្រៅឃុំ បណ្ដោះអាសន្ន□ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ□ ដោយសំអាងហេតុផលថា
.........................................................................................................................
.........................................................................................................................
.........................................................................................................................

II. សំអាងហេតុនៃសេចក្តីសម្រេច

៥. ជនត្រូវចោទឈ្មោះ....................................ត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦. (បញ្ចូលនូវការយល់ឃើញឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលលើកឡើងដោយភាគីមាន ដូចជា តំណាងអយ្យការ និងជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ដោយពន្យល់សំអាងហេតុ គាំទ្រទៅនឹងមូលហេតុនៃការឃុំខ្លួន ចំនួនមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា២០៥ នៃក្រម នីតិវិធីព្រហ្មទណ្ឌ)..........................................................................................................

..........................................................................................................................

..........................................................................................................................

(ហេតុផលជាមូលដ្ឋានពីថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន និងមានយោងតាមបញ្ញត្តិច្បាប់)

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងអាចធានាឲ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ..............................ជាបណ្តោះអាសន្នរយៈពេលអតិបរមា............។

ធ្វើនៅ..............ថ្ងៃទី.........ខែ...........ឆ្នាំ.........

**ចៅក្រមស៊ើបសួរ**

**ក្រឡាបញ្ជី**

## លិខិតបញ្ជូន

យើង.................................បានប្រគល់ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ...........
ចុះថ្ងៃទី........ខែ............ឆ្នាំ..........
ដល់ឈ្មោះខាងក្រោម នៅថ្ងៃទី........ខែ......... ឆ្នាំ................

អ្នកប្រគល់

អ្នកទទួល

| តំណាងអយ្យការ | មេធាវីជនត្រូវចោទ | ជនត្រូវចោទ |
|---|---|---|

**សំគាល់៖** *តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា៖*

*ជនត្រូវចោទមានសិទ្ធិប្ដឹងឧទ្ធរណ៍ នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នរបស់ចៅក្រមស៊ើបសួរ ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា២៦៧ និងមាត្រា២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ: ៦២០ ក.ស.ក.ស.ក./២៤

រាជធានីភ្នំពេញ,ថ្ងៃទី២៣ខែ មករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបជូន**

**ឯកឧត្តម លោក ប្រធានសាលាដំបូងរាជធានី ខេត្ត**

**ឯកឧត្តម លោក លោកស្រី ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត**

**កម្មវត្ថុ ៖** ការដាក់ឲ្យប្រើប្រាស់ទម្រង់បែបបទនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូន ឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូងរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ថាកន្លងមកក្រសួងយុត្តិធម៌បានផ្តល់នូវទម្រង់បែបបទនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នប្រើប្រាស់សាកល្បង ឃើញថានៅមានការខ្វះចន្លោះដែលមិនអាចធានាបាននូវការជឿជាក់ពីសំណាក់សាធារណៈជន។ ដូច្នេះក្រសួងយុត្តិធម៌បានបង្កើតទម្រង់បែបបទថ្មីដែលអាចបង្ហាញពីតម្លាភាព និងគណនេយ្យភាពក្នុងការធ្វើសេចក្តីសម្រេច ដែលអាចពង្រឹងនូវការជឿទុកចិត្តរបស់សាធារណៈជនលើប្រព័ន្ធតុលាការ។

ក្រសួងយុត្តិធម៌សូមធ្វើការណែនាំសម្រាប់ការបំពេញតាមចំណុចមួយចំនួន ដែលមាននៅក្នុងទម្រង់បែបបទនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នតាមគំរូថ្មីនេះដូចតទៅ ៖

- នៅផ្នែកខាងដើមនៃទម្រង់បែបបទពុំមានអ្វីផ្លាស់ប្តូរច្រើននោះឡើយ ហើយក៏ពុំមានអ្វីដែលពិបាកយល់ក្នុងការបំពេញនោះទេ។

នៅផ្នែកនេះ: ចៅក្រមស៊ើបសួរត្រូវព្យាយាមសួរព័ត៌មានឲ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ឃុំខ្លួន ឬ មិនឃុំខ្លួន ដូចជាជនត្រូវចោទ ជាអនីតិជន ជាស្ត្រីមានផ្ទៃពោះ ជាស្ត្រីមានកូនតូចៗនៅជាមួយ ដោយគ្មានអ្នកណាផ្សេងទៀតជួយមើលថែរក្សាកូនតូចៗទាំងនោះ ឬ ជនត្រូវចោទ ជាចាស់ជរា។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសវាងបាន មិនគួរគប្បីសម្រេចឃុំខ្លួននោះឡើយ។

ដើម្បីធានាបានករណីខាងលើនេះ នៅក្នុងនីតិវិធីសួរដេញដោលចំពោះមុខគប្បីមានការចូលរួមពីតំណាងអយ្យការ ជនត្រូវចោទ និង ឬ មេធាវីជនត្រូវចោទ ដើម្បីបង្ហាញអំពីការអះអាងរបស់ពួកគេរៀងៗខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដើម្បីគាំទ្រ ឬ ប្រឆាំងនឹងការសម្រេចឃុំខ្លួន។ នៅពេលបញ្ចប់ការសួរដេញដោលនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន ឬ មិនឃុំខ្លួនបណ្តោះអាសន្ន។ ប្រសិនបើសម្រេចថាត្រូវឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដោយប្រើគំរូតាមទម្រង់បែបបទថ្មីនេះ។

ការប្រើនីតិវិធីសួរដេញដោលបែបនេះ អាចឲ្យចៅក្រមស៊ើបសួរទទួលបាននូវអំណះអំណាងគ្រប់ជ្រុងជ្រោយក្នុងការសម្រេច ប្រកបដោយតម្លាភាព និងគណនេយ្យភាព ។

I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

1. ចំណុចលេខ១គួរចនេះ: ចៅក្រមស៊ើបសួរត្រូវដាក់បញ្ចូលឈ្មោះបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ។

2. ចំណុចលេខ២គួរចនេះ: ចៅក្រមស៊ើបសួរត្រូវសរសេរសង្ខេបពីអង្គហេតុនៃរឿងក្តី។

3. ចំណុចលេខ៣គួរចនេះ: ចៅក្រមស៊ើបសួរត្រូវសង្ខេបពីសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ២ឬ៣ បន្ទាត់ដាក់បញ្ចូល។ តើតំណាងអយ្យការមានសំអាងអ្វីខ្លះ ដែលស្នើសុំឲ្យឃុំខ្លួន ឬ មិនឲ្យឃុំខ្លួន ធ្វើយ៉ាងនេះដើម្បីបង្ហាញថា ចៅក្រមស៊ើបសួរបានពិចារណាទៅលើមូលហេតុដែលតំណាង អយ្យការបានលើកឡើង។

4. ចំណុចលេខ៤គួរចនេះ: ចៅក្រមស៊ើបសួរត្រូវធ្វើសេចក្តីសង្ខេបពីការកត់សម្គាល់ ឬ ការអះអាង របស់ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ២ឬ៣ បន្ទាត់។

II. សំអាងហេតុសេចក្តីសម្រេច ៖

5. ចំណុចលេខ៥គួរចនេះ: ចៅក្រមស៊ើបសួរត្រូវតែប្រាកដថាជនត្រូវចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ (យោងតាមមាត្រា២០៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរត្រូវពិនិត្យមើលថាប្រសិនបើរកឃើញពិរុទ្ធភាព ក្រោយពេលសវនាការជនត្រូវចោទអាចទទួលទោសជាប់ពន្ធនាគារស្មើ ឬ លើសពី១ឆ្នាំ ឬ អត់។

6. ចំណុចលេខ៦គួរច ចៅក្រមស៊ើបសួរ ត្រូវសរសេរនូវការយល់ឃើញរបស់ខ្លួនឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលបានលើកឡើងដោយភាគីដូចជា តំណាងអយ្យការ ជនត្រូវចោទ ឬ មេធាវីរបស់ជនត្រូវចោទ។

ទន្ទឹមនេះ នៅក្នុងចំណុចនេះដែរ ចៅក្រមស៊ើបសួរត្រូវបង្ហាញអំពីមូលហេតុនៃការឃុំខ្លួនចំនួនមួយ ឬ ច្រើនដែលមានចែងនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដោយពន្យល់បង្ហាញពីសំអាងហេតុសំរាប់គាំទ្រទៅនឹងមូលហេតុនីមួយៗ ដែលចៅក្រមស៊ើបសួរលើកឡើង ឬ មិនត្រូវយកមកអនុវត្ត ដែលមានជាអាទិដូចខាងក្រោម៖

ក. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវចោទឬទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចបន្តប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសនោះជាថ្មីឬទេ?

ខ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនអាចរារាំងដល់ការគាបសង្កត់សាក្សី ឬជនរងគ្រោះ ឬរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនសមគំនិត - តើមានហេតុផលសមរម្យ ដើម្បីជឿជាក់ថា ជនត្រូវចោទអាចគាបសង្កត់សាក្សី ឬជនរងគ្រោះដែរឬទេ? តើជនសមគំនិតនៅតែមានសេរីភាពឬទេ (មិនបារម្ភពីការត្រូវរ៉ូវគ្នាទេ ប្រសិនបើពួកគេត្រូវបានឃុំខ្លួន)?

គ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចរារាំងជនត្រូវចោទពីការធ្វើអោយខូចភស្តុតាង ឬ តម្រុយជាសម្ភារៈ - តើនៅតែមានភស្តុតាង ឬ តម្រុយជាសម្ភារៈ ដែលនគរបាលមិនទាន់មានដែរឬ ទេ? តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬ បំផ្លាញភស្តុតាង ឬតម្រុយជាសម្ភារៈ ឧ: អាវុធពាក់ព័ន្ធនឹងបទល្មើសជាដើម?

ឃ. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចធានារក្សាវត្តមានជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី - តើមានហេតុផលសមរម្យដើម្បីជឿជាក់ថា ជនត្រូវចោទអាចនឹងរត់គេចខ្លួន ឬភៀសខ្លួនទៅក្រៅប្រទេសដែរឬទេ?

ង. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួន អាចការពារសន្តិសុខឲ្យជនត្រូវចោទ - តើមានយោបល់ណាមួយដែលថាជនរងគ្រោះ ឬជនផ្សេងទៀតអាចចង់បង្កគ្រោះថ្នាក់ដល់ជនត្រូវចោទ ដែរឬទេ?

ច. ចៅក្រមស៊ើបសួរត្រូវពន្យល់ពីរបៀបដែលការឃុំខ្លួនជនត្រូវចោទ អាចរក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានភាពច្របូកច្របល់ណាមួយដែលបណ្តាលមកពីបទល្មើសនេះ។

ឆ. ចៅក្រមស៊ើបសួរក៏គួរពិចារណាពីធាតុផ្សំ/ហានិភ័យជាសក្តានុពលដើម្បីជាយុត្តិកម្មដល់ការដាក់នរណាម្នាក់ក្នុងការឃុំជាបណ្តោះអាសន្ន ហើយក៏ពិចារណាផងដែរពីធាតុផ្សំដែលអាចបំបាត់ហានិភ័យនេះ ឧទាហរណ៍: ការងារជាប់លាប់នៅក្នុងសហគមន៍ ចំណងគ្រួសារជាដើម។ល។

នៅក្នុងផ្នែកចុងក្រោយនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសន្និដ្ឋានដោយកំណត់ឲ្យច្បាស់ នូវមូលហេតុមួយ ឬច្រើន ក្នុងចំណោមមូលហេតុទាំង៦ ដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ ដើម្បីយកមកអនុវត្តចំពោះរឿងក្តីនេះ និងដើម្បីធ្វើយុត្តិកម្មដល់ការសំរេចរបស់ខ្លួនក្នុងការឃុំខ្លួន។ ក្នុងផ្នែកនេះ ចៅក្រមស៊ើបសួរត្រូវកំណត់ផងដែរ នូវមាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីនេះ។ ថិរវេលានេះ អាស្រ័យលើចរិតលក្ខណៈនៃបទល្មើស និងអាយុរបស់ជនត្រូវចោទ (សូមពិនិត្យមើលតារាងខាងក្រោម)។ នៅទីបញ្ចប់ យោងតាមមាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងថា ជនត្រូវចោទត្រូវមានសេរីភាពនោះ ចៅក្រមត្រូវបង្ហាញថាគ្មានការដាក់កាតព្វកិច្ចណាមួយតាមរយៈការដាក់ឲ្យស្ថិតនៅ

ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អាចនឹងមានលក្ខណ:តឹងរឹងគ្រប់គ្រាន់ ដើម្បីសម្រេចបាន គោលដៅនានា ដូចបានកំណត់នៅក្នុងផ្នែកខាងដើមនោះឡើយ។

ចៅក្រមស៊ើបសួរត្រូវសម្រេចផងដែរ ពីរយ:ពេលអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីនេះ។ តារាងខាងក្រោមបង្ហាញពីថិរវេលាអតិបរមានៃការឃុំខ្លួនបណ្ដោះអាសន្ន សំរាប់ប្រភេទនីមួយៗនៃរឿងក្ដី។

| ប្រភេទនៃបទល្មើស និង មាត្រានៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធ | អាយុជនត្រូវចោទ | ថិរវេលាអតិបរមាដំបូងនៃការឃុំខ្លួន | ការពន្យារថិរវេលាឃុំខ្លួន តាមរយ:ដីកាឃុំខ្លួន មួយទៀត |
|---|---|---|---|
| បទឧក្រិដ្ឋ - មាត្រា២០៨ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៦ខែ | ៦ខែ + ៦ខែ |
| បទមជ្ឈឹម - មាត្រា២០៩ | ១៨ឆ្នាំ ឬចាស់ជាងនេះ | ៤ខែ | ២ខែ - ថិរវេលាសរុបមិនត្រូវលើសពីពាក់កណ្ដាលអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៤ - ១៦ឆ្នាំ | ៤ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈឹម - មាត្រា២១៤ | ១៤ - ១៦ ឆ្នាំ | ២ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទឧក្រិដ្ឋ - មាត្រា២១៣ | ១៦ - ១៨ឆ្នាំ | ៦ខែ | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |
| បទមជ្ឈឹម - មាត្រា២១៤ | ១៦ - ១៨ឆ្នាំ | ៤ខែ ឬ ១/២ នៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សំរាប់ អនីតិជន (ថិរវេលាមួយណាក៏បាន ដែលជាថិរវេលាខ្លីបំផុតរវាងថិរវេលាទាំង២នេះ) | មិនអាចពន្យារពេលឃុំខ្លួនបានឡើយ |

ចៅក្រមស៊ើបសួរគួរធ្វើការកត់សំគាល់ថា ក្នុងករណីបទមជ្ឈិម អប្បបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្ដាល ប្រសិនបើជនត្រូវចោទជាអនីតិជន នៅពេលប្រព្រឹត្តបទល្មើស (មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ)។

ចៅក្រមស៊ើបសួរត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ផ្នែកបញ្ចប់នៃរូបមន្តនេះ គឺជាបង្កាន់ដៃដែលបញ្ជាក់ថាបានប្រគល់ - បុគ្គលដែលបញ្ជូនដីកានេះត្រូវតែចុះហត្ថលេខាលើដីកានេះ ដើម្បីបញ្ជាក់ថាដីកានេះត្រូវបានបញ្ជូនហើយ។ អ្នកទទួលត្រូវចុះហត្ថលេខាលើដីកានេះផងដែរ បន្ទាប់ពីបានទទួល។ ជនត្រូវចោទត្រូវបានគេប្រាប់ឲ្យដឹងអំពីសិទ្ធិប្ដឹងឧទ្ធរណ៍របស់គេ និងពេលកំណត់ប្ដឹងឧទ្ធរណ៍។

ទទួលបានការណែនាំនេះ សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ចាត់វិធានការអនុវត្តឲ្យមានប្រសិទ្ធភាព។

សូមឯកឧត្តម លោក លោកស្រី ប្រធានសាលាដំបូង ព្រះរាជអាជ្ញាអមសាកាដំបូងរាជធានី ខេត្ត ទទួលនូវការរាប់អានអំពីខ្ញុំ ។ ៕

រដ្ឋមន្ត្រី

អង្គ-វង្សវឌ្ឍនា

ភ្ជាប់ :

- គំរូរូបមន្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ០១ច្បាប់

ចម្លងជូន :

- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍

"ដើម្បីជូនជ្រាប"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមានលោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដឹកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់ភ្លៅស្ប៉ោរ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្ដាយឈ្មោះ (ស្លាប់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្ដាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 កូរ៉េ ផ្លើស ពណ៌ក្រហម ទៅឈ្មោះ ខ្ញីយកជិះទៅធ្វើសកម្មភាពគាស់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទ័ហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្ដង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្ដាប់ សាម៉ីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្ដិតស្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៤៥៩៦ អ.យ.ទ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[1] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយពាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្ដីឈ្មោះ ហៅ (គេចខ្លួន)

បានប្រព្រឹត្តអំពើដូចតទៅ[2] ÷

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY ១០០ Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្ដោងរ៉ឺម៉ក

---

[1] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[2] សេចក្ដីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ មកឈរប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពយកទួឡីវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ បានយកប្រាក់ចំនួន ៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ ។ ចំណែកជនសង្ស័យឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ ឈ្មោះ ហៅចយ ឈ្មោះ ឈ្មោះ និងឈ្មោះ ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

- បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១- ភេទប្រុស អាយុ១៨ឆ្នាំ (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៨]៖ .......................................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៩]៖

១- ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន)

២- : ហៅ _ ភេទប្រុស (គេចខ្លួន)

៣- . ភេទប្រុស (គេចខ្លួន)

៤- . ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន)

ពីបទ៖ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- . ភេទស្រី ពីបទ ទទួលផលចោរកម្ម

- ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖
  - បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
  - ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
  - រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

[៨] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៩] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៨៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤]៖ ........................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[៥]៖

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- ភេទស្រី ពីបទ ទទួលផលចោរកម្ម

- ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖
  - បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
  - ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
  - រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

---

[៤] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥

# ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្តោះអាសន្ន

យើង .. ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៥៥៤. អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ ដែលបើកការស៊ើបសួរពីបទ៖ សមគំនិត និងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តហិង្សា។
- បានឃើញដីកាបញ្ជូនឲ្យឆ្លើយរបស់ចៅក្រមស៊ើបសួរចុះថ្ងៃទី ........ ខែ........... ឆ្នាំ...............
- បានឃើញមាត្រា ២០៣, ២០៥, និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ដោយហេតុថា ការឃុំខ្លួនបណ្តោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី

☐ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

☐ រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការ ត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

☐ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

☐ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

☐ ការពារសន្តិសុខឲ្យជនត្រូវចោទ

☐ ធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស

យល់ឃើញថា ÷

ការឃុំខ្លួនបណ្តោះអាសន្នជាមធ្យោបាយសំរាប់បញ្ចប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះ សណ្តាប់ធ្នាប់សាធារណៈ ដោយមូលហេតុ៖

☐ ភាពធ្ងន់ធ្ងរនៃបទល្មើស

☐ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស

☐ ទំហំនៃព្យសនកម្មដែលបង្កឡើងដោយបទល្មើស

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នលើ

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៨ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

(៣១)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥
លេខ : ៦៣ អ.យ.ទ

# ដីកាសន្និដ្ឋានស្ថាពរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ សំណុំរឿងស៊ើបសួរលេខ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ២១១៦៩ ត.ព្រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា

១. គោត្តនាម-នាម ភេទប្រុស <u>អាយុ១៨ឆ្នាំ</u> ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរវើសអេតចាយ នៅ លើវ ឪពុកឈ្មោះ "ស្លាប់"ម្ដាយឈ្មោះ "រស់"ទោសពីមុន "គ្មាន"ជា<u>អនីតិជន</u>។

២.គោត្តនាម-នាម : ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) កើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) កូនគ្មាន ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៤.ឈ្មោះ : ភេទប្រុស(គេចខ្លួន)

៥.ឈ្មោះ ភេទប្រុស(គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់ភ្នំពេញថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរើសអេតចាយ នៅ លីវ ឪពុកឈ្មោះ រស់ ម្តាយឈ្មោះ ស្លាប់ ទោសពីមុន គ្មាន ជាអនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧. ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តីឈ្មោះ ហៅ (រ) កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

**ឃើញថា**

កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣ម១៥នាទី ទាបភ្លឺជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ ហៅ , ឈ្មោះ ឈ្មោះ និង ឈ្មោះ បានជិះម៉ូតូម៉ាក CITY 100PLUS ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពយកទួឡឺវីសឆ្កឹះសោរទ្វារខាងមុខ ចំណែកជនត្រូវចោទឈ្មោះ បានឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ចំនួនប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនត្រូវចោទបានគេចខ្លួនទៅផ្ទះរបស់ជនត្រូវចោទឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន១លានរៀល។ ក្រោយមកជនត្រូវចោទឈ្មោះ បានយកប្រាក់ចំនួន៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ។ ចំណែកជនត្រូវចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការ

ស្រាវជ្រាវ ហើយឃាត់ខ្លួនជនត្រូវចោទពីរនាក់មានឈ្មោះ និង ឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។ 3:/6

បានឃើញរបាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ (ឃាត់ខ្លួន) និងបក្ខពួកឈ្មោះ ,ឈ្មោះ , ឈ្មោះ និង ឈ្មោះ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីវេលាម៉ោង ០៣ម១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនស៊ីហ្គាទេសចរណ៍ និង ពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន។ ចំណែកជនត្រូវចោទឈ្មោះ (ឃាត់ ខ្លួន) ពិជាបានសមគំនិត ផ្ដល់ជាមធ្យោបាយធ្វើសកម្មភាព និង ទទួលផលចោរកម្ម ក្នុងករណីនេះប្រាកដមែន រីឯឈ្មោះ (គេចខ្លួន) ដែលជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្ម ក្នុងករណីនេះផងដែរ។

បានឃើញចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ .... បានឆ្លើយនៅសមត្ថកិច្ចថា ៖កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុនរបស់ខ្លួន មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសំរាកនៅផ្ទះ។ លុះដល់ម៉ោងប្រហែល ០៤ម០០នាទី ទៀបភ្លឺចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសំរាក ក៏មានសមត្ថកិច្ចទូរស័ព្ទមកប្រាប់ខ្លួនថា ក្រុមហ៊ុនរបស់ខ្លួនត្រូវបានចោរគាស់ទ្វារ ពេលនោះ ខ្លួនក៏បានមកមើល ទើបដឹងថា បាត់ទូដែកចំនួន០១ ហើយក្នុងទូដែកនោះមានប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន ២លានរៀល ឯកសារប្លង់ដីមួយចំនួន សៀវភៅធនាគារចំនួន០៣ក្បាល និង បាត់ម៉ាស៊ីនស្កេនចំនួន០១គ្រឿងផងដែរ។

បានឃើញចម្លើយរបស់សាក្សីឈ្មោះ /បានឆ្លើយនៅសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុន ត្រលប់ទៅផ្ទះសំរាក ដោយខ្លួនបានចាក់សោរទ្វាក្រុមហ៊ុនត្រឹមត្រូវ។ លុះទៀបភ្លឺថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា នៅក្រុមហ៊ុនមានចោរចូលគាស់ទ្វា ពេលនោះខ្លួនក៏ប្រញ៉ាប់មកក្រុមហ៊ុន រួចទើបដឹងថាចោរលួចយកទូរដែក០១ នៅក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន។

បានឃើញចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០៣ម ១៥នាទី ខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្ដុំទួលស្វាយព្រៃ ដោយលួចបានទូរដែកប្រាកដមែន។ មុនដំបូងឈ្មោះ ( ) បានយកម៉ូតូ០១គ្រឿងម៉ាកសេ១០០កូរ៉េឆ្លើសពណ៌ក្រហម គ្មានស្លាកលេខ ពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉ក ដឹករូបខ្លួន និង បក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ។ ពេលពួកខ្លួនធ្វើដំណើរមកដល់ម្ដុំទួលស្វាយព្រៃ ក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោរនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនក៏បានយកទុលឡឺវីសមកឆ្កឹះសោរសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោរទ្វាខាងក្នុង រួចនាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយ និងលួចយកបានទូរដែក០១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉ក ទៅផ្ទះរបស់ឈ្មោះ

ដើម្បីគាស់ បានឃើញលុយដុល្លារជាច្រើន និង ឯកសារផ្សេងទៀត ហើយចែកលុយគ្នា ដោយខ្លួនទទួលបានប្រាំមួយពាន់ដុល្លារ រីឯឯកសារទាំងនោះត្រូវបានដុតចោល។ បន្ទាប់មកខ្លួនបានយកលុយចំនួនបួនពាន់

ដុល្លារទៅធ្វើរនិងឈ្មោះ ហើយសល់ប៉ុន្មានខ្លួនទៅចាយវាយនិងចែកអ្នកជិតខាងនៅស្វាយរៀង។ លុះដល់ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី រសៀល ពេលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និង ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ខ្លួនពិតជាបានអោយម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែក ប្រាកដមែន។ មុនដំបូងនៅល្ងាចថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ បានទូរសព្ទមកខ្លួនអោយទៅយកគេនៅម្តុំច្បារអំពៅ ពេលនោះខ្លួនក៏បានជិះម៉ូតូម៉ាក ១០០ កូរ៉េឆ្លើស ពណ៌ក្រហម គ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្លួនជិះ រួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ។ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្លួន គឺម៉ូតូរបស់ខ្លួនមានប្រដាប់សណ្តោងរ៉ឺម៉កស្រាប់។ លុះព្រឹកឡើងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល៧ម០០នាទី ឈ្មោះ បានទូរស័ព្ទមកខ្លួនអោយយកមកម៉ូតូ និង បានឲ្យលុយមកខ្លួនចំនួនមួយលានរៀល។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី ខ្លួនបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និង ឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់មានសមត្ថកិច្ចមកឃាត់រូបខ្លួន និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលខណ្ឌចំការមនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ ខ្លួនពិតជាបានចូលរួមប្រព្រឹត្តអំពើលួចគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ ក្នុងនោះមានឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ ហៅ ។ ពេលនោះពួកខ្លួនលួចបាន ទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិកគត់) ហើយក៏បានចែកគ្នា ដោយរូបខ្លួនបានចំណែកចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិកគត់) លុយសល់ពីនោះ ទុកឲ្យបក្ខពួក៤នាក់ទៀតចែកគ្នា។ ចំណែកទូរដែកនោះ បានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ១៨៤៨៦ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨០៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥១៦៣ គ.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ គ.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៤ គ.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ គ.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៣ គ.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៩ គ.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបញ្ជូនឲ្យឆ្លើយលេខ ២០៩១២ គព្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៥ របសចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨១៣ គព្រ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ ១៨៤៨៩ គព្រ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស។

- របាយការណ៍របស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការចុះស្រាវជ្រាវរកឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ពុំមានស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤នោះទេ។

- លិខិតជូនដំណឹង ឬជូនព័ត៌មានដល់តំណាងអយ្យការលេខ ២០៧៣៧ គ.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធសំណុំរឿង ។

## <u>យល់ឃើញថា</u>

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងចម្លើយសារភាពរបស់ជនត្រូវចោទ រោនភាពស៊ីសង្វាក់ទៅនឹងភស្តុតាងអាចបង្ហាញឲ្យឃើញថា ៖ ជនត្រូវចោទឈ្មោះ ភេទប្រុស ងាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ពិតជាបានប្រព្រឹត្តអំពើឆ្កឹះសោរទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ដើម្បីលួចយកប្រាក់របស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ ភេទប្រុស (គេចខ្លួន), ឈ្មោះ ភេទប្រុស (គេចខ្លួន) និង ឈ្មោះ ភេទប្រុស (គេចខ្លួន) គឺអំពើដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត តាមមធ្យោបាយឆ្កឹះសោទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ ដើម្បីមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសលួចមានស្ថានទម្ងន់ទោស និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> គឺជាអំពើសំរបសំរួលដើម្បីសម្រេចបាននូវសកម្មភាពក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិតតាមមធ្យោបាយឆ្កឹះសោទ្វារក្រុមហ៊ុន

ស៊ុហ្គាទេសចរណ៍ដើម្បីយកប្រាក់ធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ គឺជាអ្នកទទួលផលក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសទទួលផលចោរកម្ម និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ ភេទប្រុស អាយុ២៧ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជានីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជា <u>អនីតិជន</u> ប៉ុន្តែមានលក្ខណៈសម្បត្តិយល់ដឹងធនល្មមក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ និង ឈ្មោះ ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ឈ្មោះ ភេទប្រុស ពីបទៈសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងឈ្មោះ ភេទស្រី ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ។

- តាមលទ្ធផលស្រាវជ្រាវរបស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ រកពុំឃើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤ ទេ។

- យោងតាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧១ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមលើកលែងចោទប្រកាន់លើឈ្មោះ ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ដោយហេតុជនត្រូវចោទនេះពុំសាវតាជាតិពិតប្រាកដ។

## <u>ហេតុដូច្នេះ</u>

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

១. ...... ភេទប្រុស អាយុ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ... ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>(ឃាត់ខ្លួន) ទៅជំនុំជម្រះ។

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤. ភេទស្រី អាយុ២២ឆ្នាំ (គេចខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និង មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

☑ លើកលែងចោទប្រកាន់

- ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )
សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤០៣៩ ចុះថ្ងៃទី ១៣
ខែ តុលា ឆ្នាំ ២០១៥
លេខស៊ើបសួរ ២៦០៥
ចុះថ្ងៃទី ១៥ ខែ តុលាឆ្នាំ
២០១៥ ។

## កំណត់ហេតុស្តីពី
## ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

(មាត្រា ១៥០ និង មាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ )

ឆ្នាំពីរពាន់ដប់ប្រាំ ខែ ធ្នូ ថ្ងៃទី មួយ វេលាម៉ោង ៨ និងសាមសិបនាទីព្រឹក

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងមន្ទីរស៊ើបសួរចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម៖

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ ៤២ ឆ្នាំ ជាតិខ្មែរ មានទីលំនៅកំណើតនៅឃុំ កំពង់ចាម ស្រុកកំពង់ចាម ខេត្តកំពង់ចាម មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ:២៧៩ BE₀ ផ្លូវលេខ ១៨២ ភូមិទី ៨ សង្កាត់ទឹកល្អក់ទី ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ ប្រធានក្រុមហ៊ុន កំរិតវប្បធម៌ ថ្នាក់ទី១២ ប្រពន្ធឈ្មោះ (រ) កូន ០៣ នាក់ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ជានីតិជន ។

**-ជននេះ ចេះនិយាយ ចេះអាន ចេះសរសេរអក្សរខ្មែរ**

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លេខ:**២៥៩៤ អ.យ.ទ** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យើងបានសួរ និងស្តាប់ចម្លើយដូចខាងក្រោមថា៖**

**ស.ឆ:** ពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ពិតជាពាក្យបណ្តឹងដែលខ្ញុំបាទបានធ្វើនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ទួលស្វាយព្រៃទី១ ដោយសមត្ថកិច្ចជាអ្នកសរសេរឲ្យ ហើយខ្ញុំបាទបានផ្តិតមេដៃប្រាកដមែន ។

**ស.ឆ:** ខ្ញុំបាទសូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ នៅម៉ោងប្រហែល ៤ ទាបភ្លឺ សមត្ថកិច្ចប៉ុស្តិ៍នគរបាល បានទូរស័ព្ទមកសួរខ្ញុំបាទបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្ញុំថាតើខ្ញុំបាទពិតជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុននោះមែនឬអត់ ? ដោយគាត់បញ្ជាក់ប្រាប់ថា ឃើញក្រុមហ៊ុនរបស់ខ្ញុំបានត្រូវរបើកទ្វារ និងបែកទ្វារកញ្ចក់ និង ឲ្យខ្ញុំបាទទៅពិនិត្យមើល ភ្លាមនោះ ខ្ញុំបាទក៏បានទៅមើលភ្លាមដែរ នឹងបានឃើញដូចអ្វីដែលសមត្ថកិច្ចបានប្រាប់ខ្ញុំបាទមែន ។ បន្ទាប់ពីបានពិនិត្យមើលឃើញទូរដែករបស់ខ្ញុំមួយត្រូវបានបាត់ក្នុងនោះ ( មានប្រាក់ប្រហែលចំនួន **៥០.០០០ $** ( ប្រាំម៉ឺនដុល្លារអាមេរិក ) និង លុយខ្មែរចំនួន**២.០០០.០០០ ៛,០០** ( ពីរលានរៀល ) ព្រមទាំងឯកសារមួយចំនួន ដូចជា លិខិតផ្ទេរសិទ្ធិប្រើប្រាស់ដីធ្លីមួយកន្លែង និង សៀវភៅធនាគារចំនួន ៣ ក្បាល, ឯកសារពាក់ព័ន្ធនិងក្រុមហ៊ុនរបស់ខ្ញុំបាទហើយរបស់របរផ្សេងទៀតត្រូវរើកកាយ។

ស.ឆ:ក្នុងខណៈនោះ ជនល្មើសពុំទាន់ត្រូវបានចាប់ខ្លួនបានទេ ក្រោយមកទើបសមត្ថកិច្ចកំណត់មុខសញ្ញា ដោយផ្អែកតាមរយៈកាមមីរ៉ាសុវត្ថភាពដែលបញ្ជាក់ពីមុខសញ្ញា និង តាមការពិនិត្យទៅលើក្រយៅដៃ ទើបឈានដល់ការឃាត់ខ្លួនជនល្មើសបាន ។

ស.ឆ: ក្នុងរឿងនេះ ខ្ញុំបាទប្តឹងសុំទាមទារសំណងជាប្រាក់ដែលត្រូវបានបាត់បង់ ចំនួន **៥០.០០០ $** ( ប្រាំម៉ឺនដុល្លារអាមេរិក ) និង លុយខ្មែរចំនួន **២.០០០.០០០ ៛,០០** ( ពីរលានរៀល ) និងសម្ភារៈដែលបានបាត់បង់ជាឯកសារ និងពុំទាមទារសំណងជម្ងឺចិត្តអ្វីពីជនល្មើសទេ តែសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ចុះ ។

យើងបានឲ្យដើមបណ្តឹងអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយដើមបណ្តឹងមិនបានបដិសេធត្រង់ចំណុចណាទេ និង បានចុះហត្ថលេខាជាមួយយើង និង ក្រឡាបញ្ជី ។

| | | |
|---|---|---|
| **ដើមបណ្តឹងរដ្ឋប្បវេណី** | **ក្រឡាបញ្ជី** | **ចៅក្រមស៊ើបសួរ** |

2001-16 34/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ...358......(ព)ដឃដ

# ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំលស្សូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៣ តព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

## យល់ឃើញថា

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្តាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស ។

## ហេតុដូច្នេះសម្រេច

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម២) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ភេទប្រុស អាយុ ១៤ឆ្នាំ រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

បានទទួលដំណឹង

រាជធានីភ្នំពេញថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

ជ. ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

មន្ទីរស៊ើបសួរ ( ៣ )

លេខ ២៤០ ដដ

## <u>ដីកាលើកលែងចោទប្រកាន់</u>

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

**សំអាងហេតុ**

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ......៦៨......អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦

ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី...១០...ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ ៤១ ដ.ជ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្នលេខ៦៩៩,៦៩១,៦៩០(ព)ជឃជ ចុះថ្ងៃទី....១៨.... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ... វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) នៅលីវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលីវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ជាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្តីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ,ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង

ាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១០...ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៤០៣៩
ចុះថ្ងៃទី១៣/១០/២០១៥
ជំនុំជំរះលេខ: ១៩៧
ចុះថ្ងៃទី២២/០១/២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ: ១៤១ ក្រ៨ "ជ"
ចុះថ្ងៃទី២២/០៤/២០១៦

**<u>គាមនាមប្រជារាស្ត្រខ្មែរ</u>**
**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៨.៣០នាទី ព្រឹកដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ប្រធានក្រុមប្រឹក្សា
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ មានជនជាប់ចោទ:

១/ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដើររើសអេតចាយ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក សង្កាត់វាស្សវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)នៅលីវ ជា<u>អនីតិជន</u> ។

-ឃាត់ខ្លួននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៩ ត.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

២/ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ៣៥២៦ តព ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣/ឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ មុខរបរដើររើសអេតចាយទីកន្លែងកំណើតស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក

សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) ជាអនីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៤ តព ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤/ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស)ម្ដាយឈ្មោះ (រ)ប្ដីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន(ក្រៅឃុំ) ។

ដោយមានកញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរជាប្រធានក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍និងពាជ្ជណិ ទីលំនៅកំណើតឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧៩BEo ផ្លូវ១៨២ ភូមិ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់របស់អធិការរដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការរដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរៈលេខ ២០៩ ដ.ដ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

<u>អង្គហេតុដែលត្រូវបានចោទប្រកាន់និងបញ្ជូនមកជំនុំជម្រះ</u>

កាលពី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីទាបភ្លឺជនជាប់ចោទឈ្មោះ ,ឈ្មោះ ហៅ ,ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 PLUS ពណ៌ក្រហមគ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ ដោយមាន សណ្ដោងរ៉ឺម៉កដែលជាកម្មសិទ្ធិរបស់ឈ្មោះ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ិនស៊ីហ្គោលទេសចរណ៍ និងពាជ្ជណិ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសផ្ដិះសោទ្វាខាងមុខចំណែកជនជាប់ចោទឈ្មោះ បានផ្ដិះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួន១ ដែលក្នុងនេះមានប្រាក់ចំនួន

ប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និង ឯកសារប្លង់ដីព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួន១ បន្ទាប់មកជនជាប់ចោទបានគេចខ្លួនទៅផ្ទះរបស់ឈ្មោះ ហើយបានយកប្រាក់ទាំងនេះចែកជាចំណែក ដោយឈ្មោះ ទទួលបានប្រាក់ចំនួន១លានរៀល បន្ទាប់មកជនជាប់ចោទឈ្មោះ បានយកប្រាក់ចំនួន៤,០០០$ផ្ញើទុកនៅនឹងឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទរបស់ឈ្មោះ ។ ចំណែកជនជាប់ចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវហើយឃាត់ខ្លួនជនជាប់ចោទបានចំនួន២នាក់គឺឈ្មោះ និងឈ្មោះ ព្រមទាំងដកហូតបានវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទី ខ្ញុំពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយគ្រឿងម៉ាកសេ១០០ក្បរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉កបានដឹករូបខ្ញុំនិងបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលពួកខ្ញុំធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្ញុំក៏បានឈប់ម៉ូតូហើយខ្ញុំក៏បានយកទួទ្បីវីសមកផ្តិះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ផ្តិះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសារផ្សេងទៀត រួចហើយបានចែកលុយគ្នាដោយខ្ញុំទទួលបានប្រាំពាន់ដុល្លារអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្ញុំបានយកលុយចំនួន៤ពាន់ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានពួកខ្ញុំបានយកទៅចាយវាយនិងចែកអ្នកជិតខាង នៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទីរសៀលខ្ញុំកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ខ្ញុំពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាកដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្ញុំឲ្យយកទៅគេនៅម្តុំច្បាររំពៅ ពេលនោះខ្ញុំក៏បានជិះម៉ូតូម៉ាកសងសេ១០០ ក្បរ៉េផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្ញុំជិះរួចខ្ញុំក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញមូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្ញុំគឺម៉ូតូរបស់ខ្ញុំមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ឲ្យខ្ញុំមកយកម៉ូតូ និងបានឲ្យលុយមកខ្ញុំចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្ញុំបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: ខ្ញុំពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្ញុំលួចបានទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្ញុំ ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្ញុំបានចំនួន១០,០០០$ លុះសល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅពេលសវនាការថា: កាលពី ថ្ងៃទី០៨ខែតុលា ឆ្នាំ២០១៥ ខ្ញុំបានចេញពីក្រុមហ៊ុនរបស់ខ្ញុំមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេល ខ្ញុំកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ខ្ញុំថា ក្រុមហ៊ុនរបស់ខ្ញុំត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្ញុំក៏បាននមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្គេនចំនួន១ផងដែរ នៅក្នុងរឿងនេះខ្ញុំសុំទាមទារប្រាក់ដែលបានបាត់បង់ទៅសរុបចំនួន ៥០,០០០$ លុយខ្មែរចំនួន ២,០០០,០០០រៀល ព្រមទាំងឯកសារផ្សេងៗទៀត ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ . នៅពេលសវនាថា : កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ខ្ញុំបាន ចេញពីក្រុមហ៊ុនត្រលប់ទៅផ្ទះសម្រាក ហើយខ្ញុំបានចាក់សោរទ្វាត្រឹមត្រូវលុះទាមភ្លឺថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្ញុំបានទូរសព្ទ័មកប្រាប់ខ្ញុំថា នៅក្រុមហ៊ុនមានចោរ ចូលគាស់ទ្វា ពេលនោះខ្ញុំក៏ប្រញាប់មកក្រុមហ៊ុន ទើបដឹងថាចោរបានលួចយកទូរដែក១នៅ ក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន ។

-តំណាងយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់ឃើញថា ជនជាប់ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជដោយលួចបានទូរដែកចំនួន១ ហើយនៅក្នុងទូរដែកនេះមានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្គេនចំនួន១ផងដែរ រួចហើយពួកខ្លួនក៏បានយកលុយទៅចែកគ្នាអស់ ចំណែកឯកសារផ្សេងៗពួកគេបានយកទៅបោះចោលអស់ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុក នៅដដែល ដោយជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ

ពីបទ លួចមានស្ថានទម្ងន់ទោស សមគំនិតក្នុងអំពើលួច ដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ .ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩និងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ . ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ បានធ្វើសេចក្ដីសន្និដ្ឋានការពារសិទ្ធិថា : កូនក្ដីរបស់ខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជពិតប្រាកដមែនដូច្នេះសុំឲ្យលោកប្រធានក្រុមប្រឹក្សា មេត្តាជួយសម្រាលទោសឲ្យកូនក្ដីខ្ញុំដោយអនុគ្រោះចំណែកខ្ញុំឈ្មោះ ខ្លួនមិនបានដឹងអីទេសូមឲ្យលោកប្រធានក្រុមហ៊ុន មេត្តាលើកលែងឲ្យកូនក្ដីខ្ញុំរួចខ្លួនពីបទចោទ ។

*-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ*

*-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ*

*-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ*

*-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង*

*-ក្រោយពីបានស្ដាប់សំដីចុងក្រោយរបស់ជនជាប់ចោទ*

*-ក្រោយពីក្រុមប្រឹក្សាបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>យល់ឃើញថា</u>**

១/តាមរបាយការណ៍សំយោគលេខ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការរដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ផ្អែកតាមរបាយការណ៍នគរបាលប៉ុស្តិ៍ តាមពាក្យបណ្ដឹងរបស់ជនរងគ្រោះ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឃើញថាឈ្មោះ និងឈ្មោះ ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (គាស់សោទ្វាក្រុមហ៊ុនលួចទូដែក) កាលពីវេលាម៉ោង៣,១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃ ទី៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនទេសចរណ៍ និងពាណិជ្ជដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BE០ ផ្លូវ៣៤៨ ក្រុម១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែនចំណែកជនជាប់ចោទឈ្មោះ ពិតជាបានសមគំនិត ផ្ដល់មធ្យោបាយធ្វើសកម្មភាព និងទទួលផលចោលរកម្មក្នុងករណីនេះប្រាកដមែនរីឯជនជាប់ឈ្មោះ ដែលជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្មក្នុងករណីខាងលើនេះដែរ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វាក្រុមហ៊ុននៅម្ដុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយ គ្រឿងម៉ាកសេ១០០កុងរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ') មកតកន្ទុយរ៉ឺម៉កខ្លួនបានដឹកបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលខ្លួនធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូហើយក៏បានយកទូឡឺវីសមកឆ្កឹះសោសូឡិចទ្វាខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុង ក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅ ផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាខ្លួនទទួលបានប្រាំពាន់ដុល្លាអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្លួនយកលុយចំនួន៤ពាន់

ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ នៅសល់ប៉ុន្មានខ្លួនបានយកទៅចាយវាយ និងចែកអ្នកជិតខាងនៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣,០០នាទីរសៀលពេលដែលខ្លួនកំពុងអង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមក ឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

៣/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថាៈ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាក់ដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ

បានឲ្យទូរសព្ទមកខ្លួនឲ្យយកទៅគេនៅម្តុំច្បារអំពៅ ពេលនោះក៏បានជិះម៉ូតូម៉ាកសងសេ១០០ កូរ៉េផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានឌុបម៉ូតូខ្លួនជិះរួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ មូលហេតុដែលឈ្មោះ ឌុបម៉ូតូគឺម៉ូតូរបស់ខ្លួនមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ខ្លួនថាឲ្យមកយកម៉ូតូ និងបានឲ្យលុយខ្លួនចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្លួនក៏បានជិះម៉ូតូមកអង្គុយ លេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនជាមួយឈ្មោះ នាំមកតែម្តង ចំណែកឈ្មោះ បាន រត់គេចខ្លួនបាត់ ។

៤/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថាៈ ខ្លួនពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ , ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្លួនលួចបានទូដែក១ យកទៅបើកនៅផ្ទះខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្លួនបានចំនួន ១០,០០០$ លុះ សល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ ។

៥/តាមចម្លើយបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ្លើយថាៈ កាលពី ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ខ្លួនបានចេញពីក្រុមហ៊ុនដែលមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទប្រាប់ថា ក្រុមហ៊ុនរបស់ខ្លួនត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្លួនក៏បានមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ ។

៦/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ,ឈ្មោះ , ឈ្មោះ

បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់បណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីនិងភស្តុ តាងនានានៅក្នុងសំណុំរឿងថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចគាស់ទ្វាក្រុមហ៊ុនស៊ី ហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែន ។

៧/ជនជាប់ចោទមានស្មារតីល្អនៅពេលប្រព្រឹត្តបទល្មើស អំពើប្រព្រឹត្តរបស់ជនជាប់ជាប់ចោទឈ្មោះ , ឈ្មោះ ពី , ឈ្មោះ , និងឈ្មោះ

បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គមយ៉ាង

ធ្ងន់ធ្ងរដែលដែលធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងផ្ទុយទៅនឹងច្បាប់កំណត់ ។

៨/ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជាអនីតិជនតុលាការគប្បីពិចារណាពីស្ថានសម្រាល ។

៩/តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១០/មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ , ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

១១/វត្ថុចាប់យកមាន:

១១.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខៗម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្ប) និង អង្គចងចាំចំនួន១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

១១.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន១តុលាការគប្បីសម្រេចរឹបអូស ។

១២/ដើមបណ្តឹងសុំទាមទារសំណង ជាប្រាក់ដែលបានបាត់បង់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ,លុយខ្មែរចំនួន២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈដែល បានបាត់បង់ជាឯកសារ តុលាការគប្បីសម្រេចតាមច្បាប់ ។

**ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ**

**វិនិច្ឆ័យសេចក្តី**

១/ផ្តន្ទាទោស:

១.១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈ ០២ឆ្នាំ (ពីរឆ្នាំ) និងឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៤ឆ្នាំ (បួនឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១សង្កាត់ ទួលស្វាយព្រៃ

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.២/ផ្តន្ទាទោសលើឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.៣/ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាងគារកំណត់តយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុចាប់យកមាន:

២.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្បូ) និង អង្គចងចាំចំនួន១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

២.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដក់គ្រឿងញៀនចំនួន១រឹបអូស ។

៣/បង្គាប់ឲ្យឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណាងដែលបានបាត់បង់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) , លុយខ្មែរចំនួន ២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈ ដែល បានបាត់បង់ជាឯកសារ ទាមទារលើសពីនេះបដិសេធន៍ចោល ។

៤/បង្គាប់ឲ្យចេញដីកាចាប់និងឃុំខ្លួនឈ្មោះ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ខែមេសា ឆ្នាំ ២០១៦ចំពោះមុខជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីទុកសិទ្ធិប្តឹងទាស់ និងបើផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"
រាជធានីភ្នំពេញថ្ងៃទី២២ខែមេសា ឆ្នាំ២០១៦
ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៩១
ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩

សាលដីកា
លេខ: ២៦៧
ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម | ជាប្រធាន |
| ២-លោកស្រី | ជាចៅក្រម |
| ៣-លោក | ជាចៅក្រម |
| ៤-លោក | ជាចៅក្រម |
| ៥-លោក | ជាចៅក្រម |

ក្រឡាបញ្ជី

លោក

តំណាងមហាអយ្យការ

លោក ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៩៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៩១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៩ របស់តុលាការកំពូល។

ពីបទ: នាំពង្រត់ និងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ឃុំកំពង់ស្វាយ ស្រុកសិរីសៅភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧។ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីបង្ក្រាប់អំពើនាំពង្រត់ លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទឈ្មោះ "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ទីលំនៅសព្វថ្ងៃនៅភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបររកស៊ីគ្មាន ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ទោសពីមុនគ្មាន។

-មានមេធាវីលោក និង

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤២ឆ្នាំ ទីលំនៅសព្វថ្ងៃនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរមេផ្ទះទូរស័ព្ទលេខ០១២ ៧០១ ៧១៨ (ត្រូវជាម្តាយជនរងគ្រោះ)។

-ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ១៨ឆ្នាំ មុខរបរសិស្ស។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ ថាកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង១៣:០០នាទី នាងខ្ញុំទើបតែមកពីផ្សារ ចូលផ្ទះភ្លាមក៏លឺស្វរខ្វះជញ្ជាំងក្តារកន្លែងបន្ទប់កូនស្រីរបស់ខ្លួនឈ្មោះ អាយុ១៨ឆ្នាំ លឺដូច្នេះខ្លួនក៏ចូលទៅមើលក្នុងបន្ទប់កូនស្រីរបស់ខ្លួនៗឃើញស្នាមជើងឡើងលើពិដាន ខ្លួនឡើងតាមមើលក៏ឃើញឈ្មោះ ភេទប្រុស <u>អាយុ១៦ឆ្នាំ</u> នៅពួនលើពិដានផ្ទះក្នុងសភាពអាក្រាត ខ្លួនក៏បណ្តេញចេញពីផ្ទះ។ ក្រោយបន្តិចមកខ្លួនទៅផ្សារលុះម៉ោង៣:០០នាទីរសៀល ខ្លួនក៏ត្រលប់មកផ្ទះវិញ ក៏ស្រាប់តែបាត់កូនស្រីនាងខ្ញុំរហូតដល់សព្វថ្ងៃនេះ។

-បានឃើញដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានសម្រេច៖

១-លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស កើតថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩១ ជាតិខ្មែរ កើតនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិ៣ ឃុំព្រះពន្លា ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ មុខរបរនៅផ្ទះ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ទោសពីមុនគ្មាន ពីបទរំលោភសេពសន្ថវៈ និងនាំព្រត់មនុស្ស ប្រព្រឹត្តនៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៧ តាមមាត្រា៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើនាំពង្រត់លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស។

២-ឲ្យឈ្មោះខាងលើមានសេរីភាពឡើងវិញ ប្រសិនបើឈ្មោះនេះ មិនត្រូវបានចោទប្រកាន់ពីបទល្មើសអ្វីផ្សេងទៀត។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ គ្រប់ចំនុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈគួរគប្បីឲ្យរួចពីការចោទប្រកាន់ និងសុំឲ្យតម្កល់ដីកាលើកលែងចោទប្រកាន់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់លេខ៣៥៧ ដសលច ចុះថ្ងៃទី១០ ខែកក្កដាឆ្នាំ២០០៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសនាពេលសវនាការអសាធារណៈនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

-ទទួលបណ្ដឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តា ពិនិត្យនិងសំរេចតាមច្បាប់។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី ការពារជនជាប់ចោទឈ្មោះ នាពេលសវនាការថា៖កូនក្ដីខ្ញុំជាមួយ ពិតជាស្រលាញ់គ្នាពិតប្រាកដគ្មានការរំលោភទេ ព្រោះ បានឆ្លើយថានាងខ្ញុំ និង បានស្រលាញ់គ្នាយូរហើយ កូនក្ដីខ្ញុំជាមួយនាង បានស្រលាញ់គ្នាតាំងពីឆ្នាំ២០០៦ តែដោយសារការបង្គាប់លុយក្នុងការរៀបការ ខាងស្រីបានឲ្យកូនក្ដីខ្ញុំបង់លុយក្នុងការរៀបការច្រើនពេក តែកូនក្ដីខ្ញុំមានតែ៥០០$ ទើបបានខាង ស្រីប្ដឹងចោទថាកូនក្ដីខ្ញុំចាប់រំលោភ។

សំណូមពរ: តម្កល់សាលដីការបស់សាលាឧទ្ធរណ៍។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារឲ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>តុលាការកំពូល</u>**

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៧២ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៨ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា តាមកំណត់ហេតុសួរចម្លើយចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ របស់តុលាការខេត្តបន្ទាយមានជ័យ ក៏ដូចជានាពេលសវនាការនៅតុលាការអង្គសេចក្ដីផងដែរ ឈ្មោះ និងឈ្មោះ បានឆ្លើយប្រាប់តុលាការថាពួកខ្លួនទាំងពីរនាក់បានស្រលាញ់គ្នាពិតប្រាកដមែនដោយគ្មានការបង្ខិតបង្ខំ ឬគំរាមកំហែងអ្វីឡើយ ហើយឪពុកម្ដាយអ្នកទាំងពីរក៏បានដឹងឮថាអ្នកទាំងពីរបានស្រលាញ់គ្នាដែរ មូលហេតុដែរឈ្មោះ និងឈ្មោះ ព្រមព្រៀងគ្នារត់ចេញពីផ្ទះនោះដោយសារតែ ឪពុកម្ដាយមិនព្រមរៀបការឲ្យពួកគេ ហើយសព្វថ្ងៃនេះអ្នកទាំងពីរកំពុងរស់នៅជាមួយគ្នាជាប្ដីប្រពន្ធទៀតផង។ ដូច្នេះឃើញថាពុំមានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទពីបទ: នាំពង្រត់ និងរំលោភសេពសន្ថវៈដូចពាក្យបណ្ដឹងចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ នោះទេ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចមកនេះ ត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ១៧២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ របស់ឈ្មោះ

។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៥"ស" ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ២០១២ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២។

ប្រធាន ចៅក្រម ចៅក្រម ចៅក្រម ចៅក្រម ក្រឡាបញ្ជី

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០១២

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ [illegible] ឆ្នាំ២០១២

ជ. ប្រធាន[illegible]

អនុប្រធាន

# ឯកឧត្តមរដ្ឋមន្ត្រី វង សូត អញ្ជើញចុះពិនិត្យសមិទ្ធិផលចំនួន ៣ នៅឃុំបារគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

បណ្ណាល័យរូបភាព | ព័ត៌មានថ្មីៗ

ខែឧសភា 26, 2021 | ចំនួនទស្សនា៖ 178

ណ្ដាល៖នាព្រឹកថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការអមដំណើរពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ និងមានការអញ្ជើញចូលរួម ពីសំណាក់ ឯកឧត្តម គង់ សោភ័ណ្ឌ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល អញ្ជើញចុះពិនិត្យមើលនូវសមិទ្ធផលធំៗចំនួន ៣នៅក្នុងភូមិសាសស្ត្រឃុំបារគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

សមិទ្ធិផលទាំងនោះរួមមាន៖ ទី១.ការបង្កើតមណ្ឌលថែទាំ និងស្ដារនីតិសម្បទា ជនវិបល្លាសស្មារតី ដែលបានបើកដំណើរការមួយរយៈមកនេះ ទី.២ មណ្ឌលយុវនីតិសម្បទា ដែលទើបបញ្ចប់ការសាងសង់ និងសមិទ្ធផលទី៣ គឺមជ្ឈមណ្ឌលជាតិព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលកំពុងស្ថិតក្រោមការសាងសង់នៅឡើយ។

ដោយឡែកមណ្ឌលយុវនីតិសម្បទា ជាមណ្ឌលទី១នៅកម្ពុជាដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់យុត្តិធម៌អនីតិជន ដើម្បីផ្ទេរអនីតិជនល្មើសច្បាប់អាយុក្រោម ១៨ឆ្នាំ ចេញពីពន្ធនាគារមករស់នៅ ទទួលបានការបណ្ដុះបណ្ដាលជំនាញផ្សេងៗដាច់ដោយឡែកពីអ្នកល្មើសច្បាប់ដែលមានអាយុចាប់ពីអាយុ១៨ឆ្នាំឡើងទៅ។ តាមគម្រោងនៃការផ្ទេរអនីតិជនល្មើសច្បាប់មកទីតាំងមណ្ឌលយុវនីតិសម្បទានេះ គឺអាចចាប់ផ្ដើមឡើងក្នុងកំឡុងខែមិថុនាខាងមុខ នេះជាការបញ្ជាក់របស់លោក ឌីន បូរី ប្រធាននាយកដ្ឋានយុវនីតិសម្បទា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ លោកបន្តថា ក្នុងដំណាក់ដំណាក់កាលដំបូងនេះ គឺគ្រោងដាក់ចំនួន ១០០ ទៅ២០០នាក់ ដើម្បីសាកល្បង។ ចំណែកលទ្ធភាពផ្ទាល់របស់មណ្ឌលទាំងមូល គឺអាចទទួលអនីតិជនល្មើសច្បាប់ចំនួនរហូតដល់ ២០០០នាក់។ លោកពន្យល់បន្ថែមថា ការផ្ទេរអនីតិជនមកទីតាំងមណ្ឌលនេះគឺមានរយៈពេលកំណត់ ក្នុងករណីអនីតិជនល្មើសច្បាប់ត្រូវបន្តទោសបន្ថែមទៀត គឺពួកគេនឹងត្រូវបញ្ជូនត្រឡប់ទៅពន្ធនាគារវិញ៕